គង្គ ប៊ុនឈឿន



# ំណាព្យស្នេហ៍មាស

អមដោយជីវប្រវត្តពិតរបស់អ្នកនិពន្ធ

.93

គន្ធ ប៊ុនឈឿន

សូមជូន

# កំណាព្យស្នេហ៍មាស

អមដោយ

- ជីវប្រវត្តិសង្ខេបរបស់អ្នកនិពន្ធ
- ប្រវត្តិ បទភ្លេងទំនុកច្រៀង មកដល់ថ្ងៃ 17-04-75
- ខ្លឹមសារសង្ខេបនៃរឿងប្រលោមលោកត្រឹមឆ្នាំ 2000

015870

ការផ្សាយរបស់

បណ្ណាល័យ ឆពណ្ណរង្សី

រក្សាសិទ្ធិគ្រប់បែបយ៉ាង

៚ ឆ្នាំ ២០០១ ៚

# មាតិកា


ទំព័រ

- ឧទ្ទិស ........................................ 3
- គោលបំណង ........................................ 4
- ជីវប្រវត្តិសង្ខេបរបស់អ្នកនិពន្ធ ........................................ 10
- **កំណាព្យស្នេហ៍មាស** ........................................ 29

**ប្រវត្តិដើម-បទភ្លេងនិងទំនុកច្រៀង ដែលជាស្នាដៃរបស់លោក គន្ធ ប៊ុនឈឿន**

| ឈ្មោះបទចម្រៀង | ទំព័រ |
|---|---|
| 1. អារសាច់ជូនម្ដាយ ......... | 30 |
| 2. យំមួយពាន់ដង ............ | 33 |
| 3. រសស្នេហ៍ឧត្តម ............ | 34 |
| 4. មួប់ជួងទី ១០ .............. | 36 |
| 5. ស្ពានឈើអភ័ព្វ ............ | 38 |
| 6. ខ្សែទឹកភ្លួច .................. | 42 |
| 7. សម្រស់នាងទេវទូកជរ .... | 43 |
| 8. ស្ពានអូរតាគី ................ | 46 |
| 9. លាហើយសោភីនី ! ...... | 48 |
| 10. រំជួលដងស្ទឹងសង្កែ ....... | 51 |
| 11. មេឃាភ្នំពេញ តារាបាត់ដំបង | 54 |
| 12. ជ្រោះពេជ្រចិន្ដា ............ | 55 |
| 13. ទឹកភ្នែកឪពុក ............... | 57 |
| 14. អនុស្សាវរីយ៍ខ្នងភ្នំសំពៅ.. | 60 |
| 15. នាងដើរទៅណា ? ...... | 63 |
| 16. វិញ្ញាណផ្នូរខ្ញុំ ............... | 64 |
| 17. ជាន់ជើងក្របី ............ | 66 |
| 18. ដួងចិត្តវិយោគ ........ | 67 |
| 19. បណ្ដាំទៅផ្កាស្រពោន ... | 68 |
| 20. នេះឬជីវិត ? ........... | 70 |
| 21. ទាសករស្នេហា .............. | 72 |
| 22. ស្ពានកំពង់ហ្លួង............. | 73 |
| 23. ស្បៃអប្សរា ចំពាំចាណង់ .... | 76 |
| 24. ព្រះគុណម៉ែ . ............... | 78 |
| 25. សែនស្ដាយផ្កាល់ស្នាំ ........ | 79 |
| 26. ប្រទីបខែធម៌ ................ | 82 |
| 27. ជួបភ័ក្ត្រ ជួបស្នេហ៍........ | 83 |
| 28. កម្សោះហុងជាកញ្ញាប៉េសេ. | 86 |
| 29. ចំរៀងមរណៈ.................. | 87 |
| 30. ប្រពន្ធខាំញីថ .................. | 89 |
| 31. សែនឈឺចិត្ត .................. | 91 |
| 32. ស្នាមក្រេមជាប់ថ្ពាល់ ....... | 92 |
| 33. ស្នែកអូនលាបងហើយ ..... | 93 |
| 34. អូរជ្រៅរណ្ដៅស្នេហ៍ចាស់.. | 94 |
| 35. សម្លេងចាបត្រចាប់ស្នេហ៍ចាស់ | 95 |
| 36. ទឹកភ្នែកស្រីហ្លួរ.............. | 98 |
| 37. កូនស្រីអ្នកនេសាទ ........... | 99 |
| 38. រាហូចាប់ច័ន្ទ.................. | 102 |
| 39. ភ្លេងមង្គុរាជ ..................... | 105 |
| 40. មន្តស្នេហាបង.............. | 106 |

| ឈ្មោះបទចម្រៀង | ទំព័រ |
|---|---|
| 41. លាហើយស្ទឹងម៉ាត្រា .......... | 107 |
| 42. បួតសណ្ដែក.................. | 110 |
| 43. ផ្គរលើប៉ៃលិន.................. | 111 |
| 44. អាទិត្យរះព្យាស៊ីស៊ុរិយាវង្ស.. | 112 |
| 45. សម្លាយកម្ម .................... | 113 |
| 46. ម្លប់ស្នេហ៍ដើមស្រឡៅ ....... | 115 |
| 47. តំនួញហ្វឺតារមាស........... | 118 |
| 48. ជំនោរប៉ៃលិន ................. | 119 |
| 49. បេះដូងកំព្រា ................... | 121 |
| 50. ស្រណោះផ្កាខ្ទុម ............... | 123 |
| 51. ភ្នំចំទ្រទំស្នេហ៍ចាស់........... | 125 |
| 52. ស៊ីចាយលោកឆ្នាំង............. | 128 |
| 53. កណ្ដុរលេងសួន.............. | 131 |

| ឈ្មោះបទចម្រៀង | ទំព័រ |
|---|---|
| 54. សារ៉ាវ៉ាន់ស្លៀកខ្យល់......... | 133 |
| 55. បងដើរកាត់ភ្លៀង............ | 135 |
| 56. ទំនួញស្នេហ៍ព្រះជិនវង្ស.... | 138 |
| 57. កុំទឹងណាំថ្ងៃ................... | 139 |
| 58. ទិញស្រាឱ្យនី !............. | 141 |
| 59. ក្មេងវាយស្បែកជើង........ | 142 |
| 60. ទៅលេងចាត់ដំបង......... | 145 |
| 61. កន្ទ្រឹប ទ្រឹមៗ............... | 146 |
| 62. អ្នកមើល[illegible]......... | 147 |
| 63. ថ្ងៃគោរព[illegible]ស្នេហ៍ចាស់.. | 148 |
| 64. សាយ[illegible]......... | 150 |
| 65. ភូងស្នេហ៍កម្រង.............. | 151 |
| 66. អូនឈឺចិត្តណាស់ !......... | 152 |
| 67. វិជ្ជាច្រាំយ៉ាង................. | 153 |


* **សេចក្ដីបញ្ជាក់**


- ប្រលោមលោកដែលមិនទាន់បោះពុម្ព .............................................. 159
- ប្រលោមលោកដែលបោះពុម្ពរួចហើយ .............................................. 161
- ប្រលោមលោកដែលបោះពុម្ពមិនទាន់រួច .............................................. 169
- ប្រលោមលោកដែលបោះពុម្ពចេញបន្ត... .............................................. 170
- មកទល់ខែមេសាឆ្នាំ ១៩៧៥ មានសល់ ប្រលោមលោកមួយចំនួនក្នុងរោងពុម្ព .............................................. 177
- វណ្ណកម្មចាប់ពីឆ្នាំ ១៩៧៩ .............................................. 179


គ.ប.ឈ

# ៚ ឧទ្ទិស ៚

សូមឧទ្ទិសសៀវភៅ

កម្រង "កំណាព្យស្នេហ៍មាស" នេះ

ដល់វិញ្ញាណខ័ន្ធ របស់

លោក **ស៊ីន ស៊ីសាមុត**

លោក **ហាស់ សាឡុន**

លោក **ទ៉ោយ ហួរ**

លោក **ម៉ែរ ប៊ុន**

លោក **ម៉ក់ ឈួន**

លោក **អ៊ុច ណារី**

លោក **គួច គេច**

អ្នកស្រី **រស់ សេរីសុទ្ធា**

អ្នកស្រី **ប៉ែន រ៉ន**

ដែលបានរួមប្រយុទ្ធ តស៊ូជាមួយខ្ញុំ លើពិភពតន្ត្រី និងជួយធ្វើអោយស្នាដៃ បទភ្លេងទំនុកច្រៀងរបស់ខ្ញុំទាំងអស់បានសំរេចឡើង និងមានជីវិតរហូតមកទល់សព្វថ្ងៃនេះ...

**គ,ប,ឈ**

# គោលបំណង

សៀវភៅនេះ គឺជាកំណត់ហេតុស្នាដៃរបស់ខ្ញុំ ។

អាចនិយាយម្យ៉ាងទៀតក៏បាន គឺវាជាកម្រងវណ្ណកម្មទាំងអស់ តាំងពីពេលដែលខ្ញុំឈោងដៃចាប់ផងចាក្កា ប្រឡូកក្នុងជីវិតទឹកខ្មៅ រហូតមកទល់ពេលនេះ ដូចជា**ប្រលោមលោក កំណាព្យ បទភ្លេង ទំនុកច្រៀង និងរឿងភាពយន្ត ជាដើម** ។

ខ្ញុំចងក្រងសៀវភៅនេះ ក្នុងគោលដៅបីយ៉ាងគឺ ÷

**មួយ** - ចង់រក្សាទុកនូវផ្នត់គំនិតរបស់ខ្ញុំ ដែលទោះបីជាវាមានរសជាតិយ៉ាងណា ក៏វាជាផលចំណែកនៃការត្រិះរិះពិចារណាមួយ ។

• អ្វីទាំងអស់វាហូរចេញពីមនោសញ្ចេតនា ហើយមនោសញ្ចេតនារបស់ខ្ញុំនេះ សឹងបានមកពីការរំភើបជាក់ស្ដែង តាមរយៈការឆ្លុះបញ្ចាំង[illegible]ជីវិតរស់នៅពិតៗ របស់មនុស្សក្នុងសង្គម ។

ខ្ញុំសូមនិយាយថា សំនួនវោហារមួយម៉ាត់ៗ ដែលពិរោះមានន័យ ពាក្យពេចន៍មួយឃ្លាដែលប្រកបដោយគតិបណ្ឌិត ឬប្រលោមលោកមួយខ្សែ ដែលមានសាច់រឿងរណ្ដំទាក់ទងគ្នាពិរោះជក់អារម្មណ៍ មិនអាចកើតងាយៗបានដោយគ្រាន់តែយកដៃគងថ្ពាស់គិតមួយស្របក់ ឬទាញស្លាបចាក្កាសរសេរពីរបីខ្ទាកនោះឡើយ ។ វាសុទ្ធជាផលចំណែកនៃការត្រិះរិះពិចារណាសារចុះសារឡើង រាប់សិបដង និងការវិភាគថ្លឹងថ្លែងយ៉ាងប្រុងប្រយ័ត្ន ទើបអាចសំរេចចេញជាអ្វី ដែលនៅក្រោមក្រសែភ្នែកលោកអ្នកអានបាន ។

និយាយនេះ ខ្ញុំមិនមែន ចង់លើកពីភាពអស្ចារ្យនៃការនិពន្ធនោះឡើយ ប៉ុន្តែធាតុពិត **ការស្រាវជ្រាវរុករកគំណប់គំនិតនៅក្នុងជីវិត មានពេលខ្លះអាចលំបាកច្រើនជាងការផ្សងព្រេងរុករកកំណប់ត្បូងពេជ្រ នៅក្នុងរូងភ្នំ ឬបាត**

សមុទ្រនៅឡើត" ។

កំណប់គំនិតនេះ... ដូចកាលពេលស្រាវជ្រាវរុករក វាមិនព្រមផុះចេញ ទាល់តែសោះ តែលោជាវាផុះចេញ ក៏ផុះចំពេលដែលយើងមិនបានព្រាងទុក គឺផុះចេញពេលយើងភ្ញាក់ពាក់កណ្ដាលអាធ្រាត ពេលកំពុងជិះកង់ ពេលកំពុងជិះស៊ីក្លូ ជិះឡាន ជិះយន្តហោះ ពេលអង្គុយមើលកុន ពេលកំពុងញុំាបាយ ឬពេលកំពុងផឹកស្រាស្រវឹងស្រៀង។ ស្ដាប់ភ្លេងនៅក្នុងបារជាដើម ។ល។

ដូច្នេះ ពាក្យមួយឃ្លាឬសាច់រឿងមួយចប់ ដែលអ្នកនិពន្ធប្រមូលចងក្រងយកមកដាក់ក្នុងសៀវភៅ ទន្ទឹមនឹងពេលដែលអ្នកដទៃមិនបានគិតនោះ តើវាមានតំលៃប៉ុណ្ណា ខាងផ្លូវគំនិត ? វាមានអាយុប៉ុន្មានឆ្នាំទៅមុខ និងបំរើប្រជាជនបានប៉ុន្មាននាក់ ? ហើយអាចមានឥទ្ធិពលសាយភាយដល់ព្រំដែនណា ?។

នៅពេលនេះ ខ្ញុំមិនបាននិយាយថា អ្វីដែលខ្ញុំបានគិតឃើញនិងសរសេរទុកនោះ វាមានតំលៃខ្លាំងក្លាដូចជាកំណប់គំនិតមាសរបស់អ្នកប្រាជ្ញនានានោះឡើយ តែខ្ញុំយល់ឃើញដូច្នេះវិញ ទោះបីជាគំនិតខ្ញុំមានលក្ខណៈយ៉ាងណាក្ដីក៏យ៉ាងហោចណាស់ វាបានរួមចំណែកខ្លះ។ ក្នុងការជួយលើកតំកើងនៀនវប្បធម៌ អក្សរសាស្ត្រជាតិផ្នែកអក្សរសិល្ប៍ និងបានបំរើមនោសញ្ចេតនាប្រជាជនក្នុងជំនាន់ដែលខ្ញុំរស់នៅ ឬប្រៀបដូចជាខ្ញុំបានដាំឈើមួយដើម ទុកសំរាប់ឱ្យអ្នកក្រោយជ្រកម្លប់យ៉ាងនោះដែរ ។

**គោលដៅទីពីរ**របស់ខ្ញុំ គឺចង់ឱ្យអ្នកអានទាំងអស់ ដឹងពិតប្រាកដថា ពេលដែលខ្ញុំរស់នៅ តើខ្ញុំបានធ្វើអ្វីខ្លះ ? ។ ខ្ញុំគ្មានលទ្ធភាពនឹងប្រមូលស្នាដៃគ្រប់ប្រភេទរបស់ខ្ញុំ យកមកបង្ហាញជាក់ស្ដែងឱ្យអ្នកអានឃើញនៅពេលនេះទេ ព្រោះឆ្លងកាត់របបនយោបាយប្រែប្រួលរបស់ប្រទេសជាតិ ស្នាដៃប្រលោមលោករបស់ខ្ញុំ ស្ទើរតែទាំងអស់ត្រូវរបបប៉ុលពតដុតបំផ្លាញចោល បើនៅសល់។ តែបទភ្លេង ទំនុកច្រៀងនិងសាច់រឿងខ្សែភាពយន្តឬខ្សែវីដេអូខ្លះ' ដែលខ្ញុំបានស្ដាប់បានជំនាន់ក្រោយ ។

ក្នុងមួយជីវិតរបស់ខ្ញុំៗពិតជាគ្មានទ្រព្យសម្បត្តិអ្វី ឱ្យប្រសើរថ្លៃថ្លាលើសពីកូនសៀវភៅមួយនេះ ដែលប្រៀបដូចជាមតកឯកសារប្រចាំគ្រួសារ ទៅថ្ងៃក្រោយនោះឡើយ ។

ចំពោះស្នាដៃប្រលោមលោក ក្រោយថ្ងៃរំដោះ ៧មករា ខ្ញុំបានស៊ើបដឹងខ្លះថា មាននៅសល់ខ្លះដែរ គឺកប់នៅតាមផ្ទះប្រជាជន ឬកន្លែងជួលសៀវភៅផ្សេងៗ ប៉ុន្តែមិនងាយទឹងតាមដានស្រាវជ្រាវរកឡើយ ។ តាមប្រភពពត៌មានផ្សេងៗទៀត បានឱ្យដឹងថា ស្នាដៃប្រលោមលោកខ្ញុំមួយចំនួន មានសេសសល់តាមបណ្ណាល័យខ្លះ នៅសហរដ្ឋអាមេរិក និងនៅប្រទេសបារាំង ហើយគេបានធ្វើជាអំណោយ ដោយថតជា**មីក្រូហ្វីល** **(MICRO-FILM)**ផ្ញើមកដំកល់ទុកក្នុងបណ្ណាល័យជាតិយើង ។

ដោយមិនអាចប្រមូលរកសៀវភៅទាំងអស់ មកទុកជាឯកសារបាន ទើបនៅក្នុងសៀវភៅនេះ ខ្ញុំបានរាយឈ្មោះស្នាដៃទាំងអស់ ដោយដាក់លំដាប់ឆ្នាំនៃការបោះពុម្ព និងបានសង្ខេបនូវខ្លឹមសារនៃរឿងនិមួយៗ ដែលខ្ញុំនៅចាំបានគ្រាន់ទុកជាការឆ្លុះបញ្ចាំងឱ្យឃើញនូវផ្នត់គំនិត ដែលខ្ញុំចង់និយាយ ។

ស្នាដៃទាំងនោះ ពិតជាមាននិន្នាការប្លែកៗទៅតាមសង្គមនិមួយៗ ព្រោះវាឆ្លុះបញ្ចាំងចេញពីជីវភាពសង្គម និងរបបគ្រប់គ្រងសង្គម ។ ប៉ុន្តែ ទោះបីជាមាននិន្នាការប្លែកៗយ៉ាងនេះក្តី ក៏ស្នាដៃទាំងនោះនៅថែរក្សាចរិត្តលក្ខណៈពិសេសរបស់វា គឺចរិត្តប្រជាជន ចរិត្តធម្មជាតិ និងផ្សាភ្ជាប់ជាមួយវប្បធម៌អារ្យធម៌ ទំនៀមទំលាប់ប្រពៃណី និងពណ៌សម្បុរជាតិ ។

**គោលដៅទីបី** គឺខ្ញុំចង់បញ្ជាក់ប្រាប់មជ្ឈដ្ឋានមួយចំនួន ដែលបានយកស្នាដៃខ្ញុំទៅប្រើប្រាស់ជាផ្លូវជំនួញ ដោយមិនគោរពសិទ្ធិបន្តិចបន្តួចសោះ របស់អ្នកនិពន្ធដើម ។

ខ្ញុំមិននិយាយពីរឿងប្រលោមលោកទេ ព្រោះវាច្របូកច្របល់ខ្ទេចខ្ទាំក្នុងរបបប៉ុលពត ធ្វើឱ្យបាត់ស្លាកស្លាមច្បាប់ដើម និងច្រឡំបល់ស្ទើររកទីតាំងប្រាកដ

ប្រជាពុំឃើញ ប៉ុន្តែខ្ញុំចង់និយាយពីបទភ្លេង ទំនុកច្រៀង ដែលសព្វថ្ងៃនៅពួស្រស់។ នៅចាក់គ្រប់ម៉ាញ៉េ ឬគ្រប់ច្រកល្ហកទីក្រុងនិងខេត្ត រហូតទៅដល់ប្រទេសក្រៅទៀត ។

បទភ្លេង ទំនុកច្រៀងទាំងនោះ គិតទៅជាងពីររយបទដែលខ្ញុំបាននិពន្ធនិងថតតាំងពីឆ្នាំ ១៩៦៣ រហូតមកទល់ខែមេសាឆ្នាំ ១៩៧៥ ខ្លះផ្សាយតាមវិទ្យុជាតិ ខ្លះថតជាថាស ខ្លះជាកាសែ្សត ហើយខ្លះដកស្រង់ពីប្រលោមលោកនិងបញ្ចូលក្នុងខ្សែភាពយន្ត ។

ប៉ុន្តែ មានបទខ្លះ ថតនិងចាក់ផ្សាយហើយ តែបទខ្លះចេញផ្សាយពុំទាន់ដោយកងទ័ពខ្មែរក្រហមបានចូលមក ម្ល៉ោះហើយកាសែ្សត **MASTER** ដែលម្ចាស់ក្រុមហ៊ុនបានផលិតនោះ មិនដឹងរសាត់អណ្តែតទៅទីណា គួរអោយសោកស្តាយពន់ពេក ។

មុនឆ្នាំ ១៩៧៥ មានអ្នកខ្លះបានទិញយកកាសែ្សតដែលថតហើយទាំងនោះ ទៅស្រុកសៀម ឬស្រុកបារាំង អាមេរិក ។

លុះក្រោយពេល ដែលយើងរំដោះបានពីសម័យប៉ុលពត បទចំរៀងទាំងអស់នោះ ក៏ត្រឡប់ចូលមកស្រុកខ្មែរវិញ តាមរយៈបងប្អូនខ្មែរដែលរស់នៅបរទេស ឬតាមការរត់ពន្ធមកពីស្រុកសៀម ។

មិនតែប៉ុណ្ណោះ បទចំរៀងទាំងនោះត្រូវបានរៀបចំថតសាឡើងវិញ ដោយយកលំនាំបទដើមទាំងស្រុង និងផ្លាស់ប្តូរអ្នកចំរៀងថ្មី ហើយនាំចូលយកមកលក់នៅស្រុកខ្មែរជាបន្តបន្ទាប់ ។

ប្រការមួយទៀត មានអ្នកខ្លះបានយកបទចំរៀងដែលខ្ញុំនិពន្ធទាំងនោះទៅដាក់ក្នុងខ្សែភាពយន្តឬខ្សែវីដេអូ និងថតផ្សំជាចំរៀងកាយវិការ ការ៉ាអូខេចេញលក់ព្រោងព្រាត ដោយឥតមានគិតដល់អ្នកនិពន្ធដើមបន្តិចសោះ ។ **បើថាអ្នកដែលមិនដឹង ក៏ហើយទៅចុះ តែអ្នកដែលដឹងហើយក៏នៅតែបំពាន** ។

ខ្ញុំក៏យល់ដែរថា នៅពេលដែលប្រទេសជាតិយើងពុំទាន់មានច្បាប់ទម្លាប់

ត្រឹមត្រូវ ក្នុងកិច្ច ˝ការពារសិទ្ធិអ្នកនិពន្ធ **(DROITS D'AUTEURS)** ឬ ˝ការពារ សិទ្ធិខាងបញ្ញា **(Propriétés intellectuelles)** នោះពិតជាមានជននិកាសនិយមមួយចំនួន ប្រឹងបឺតជញ្ជក់ញើសឈាមអ្នកនិពន្ធនិងសិល្បករ ដែលមានគំនិតថ្លៃប្រនិត ដើម្បីបំពីផលប្រយោជន៍វប្បធម៌ជាតិ ធ្វើឱ្យអ្នកទាំងនោះបាក់ទឹកចិត្ត ស្ទើរតែអស់ឆន្ទៈបន្តការងារដ៏អភ័ព្វនេះតទៅទៀត ។

ត្រូវតែរាជរដ្ឋាភិបាលចាប់អារម្មណ៍ក្នុងរឿងនេះ ព្រោះវិស័យអក្សរសិល្ប៍ជាមែកធាងមួយនៃវប្បធម៌ជាតិដែរ ។

នៅក្នុងផែនការណ៍ ១០ ឆ្នាំរបស់ពិភពលោក ខាងវិស័យវប្បធម៌ **(Decennie Mondiale)** គេបានបែងចែកច្បាស់ នូវ៤ចំណុចជាវិជ្ជមានថា :

១- ត្រូវដាក់វប្បធម៌នៅក្នុងបេះដូងនៃការអភិវឌ្ឍន៍ **( Placer la culture au cœur du Développement )**

២- ពង្រឹងនិងធ្វើឱ្យសំបូរណ៍បែបនូវអត្តសញ្ញាណជាតិ **( Renforcer et affirmer la Richesse de l'Identité nationale )**

៣- ធ្វើឱ្យការងារវប្បធម៌ ទៅជាការងាររបស់មនុស្សទាំងអស់ **( Faire la Culture pour l'Affaire de Tous )**

៤- ជំរុញវិស័យវប្បធម៌ ឆ្ពោះទៅកាន់សាមគ្គីភាពអន្តរជាតិ **( Relancer la Culture vers la Solidarité international )**

ផ្អែកលើ ៤ ចំណុចជាវិជ្ជមាននេះហើយ ទើបខ្ញុំយល់ថាការងារនិពន្ធ ទោះបីអ្នកខ្លះចាត់ទុកថាជាការងារកំប៉ិកកំប៉ុក មិនប្រសើរដូចការងារស៊ីសំណូកសូកប៉ាន់ ឬលុតក្រាបឡេមឡឺមសុំបុណ្យស័ក្តិក៏ដោយ ក៏ខ្ញុំចាត់ទុកថាវាមានតំលៃពិតប្រាកដខាងវប្បធម៌តទៅថ្ងៃអនាគត ។

អ្នកនិពន្ធភាគច្រើនជាអ្នកក្រ មិនសូវមានទ្រព្យសម្បត្តិខាងក្រៅ សំរាប់បង្អួតសំញ៉ែងឱ្យសង្គមឃើញឡើយ ប៉ុន្តែគេមានធនធានសំបូរណ៍បែបនៅខាងក្នុងដបទឹកខ្មៅ ដែលមិនងាយមានអ្នកណាប្លន់ ឬចាប់ជំរិតយកបានទេ ។

នៅលើមូលដ្ឋានទាំងនេះហើយ ទើបខ្ញុំចាំបាច់ត្រូវតែប្រមូលចងក្រងនូវ

ស្នាដៃទាំងនេះ ដើម្បីទុកជាការបំភ្លឺមួយផ្នែក ចំពោះអ្នកដែលមិនទាន់ដឹង និងអ្នកមានការភ័ន្តច្រឡំ ។

ទន្ទឹមនឹងគោលដៅទាំងបីខាងលើនេះ ខ្ញុំបានដាក់បន្ថែមក្នុងសៀវភៅនេះនូវ "**ជីវប្រវត្តិសង្ខេបរបស់ខ្ញុំ**" ទៀត ។

សូមបញ្ជាក់ថា "**ជីវប្រវត្តិសង្ខេប**" ឬ "**ដំណើរជីវិត**" របស់ខ្ញុំនេះ គឺសរសេរដោយដៃខ្ញុំពិត ព្រោះខ្ញុំយល់ថា បើខ្ញុំមិនសរសេរខ្លួនឯង ធ្វើម្ដេចអ្នកដទៃអាចដឹងបាន ។

ម្យ៉ាង ព្រោះខ្ញុំមិនមែនជារដ្ឋបុរសនយោបាយ ឬជាអ្នកដឹកនាំប្រទេស ដែលមានគេតាមដានតាំងពីកើតដល់ស្លាប់នោះឡើយ គឺខ្ញុំគ្រាន់ជាអ្នកសរសេរធម្មតា ទាល់តែខ្ញុំចងក្រងខ្លួនឯងទើបអស់សេចក្ដី ព្រោះសូម្បីតែក្រុមគ្រួសារខ្ញុំក៏ដឹងមិនច្បាស់ដែរ ។

តែខ្ញុំនិយាយតាមតែការពិត ខ្ញុំធ្វើអ្វីបានប៉ុណ្ណា ខ្ញុំថាប៉ុណ្ណឹង មិនអំនួតអួតអាងបំផ្លើសឡើយ ។

សូមឱ្យសៀវភៅនេះ បាននៅជាឯកសារ សំរាប់អ្នកស្រាវជ្រាវជំនាន់ក្រោយ និងទៅជាចំណងដៃដ៏ស្រងេះស្រងោចបំផុតចំពោះអ្នកនិពន្ធជំនាន់ខ្ញុំ ដែលរស់នៅ ទោះនៅក្នុងឬក្រៅប្រទេសក៏ដោយ ពិសេសគឺសូមឱ្យបានទៅជាកេរមត៌កដ៏មានតំលៃ សំរាប់គ្រួសាររបស់ខ្ញុំ ។

ភ្នំពេញ, ថ្ងៃ ៣១ កក្កដា ឆ្នាំ ២០០០

**គង្គ ប៊ុនឈឿន**

# ជីវប្រវត្តិសង្ខេប

ខ្ញុំ **គង្គ ប៊ុនឈឿន** កើតនៅថ្ងៃ ១៨ តុលា ឆ្នាំ ១៩៣៩ នៅភូមិចំការសំរោង ឃុំចំការសំរោង [១] ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។ ឪពុកឈ្មោះ **គង្គ ឈិន** (មានដើមកំណើតនៅឃុំព្រៃល្វា ខេត្តតាកែវ) ម្ដាយឈ្មោះ **ម៉ារ គីម** (ជាអ្នកឃុំព្រែកហ្លួង ស្រុកសង្កែរ ខេត្តបាត់ដំបង) ។

កាលពីអាយុ ៨ ឆ្នាំ បានចូលរៀននៅថ្នាក់កុមារដ្ឋាន និងបរិវេចនដ្ឋាននៅសាលាវត្តពោធិវាល ។ ចាប់ពីថ្នាក់អាទិកដ្ឋាន រហូតដល់ឧត្តមដ្ឋានរៀននៅមជ្ឈិមសាលាបឋមសិក្សាខេត្ត ហើយបានប្រលងចូលរៀននៅវិទ្យាល័យព្រះមុនីវង្ស រហូតដល់ប្រលងជាប់សញ្ញាប័ត្រមធ្យមសិក្សា ហើយបង្ខំចិត្តឈប់រៀននៅឆ្នាំ ១៩៥៧ ដោយទ័លក្រពេក ។

ឪពុកខ្ញុំ មិនមែនជាអ្នកនិពន្ធ ឬអ្នកអក្សរសាស្ត្រទេ ប៉ុន្តែខ្ញុំបានចាំច្បាស់ថា ពេលដែលគាត់ចាកចេញពីខេត្តតាកែវ មកផ្សងព្រេងនៅខេត្តបាត់ដំបង មានគេនិយាយថា គាត់ចេះភាសាបារាំងជ្រៅជ្រះ អាចសរសេរបាន និយាយបាន និងអាចធ្វើជាគ្រូបង្រៀននៅសម័យនោះបានទៀតផង ។ ប៉ុន្តែ មិនដឹងមូលហេតុអ្វី បានជាគាត់មិនព្រមចូលធ្វើការរដ្ឋ បែរជាស្ម័គ្រចិត្តទៅធ្វើជាកាប៉ូរ៉ាល់ប្រចាំឃ្លាំងស្រែបារាំង នៅតំបន់បឹងព្រីងទៅវិញ ។

សម័យ ដែលបារាំងគ្រប់គ្រងប្រទេសកម្ពុជា គេបានវាតទីយកទឹកដីម្ដុំជើងភ្នំតូច ភ្នំធំ នៅខេត្តបាត់ដំបង ចាប់ពីអូតាគី អូរតាកែ ពពាលខែ ស្រែបារាំង បឹងព្រីង មង្គលបុរី សំរាប់ធ្វើស្រែ ហើយប្រមូលភោគផលស្រូវពីតំបន់

(១)-តាមការពិត ខ្ញុំកើតនៅភូមិបឹងព្រីង ឃុំថ្មកោល (ចរណ្ហីរស្វា) ស្រុកនិងខេត្តបាត់ដំបង ប៉ុន្តែពេលស្រុកមានកលិយុគភ័ន្តប្រែ សំបុត្រកំណើតដើមបាត់អស់ ទើបសំរេចមកចុះជាតិកំណើត នៅឃុំចំការសំរោងវិញ ។

នេះនាំចេញទៅក្រៅ តាមរយៈស្ពានរថភ្លើង ដែលមានស្ថានីយ៍ដឹកជញ្ជូនបោះប្រចាំការនៅឃុំចណ្ដើរស្វា ។

នេះ ប្រហែលមកពីឪពុកខ្ញុំចេះភាសាបារាំង អាចបកប្រែបាន ទើបគេត្រូវការឱ្យគាត់ នៅធ្វើជាអ្នកគ្រប់គ្រងសំភារៈឧបករណ៍កសិកម្មផ្សេងៗ នៅប្រចាំការដ្ឋានស្រែបារាំងនោះ ។

នៅពេលនោះហើយ ដែលគាត់បានជួបនឹងម្ដាយខ្ញុំ ហើយបានឱ្យកំណើតបងប្រុសខ្ញុំម្នាក់ឈ្មោះ **គន្ធ ម៉ុនឆោម** និងរូបខ្ញុំ ។ តែបន្ទាប់ពីកំណើតខ្ញុំ ឪពុកខ្ញុំក៏ឈប់ធ្វើជាកាប៉ូរ៉ាល់ឃ្លាំងស្រែបារាំង ហើយនាំគ្រួសារទៅបោះទីតាំងរកស៊ីលក់ដូរនៅភូមិបាក់អម្រែក ក្នុងឃុំព្រែកហ្លួង ដែលជាទឹកដីកំណើតរបស់ម្ដាយខ្ញុំវិញ ។

រស់នៅទីនោះរហូតដល់ខ្ញុំអាយុបាន ៦ ឆ្នាំ ដោយភូមិស្រុកកើតកលិយុគវឹកវរ ឪពុកខ្ញុំក៏នាំគ្រួសារមកនៅខេត្តបាត់ដំបងវិញ ដោយប្រកបរបររកស៊ីជាអ្នកលក់ដូរធម្មតា ។

នៅសម័យនោះ កម្រមានអ្នកណាចូលចិត្តអានកាសែតណាស់ តែខ្ញុំនៅចាំបានថា ឪពុកខ្ញុំជាអ្នកអានកាសែតបារាំងម្នាក់យ៉ាងខ្ជាប់ខ្ជួន គឺកាសែត Extrème - ORIENT ដែលបោះពុម្ពនៅព្រៃនគរ ។ នៅពីតូច ខ្ញុំតែងត្រូវឪពុកខ្ញុំប្រើឱ្យរត់ទិញកាសែត ពីហាងមួយនៅផ្លូវលេខ ២ ជាញឹកញាប់ ។

ខ្ញុំបានយល់ដឹងពីឪពុកខ្ញុំតែប៉ុណ្ណឹង រហូតដល់គាត់មានជំងឺស្លាប់នៅឆ្នាំ ១៩៥៣ ហើយបន្សល់ទុកនូវគំនរកាសែតពីរបីហឹប និងសៀវភៅសរសេរដៃ ខ្លះជាកំណត់ហេតុកត់ត្រានូវព្រឹត្តិការណ៍ផ្សេងៗ ជាភាសាបារាំង ដែលពេលដោយខ្ញុំមិនអាចយល់បាន ព្រមទាំងអត្ថបទកំណាព្យខ្លីៗលាយជាមួយនឹងធម៌អារ្យ ម្យ៉ាងទៀតខ្ញុំនៅតូច ។

ពាក្យដែលនិយាយថា "**ស្លឹកឈើជ្រុះមិនឆ្ងាយពីគល់**" ប្រហែលជាត្រូវសម្រាប់មនុស្សខ្លះ តែសម្រាប់ខ្ញុំ ផ្ទុយពីពាក្យទំនៀមនេះស្រឡះ ដូច្នេះតើហេតុ

អ្វី ដែលបណ្តាលឱ្យខ្ញុំក្លាយមកជាអ្នកនិពន្ធ នៅពេលនេះ ? ។

ឆ្នាំដែលខ្ញុំកើត ជាឆ្នាំដែលសង្គ្រាមលោកលើកទីពីរ ចាប់ផ្តើមឆេះដង្កោលដង្កុំ ។ សម្លេងអាវុធគ្រប់ប្រភេទ បានលាន់ឮស្ទើរលើងប្រថពី ក៏ដូចជាលាន់ឮនៅលើមាតុភូមិខ្ញុំ... មាតុភូមិដែលធ្លាប់រស់គ្រាំគ្រាក្នុងនឹមផែកអាណានិគម ។

ខ្ញុំកើតចេញពីផ្ទៃម្តាយម្នាក់ ដែលមានសេរីភាពក្នុងការបង្កើតកូន តែខ្ញុំមិនមែនជាទារក ដែលមានសេរីភាពទេ ព្រោះជាទារកដែលកើតក្នុងសម័យអាណានិគម ជាគ្រួសារមួយ ក្នុងចំណោមគ្រួសាររាប់លានដែលខ្ញុំកញ្ចះគេ...។

ច្រមុះខ្ញុំ បានស្រូបយកក្លិនគ្រាប់រំសេវផ្សែងអ្នរអាប់ និងទុក្ខវេទនារបស់គ្រួសារខ្មែរទាំងអស់ តាំងពីថ្ងៃដំបូងនៃជីវិតខ្ញុំ ។

កុមារភាពរបស់ខ្ញុំ ចិតនៅក្នុងក្របខ័ណ្ឌឧត្តមគតិ និងទិដ្ឋភាពនេះទើបនៅពេលដែលខ្ញុំកំពុងរៀន និស្ស័យធម្មជាតិបានជំរុញឱ្យខ្ញុំចូលចិត្តស្តាប់រឿងដែលគេនិទាន ទោះនិទានពីអ្វីក៏ដោយ ។

ខ្ញុំចូលចិត្តស្តាប់ចំរៀងចាប៉ីដងវែង ស្តាប់លោកទេសនាឆ្លងឆ្លើយ ស្តាប់ចាស់ៗនិទានរឿងព្រេងតាមសាស្ត្រាស្លឹករឹត មើលអាយ៉ង អាយៃ មើលល្ខោនបិទមុខ (រឿងរាមកេរ្តិ៍) មើលល្ខោនបាសាក់ ស្តាប់ចំរៀងសង្គីត និងមើលភាពយន្ត ។

ប្រហែលមកពីកត្តាទាំងនេះហើយ ទើបបណ្តាលឱ្យខ្ញុំមានទំនោរស្រឡាញ់ការនិពន្ធ ?

កាលរៀននៅបឋមសិក្សា ខ្ញុំចាប់អារម្មណ៍នឹងរៀនគូរមុនដំបូង ។ ឱ្យតែពេលទំនេរ ខ្ញុំតែងទៅសំកុកមើលជាងគូររូប នៅរោងភាពយន្ត ហាប់-ឈុននៅខេត្តបាត់ដំបង (បច្ចុប្បន្នរោង១៣មករា) និងរោងកុនអេដែន (ឥឡូវនេះគ្មានទេ) ។ ក្រោយមកខ្ញុំខំរៀនគូរតាមរូបកុន ឬរូបភាពផ្សេងៗ ទាល់តែក្លាយជាសិស្សម្នាក់ ដែលពូកែជាងគេនៅក្នុងថ្នាក់រៀន ។

ផ្ដើមពីការគួសវាស និងការចូលចិត្តស្ដាប់រឿង ស្ដាប់ចំរៀងនេះហើយ ដែលធ្វើឱ្យខ្ញុំស្រឡាញ់ពាក្យជួនរណ្ដំ តាមបែបកំណាព្យ និងសំនួនវោហារដែលប្រើប្រាស់ក្នុងល្បះឃ្លាចំរៀង ហើយខ្ញុំក៏រៀនសរសេរកំណាព្យ តាមបែបរឿងនិទានផ្សេងៗ ។ ទន្ទឹមនោះ ខ្ញុំក៏ចាប់អានរឿងរ៉ាវដែរ រហូតដល់រឿងប្រលោមលោកខ្លះៗ ដែលបោះពុម្ពក្នុងសម័យនោះ ដូចជា សូផាត ផ្កាស្រពោន កុលាបប៉ៃលិន ។ល។

ក្នុងមនោសញ្ចេតនា ដែលជក់ជាប់ការឈឺចាប់ និងមើលឃើញភាពក្រខ្សត់នៃគ្រួសារផ្ទាល់ខ្លួន ដែលជួបការលំបាកវេទនាក្នុងការរៀនសូត្រ រួមជាមួយទុក្ខវេទនានៃគ្រួសារដទៃទៀត កាន់តែធ្វើឱ្យខ្ញុំប្រើមនោសញ្ចេតនាត្រិះរិះវិភាគពិចារណាវែងឆ្ងាយ និងស្រមើស្រមៃអណ្ដែតអណ្ដូង ។ ខ្ញុំធម្លាប់ដេកគងថ្ងាសតាំងពីនៅតូច ជាមនុស្សព្រួយបារម្ភច្រើនជាងសប្បាយ និងជាមនុស្សគិតច្រើនជាងនិយាយ ។

ឪពុកខ្ញុំស្លាប់នៅឆ្នាំ ១៩៥៣ ពេលដែលសភាពការណ៍ប្រទេសជាតិកំពុងផ្លាស់ប្ដូរពីការផ្ទេររដ្ឋអំណាចបារាំង មកខ្មែរទាំងស្រុង ។ ចលនាផុសផុលរបស់គណបក្សច្រើនបែប ច្រើនឈ្មោះ ដើម្បីដណ្ដើមប្រជាប្រិយភាពក្នុងការដឹកនាំប្រទេស ។

ការគៀបសង្កត់ រវាងអ្នកនយោបាយគ្រប់ពណ៌សម្បុរ និងការតស៊ូពីក្នុងព្រៃរបស់បណ្ដាចលនាអ្នកស្នេហាជាតិផ្សេងៗ បានក្លាយទៅជាឯកសារស្រស់ៗដ៏មានតំលៃបំផុត សំរាប់លត់ដំខួរក្បាលខ្ញុំ ឱ្យកាន់តែត្រិះរិះពិចារណា ចេះវិភាគពីបញ្ហាសង្គម និងការរាក់ជ្រៅ នៅក្នុងបញ្ហាជីវិត ។

នេះជាសាលារៀនមួយ ក្នុងចំណោមសាលារៀនជាច្រើនទៀត ដែលនាំឱ្យខ្ញុំចេះសរសេរ ។

ប៉ុន្តែ នេះអាចនិយាយបន្ថែមថា ជាទេពកោសល្យនិងឧបនិស្ស័យពីកំណើតមកក៏ថាបាន ព្រោះបើគ្មានសភាវៈទាំងនេះគួបផ្សំផងទេ មិនងាយនឹង

មានអ្វីស្រូបទាញជីវិតខ្ញុំ ឱ្យធ្លាក់ចូលទៅក្នុងលំអាន ផ្លូវមនោសញ្ចេតនានេះឡើយ ។

ដោយសារកត្តាតួបផ្សំទាំងនោះហើយ ដែលបានចង្អុលផ្លូវ នាំដៃឱ្យខ្ញុំឈ្មុសឈ្មុលលើផ្លូវ ដែលពោរពេញដោយក្ដីស្រមៃ និងមិនបានយល់ពីទ្រឹស្តីអ្វីបន្តិចបន្តួចសោះនៃការនិពន្ធ ប្រៀបដូចជាមនុស្សម្នាក់ដែលធ្វើដំណើរផ្សងព្រេង លើមាគ៌ាដ៏ងងឹតងងល់មួយ ។

ជាបណ្ដើរៗ ឧបនិស្ស័យ បានកែប្រែខ្លួនខ្ញុំបន្តិចម្ដងៗ ទៅជាមនុស្សដែលចូលចិត្តបំផុត ក្នុងការបណ្ដែតមនោសញ្ចេតនាឱ្យរវើរវាយ ឬស្រមៃទៅកាន់ភពមួយ ដែលគ្មានអ្នកណាទឹកដល់ ។

ខ្ញុំក៏មិនដែលគិតថា ជីវិតជាអ្នកនិពន្ធ ជួបប្រទះនូវគ្រោះថ្នាក់ ឧបសគ្គរាំងរាំងច្រើនរាប់មិនអស់ដែរ គឺខ្ញុំពេញចិត្តជាងអ្វីទាំងអស់ ។

ជួនកាលខ្ញុំឃើញស្រមោចជញ្ជូនពង ស្លឹកឈើត្រូវខ្យល់បក់រវិចៗ ទាហែលទឹកនៅក្នុងត្រពាំង ស្លឹករាំងឬស្លឹកឫស្សីធ្លាក់រុះរោយក្នុងបឹង នារីស្រុកស្រែចងពុងកណ្ដៀតក្ដមចុះដងទឹកបឹង ដៃនាងល្វតល្វន់យកក្ដមវាចទឹក បង្កើតជាផ្នត់រលកតូចៗ រត់ទៅប៉ះនឹងដើមព្រលិត ធ្វើឱ្យញ័ររញ្ជួយដល់ស្រមោលដើមត្នោត ដែលឆ្លុះចាំងមកជាមួយពន្លឺថ្ងៃក្រហមរៀបអស្ដង្គត... ។ល។

ទិដ្ឋភាពទាំងនេះសាមញ្ញណាស់ ភ្នែកទាំងឡាយ គេមើលឃើញគ្មានន័យអ្វីឡើយ តែសំរាប់ខ្ញុំ គឺជាប្រធានបទដ៏សម្បូរណ៍បែប ដែលមានអត្ថន័យជ្រាលជ្រៅបំផុត នៅក្នុងសោភ័ណភាពនៃបទនិពន្ធ ដ៏អាថ៌កំបាំងដែលគ្មាននរណាទឹកដល់ ។

... ក្រោយដែលឪពុកខ្ញុំស្លាប់ផុត ខ្ញុំកាន់តែរស់គានតឹងមែនទែនជាមួយម្ដាយមេម៉ាយ នឹងបងប្រុសម្នាក់ដែលមានវ័យស្រចាលគ្នា ចេះតែតួញត្អែរក្នុងជីវិត ចេះតូចចិត្ត និងធ្វើឱ្យខ្លោចផ្សា ។

ដោយអាណិតអាសូរ[illegible]យ៉ាងនេះហើយ ខ្ញុំក៏សាកល្បងហាត់

សរសេរកំណាព្យនៅពេលដែលខ្ញុំរៀនថ្នាក់ឧត្តមដ្ឋាន តែកំណាព្យនេះមានលក្ខណៈជាទំនុកច្រៀង ឬជាអ្វីដែលអាចជួយលួងលោមមនោរម្មណ៍ និងបន្ធូរបន្ថយមនោសញ្ចេតនាលំបាក តប់ប្រមល់ក្នុងជីវិតរបស់ខ្ញុំ ។ គួបផ្សំពេលនោះខ្ញុំចេះភ្លេងខ្លះៗនៅក្នុងសាលា ខ្ញុំចេះកាន់ឧបករណ៍ចាប៉ី (ម៉ង់ដូលីន) ច្បាស់ណាស់ ខ្ញុំក៏ឧស្សាហ៍បង្ហូរមនោសញ្ចេតនារបស់ខ្ញុំ ទៅតាមមន្តស្នេហ៍នៃតន្ត្រីនេះ និងតាមរសជាតិកំណាព្យទំនុកច្រៀង លុះត្រាតែក្លាយទៅជាទម្លាប់ ។

កាលណោះក៏មានបទភ្លេងចំរៀងសម័យ ដែលផ្សាយតាមវិទ្យុពីភ្នំពេញទៅបាត់ដំបង តាមរយៈឧត្សោសនស័ព្ទនៃការិយាល័យបណ្ដាញឃោសនាការ នៅជិតរោងកុនសង្កែ (ពេលនេះគ្មានទេ) ដែលខ្ញុំតែងព្យាយាមទៅអង្គុយស្ដាប់រាល់ៗល្ងាច ។

ខ្ញុំពេញចិត្ត អ្នកចំរៀង **ស៊ីន ស៊ីសាមុត** តាំងពីនៅក្មេង ហើយនឹងអ្នកនិពន្ធបទភ្លេងទំនុកច្រៀង **ពៅ ស៊ីផូ** ។ អ្វីៗដែលខ្ញុំបានឮនាសម័យនោះ វាដូចជាជីវជាតិស្រោចស្រព់ ផ្គួរផ្គងរះដួងខ្ញុំ ឱ្យផុះផុះពន្លកមនោសញ្ចេតនាកំណាព្យ ទំនុកច្រៀង កាន់តែរឿងរឿងៗគ្មានស្រកស្រុត ។

ទន្ទឹម នឹងការសរសេរកំណាព្យទំនុកច្រៀង ខ្ញុំក៏ហាត់សរសេររឿងខ្លះៗដោយបានមើលកាសែត ដែលចុះផ្សាយរឿងខ្លីៗនាសម័យនោះ ដូចជាកាសែតកម្ពុជា កាសែតប្រជាជន កាសែតប្រជាធិបតេយ្យ និងកាសែតសង្គមរាស្ត្រនិយម ។ល។ ខ្ញុំបានមើលប្រលោមលោករបស់អ្នកនិពន្ធ **ប៊ីច នៃលាន** ដែលទុកដូចជាប្រទីបបំភ្លឺផ្លូវ ឱ្យខ្ញុំឈានទៅកាន់ជងចាក្ដា សរសេររឿង ។

ជាបន្ថែមទៀត រហូតដល់ចូលរៀន វិទ្យាល័យព្រះមុនីវង្ស ត្រឹមថ្នាក់ទី៥ ខ្ញុំបានសាកល្បងនិពន្ធកំណាព្យទំនុកច្រៀង និងប្រលោមលោកខ្លីៗបានមួយចំនួន ប៉ុន្តែមិនទាន់បានបោះពុម្ព ព្រោះការបោះពុម្ពនៅសម័យនោះតឹងតែងណាស់ បើអ្នកនិពន្ធណាមិនទាន់មានឈ្មោះនៅលើក្របសៀវភៅបោះពុម្ព នោះម្ចាស់បណ្ណាគារ គេមិនទទួលស្គាល់ឡើយ ។

នៅឆ្នាំ ១៩៥៧ ខ្ញុំបានប្រលងជាប់លេខ ១ នៅក្នុងនិកាសមហោស្រព អក្សរសិល្ប៍មួយ ធ្វើនៅក្នុងខេត្តបាត់ដំបង នោះគឺវណ្ណកម្មប្រលោមលោកឈ្មោះថា "**ស្នេហាលុះអចសាន្ត**" ។

ពេលនោះហើយ ដែលខ្ញុំរឹតតែគិតថា អ្វីៗដែលខ្ញុំព្យាយាមកន្លងមក បានចេញជាផ្លែផ្កាខ្លះៗហើយ គឺខ្ញុំបានទទួលប្រាក់ ១៥០០រៀល ជារង្វាន់សម្រាប់ជ័យលាភីលេខ ១ នៅសម័យនោះ ។ ខ្ញុំបានយកទៅឱ្យម្ដាយខ្ញុំទាំងអស់ ជាប្រាក់ដែលខ្ញុំចេះរកបានជាលើកដំបូង នៅក្នុងជីវិត ដោយសារដំណក់ទឹកខ្មៅ។

ទោះបីយ៉ាងនេះក្ដី ក៏បណ្ណាគារនៅក្នុងខេត្ត ពុំទាន់មានបណ្ណាគារណាមួយព្រមទទួលយករឿងថ្មីៗរបស់ខ្ញុំ ទៅបោះពុម្ពឡើយ គេហាក់ដូចជានៅរារែកមិនទាន់ទុកចិត្តថាស្នាដៃខ្ញុំ តើអាចទទួលការពេញនិយមពីអ្នកអាន ឬយ៉ាងណានោះ ? ។

នៅភ្នំពេញទៀតសោត ក៏ខ្ញុំបានសាកល្បងកំពៀកប្រលោមលោកមួយចំនួន ដែលជាស្នាដៃរបស់ខ្ញុំយកមកលក់ឱ្យដែរ តែគ្មានបណ្ណាគារណាមួយទទួលយល់ព្រមទិញឡើយ ។ មិនតែប៉ុណ្ណោះ មានអ្នកខ្លះគេពេបជ្រាយ មើលងាយខ្ញុំទៀត ថាអ្នកនិពន្ធអី រាងសម្រែ នៅក្មេង ស្លៀកតែខោខ្លី អាវកញ្ចាស់ដូច CHOMEUR ។

ក្នុងឆាកជីវិតជ្រុងព្រាង យកប្រលោមលោកមកដើរលក់នៅក្រុងភ្នំពេញ ជីវិតខ្ញុំពេលនោះ ប្រៀបដូចជាស្ងួតផាត គឺបានចូលទៅថ្វាយបង្គំសម្ដេចព្រះសង្ឃរាជជួនណាត ដើម្បីសុំសំណាក់មួយយប់នៅក្នុងវត្តឧណ្ណាលោម មុននឹងត្រឡប់ទៅខេត្តបាត់ដំបងវិញ ។

ពេលនោះ ខ្ញុំមានតែទឹកភ្នែក ដេកអត់បាយ ហើយព្រឹកឡើងសំពះសុំឡានគេជិះត្រឡប់ទៅស្រុក ដោយអង្គុយអោបតែសំណៅប្រលោមលោក ទាំងអាប់អួរក្នុងចិត្ត ។ ប៉ុណ្ណឹងហើយ ក៏ពួកអ្នកបោះពុម្ពនៅក្នុងខេត្ត ក៏គេមិនទទួលស្នាដៃទៀត ខ្ញុំស្ទើរតែអស់សង្ឃឹមម្ដងៗ... ប៉ុន្តែខ្ញុំនៅតែព្យាយាម តស៊ូ

តទៅមុខទៀត... គឺនៅតែសរសេរ... សរសេរហើយសរសេរទៀត... ទោះបីជាជួបប្រទះផ្លូវអាប់អួរក្នុងជីវិតបែបណាក៏ដោយ ។ល។

ទម្ងឹម ពឹងពេលដែលខ្ញុំកាន់តែអស់សង្ឃឹម ម្ដាយខ្ញុំក៏ធ្លាក់ខ្លួនក្រមែនទែន ហើយមានជំងឺជាទម្ងន់ទៀតផង ម្ដាយនិងកូនជួលក្រោមផ្ទះគេជ្រកនៅជិតវត្តពោធិវាល ។

ដោយខ្ញុំ មិនបានល្បោះទៅជាអ្នកសរសេរ ខ្ញុំនៅតែព្យាយាមទៅសូមបំរើឱ្យតូបលក់សៀវភៅមួយ នៅក្នុងខេត្តដោយមិនយកប្រាក់ខែ ដោយសុំឱ្យតែគេអាណិតមេត្តាបោះពុម្ពសៀវភៅ ដែលជាស្នាដៃរបស់ខ្ញុំ ព្រោះគេបានសន្យាច្បាស់លាស់ហើយ ។

ពេលនោះ ខ្ញុំទៅរៀនផង ឆ្លៀតមកបំរើគេផង ព្រមទាំងឆ្លៀតរកថ្នាំមកព្យាបាលម្ដាយដែលមានជំងឺផង ។

ម្ដាយខ្ញុំឈឺទាល់តែស្លាប់ ម្ចាស់តូបលក់សៀវភៅក៏នៅតែមិនព្រមបោះពុម្ពសៀវភៅ ខ្ញុំចាប់ផ្ដើមអស់សង្ឃឹម និងរវើរវាយមែនទែន ហើយពិបាកចិត្តស្ទើរតែរៀនមិនកើត ។

ពេលនោះ ខ្ញុំឆ្លងផុតថ្នាក់ទី ៤ ទំនើបជាតិ ចូលថ្នាក់ទី ៣ ដែលជាឆ្នាំពិសេស ត្រូវប្រឡងយកសញ្ញាប័ត្រទៀតផង តើខ្ញុំត្រូវលះបង់អ្វី ? យកអ្វី ?

ពេលដែលខ្ញុំអស់សង្ឃឹមមែនទែន ថានឹងទម្លាក់ផងចាក់ក្ដាចោលនេះ ស្រាប់តែស្នាដៃប្រលោមលោកមួយរឿងឈ្មោះថា "**កំណត់ទឹកភ្នែកនារី**" ឬ "[illegible]" ដែលខ្ញុំបានផ្ញើតាមរយៈមិត្តម្នាក់ ទៅលក់ឱ្យបណ្ណាគារមួយនៅខេត្តកំពង់ចាម បានបោះពុម្ពចេញ ដោយរហ័សនាមអ្នកនិពន្ធថា គង់-ផាន។

ទោះបីជារឿងនេះ មិនដាក់ឈ្មោះពិតប្រាកដរបស់ខ្ញុំក៏ដោយ ក៏មិត្តភ័ក្តិជាច្រើន គេដឹងថារឿងនេះជារឿងរបស់ខ្ញុំ ព្រោះមុននឹងពឹងឱ្យមិត្តម្នាក់យកទៅលក់នៅខេត្តកំពង់ចាម ខ្ញុំបានកាន់សំណៅរឿងនេះបង្ហាញគេឯងស្ទើរគ្រប់គ្នាទៅហើយ ពិសេសបង្ហាញម្ចាស់បណ្ណាគារនៅក្នុងខេត្ត ដែលកាលណោះ គ្មាន

អ្នកណាម្នាក់គេចាប់អារម្មណ៍ ។

ស្នាបចិត្តខ្ញុំ ដែលប្រុងតែនឹងក្រៀមស្វិតស្រពោនរុះរោយ ពេលនេះបាន ត្រូវទឹកសន្សើមប្រស់ព្រំ ឱ្យមានជីវិតស្រស់បំព្រងឡើងវិញ ។ គ្រប់អ្នកដែល បានអានរឿង "**តំណក់ទឹកភ្នែកនារី**" ឬ "**ឧទ្ទេសមរណៈ**" គឺបានចាប់អារម្មណ៍ ចំពោះខ្ញុំ ព្រោះស្នាដៃទី ១ នេះ បានធ្វើឱ្យគេភ្ញាក់ផ្អើល ពិសេសក្នុងចំណោម អ្នកបោះពុម្ពសៀវភៅ ។

ខ្ញុំបានញញឹមចំពោះស្នាដៃ តែខ្ញុំសោកស្ដាយអាណិតម្ដាយខ្ញុំដែលស្លាប់ផុត មិនបាននៅឃើញកូនប្រុស ដែលខំតស៊ូរហូតបានទទួលជ័យជំនះក្នុងជីវិតនោះ ឡើយ ។

ចាប់តាំងពីពេលនោះ បណ្ណាគារមួយចំនួននៅក្នុងខេត្ត បានចាប់ផ្ដើមស្រុះ ស្រួលគ្នាដណ្ដើមប្រជែងគ្នា ទិញស្នាដៃខ្ញុំយកទៅបោះពុម្ព ។

នៅឆ្នាំ ១៩៥៧ បន្ទាប់ពីប្រលងជាប់សញ្ញាប័ត្រមធ្យមសិក្សា (ឌីប្លូម) ខ្ញុំ ក៏សំរេចចិត្តឈប់រៀន ព្រោះគ្មានទីពឹង ហើយគ្មានមធ្យោបាយនឹងបន្តការសិក្សា ទៅទៀត មិនតែប៉ុណ្ណោះខួរក្បាលខ្ញុំរវល់តែបែរមកនិពន្ធរឿង រៀនមិនចូលទេ។

ពេលដែលឈប់រៀន ខ្ញុំបន្តការសរសេររឿងជាប់ជានិច្ច ហើយក៏ខំប្រឹង ប្រែងរកការធ្វើណាស់ដែរ ។ សម័យនោះ មានតែរបរធ្វើគ្រូបង្រៀនទេ ដែល ងាយស្រួលដោះស្រាយជាងគេ តែលុះត្រាតែបានដាក់ពាក្យចូលគរុវិជ្ជាហើយ ស្រេចតាំងពីនៅរៀន បើកាលណាឈប់រៀនម្ដងហើយ បែរជាចង់ធ្វើគ្រូវិញ ព្រោះមិនងាយដោះស្រាយបានឡើយ ។ ខ្ញុំត្រូវរាំងស្ទះចំពោះមុខការនេះ ទោះ បីជាសមត្ថភាពអាចធ្វើគ្រូបានត្រឹមថ្នាក់កំប៉ិកកំប៉ុកក៏ដោយ ទើបខ្ញុំខំស្វះស្វែង រកការងារធ្វើផ្សេងៗទៀត ប៉ុន្តែដោយខ្ញុំគ្មានបក្សពួក គ្មានលុយកាក់សូកប៉ាន់ និងមិនមានទំនាក់ទំនងក្នុងសង្គមផង ម្ល៉ោះហើយខ្ញុំចេះតែឃ្លាងរកការងារមិន បានធ្វើរហូត ។

ចំពោះមុខសភាពការណ៍ដូច្នេះ ខ្ញុំក៏ប្ដេជ្ញានិពន្ធរឿងលក់ដើម្បីចិញ្ចឹមជីវិត

និងកំហោត់ទិសដៅអនាគតខ្ញុំច្បាស់លាស់ គឺជាអ្នកនិពន្ធ ។

នៅឆ្នាំ ១៩៥៨ ដល់ ១៩៦០ ខ្ញុំបានធ្វើជាគ្រូជំនួស ( Maître Suppléant ) នៅទក្ខិណសាលាបឋមសិក្សាខេត្ត ហើយពីឆ្នាំ ១៩៦១ ដល់ ១៩៦២ ខ្ញុំបានទៅពឹងពាក់ស្នាក់នៅជាមួយមិត្តម្នាក់ ដែលគេជាក្រុមភ្លេងប្រចាំរោងចក្រខេត្តកំពង់ចាម ដើម្បីសុំការងារនៅរោងចក្រតម្បាញនោះធ្វើ ។

ប៉ុន្តែ នៅក្នុងរោងចក្រតម្បាញ គ្មានការងារណាអាចទទួលខ្ញុំបានឡើយ ប៉ុន្តែនៅចន្លោះពេលនៃការរង់ចាំជាងមួយឆ្នាំនោះ ខ្ញុំក៏បាននិពន្ធប្រលោមលោកបានប្អូនរឿងដែរ គឺយកទៅលក់ឱ្យបណ្ណាគារប្រទីបខ្មែរ នៅខេត្តបាត់ដំបងបីរឿង និងឱ្យបណ្ណាគារនៅខេត្តកំពង់ចាមមួយរឿង ។

គឺជាគ្រោះកំណាចមួយទៀត ពេលនោះស្រាប់តែមានគ្រោះថ្នាក់ភ្លើងឆេះផ្ទះកម្មករដែលខ្ញុំសំណាក់នៅ ខ្ញុំនៅសល់តែសំបកខ្លួន ឯសំណៅប្រលោមលោកមួយចំនួនក៏ឆេះអស់ទៀត ។ ខ្ញុំអស់សង្ឃឹម នឹងសុំការងារធ្វើនៅក្នុងរោងចក្រ ក៏ចុះកចាល់ត្រឡប់មកភ្នំពេញវិញ ដើម្បីផ្សងព្រេងរកការងារធ្វើតទៅទៀត ។

នៅចន្លោះពេលដែលខ្ញុំរកការងារមិនទាន់បានធ្វើ ខ្ញុំមិនដែលទុកពេលវេលាឱ្យទំនេរទេ គឺតែងដើរស៊ីឈ្នួលធ្វើជាកម្មករសំណង់ផ្ទះថ្មស្ទើរគ្រប់កន្លែង ជួនកាលលក់នំប៉័ង ជួនកាលរែកអុសលក់ និងជួនកាលរែកខ្សាច់ដាក់កាណូតនៅមុខវត្តឧណ្ណាលោម ។

ធ្វើការរប៉េះរប៉ោះបែបនេះ មិនអាចទៅជាអ្វីទេ ប៉ុន្តែគ្រាន់កំដរពេលវេលាកុំឱ្យវាហួរទៅដោយឥតប្រយោជន៍ប៉ុណ្ណោះ និងគ្រាន់បានលុយទិញបាយចំអែតក្រពះខ្វះជាមួយបងប្រុស ដែលមិនទាន់មានការងារធ្វើដូចគ្នាដែរ ។

ចំពោះផលកំរៃ ដែលបានមកពីការលក់ប្រលោមលោកម្តងៗនោះ គឺចាយវាយយ៉ាងសន្សំសំចៃអស់ទៅ ម្យ៉ាង តំលៃសិទ្ធិនៅពេលនោះតិចតួច ហើយគេមិនមែនចេះតែត្រេវការកោះពុម្ពញឹកញាប់នោះឡើយ ។

នៅពេលដែលនាវាជីវិតខ្ញុំ ត្រូវព្យុះបោកបក់រកត្រើយនាយអ្វីមិនឃើញនោះ ស្រាប់តែមានមិត្តខ្ញុំម្នាក់ឈ្មោះ **ឱ‿ឌុំ** ដែលធ្លាប់រៀនជាមួយគ្នា និងមានស្រុកកំណើតនៅបាត់ដំបង បានមកប្រាប់ថា មានក្រុមហ៊ុនផលិតកម្មភាពយន្តមួយ គេត្រូវការរកជួបខ្ញុំ ដើម្បីរកសុំទិញប្រលោមលោករបស់ខ្ញុំមួយ ឈ្មោះថារឿង "**ពេជ្ឈឃាតក្រមុំ**" ដែលបោះពុម្ពដោយបណ្ណាគារមួយនៅខេត្តបាត់ដំបង យកទៅថតជាខ្សែភាពយន្ត ។

មិត្ត **ឱ‿ឌុំ** ក៏បាននាំខ្ញុំ ទៅជួបនឹងផលិតកម្មខ្សែភាពយន្តនោះ ហើយខ្ញុំបានទទួល ៥០០០រៀល ចំពោះតំលៃសិទ្ធិទិញរឿងថតខ្សែភាពយន្តនៅសម័យនោះ ហើយសំខាន់ជាងនេះ គឺគេបានឱ្យខ្ញុំ ធ្វើការនៅប្រចាំក្រុមហ៊ុននោះ ក្នុងឋានៈជាអ្នកនិពន្ធរឿង ដោយឱ្យប្រាក់ខែទៀតផង ។

ចាប់តាំងពីពេលនោះមក ដែលខ្ញុំទាំងពីរនាក់បងប្អូន បានរស់នៅក្រោមម្លប់ដ៏ត្រជាក់នៃដំណក់ទឹកខ្មៅ ដែលខ្ញុំខំពុះពារហែលឆ្លងកាត់មកជាយូរឆ្នាំ តាំងពីយុវវ័យ ។

នៅបំរើការក្នុងផលិតកម្មភាពយន្ត គេបានចាប់ថតរឿងពេជ្ឈឃាតក្រមុំរបស់ខ្ញុំមុនដំបូង ខ្ញុំបានយកចិត្តទុកដាក់រៀនសូត្រពីមុខជំនាញនេះយ៉ាងប្រុងប្រយ័ត្ន ។ អាស្រ័យដោយឧបនិស្ស័យរបស់ខ្ញុំ និងការខិតខំទាំងយប់ទាំងថ្ងៃ ខ្ញុំក៏ចាប់យល់ដឹងពីវិស័យភាពយន្តជាបណ្តើរៗ ហើយក៏រៀនសរសេរ **Scénario** និងរៀនដឹកនាំរឿង ។ល។

ទោះបី ឆាកជីវិតខ្ញុំ ឈានដល់មុខជំនាញមួយថ្មី គឺសិល្បៈទី **៧** ក៏ខ្ញុំនៅតែបន្តការសរសេរប្រលោមលោក ដោយឥតបោះបង់ចោលមួយវិនាទីណាឡើយ ។

នៅឆ្នាំ ១៩៦៣ ពេលដែលខ្ញុំកំពុងផលិតសំរេចខ្សែភាពយន្តមួយឈ្មោះថា **ត្បើខជីវិត** ខ្ញុំត្រូវរដ្ឋអំណាចចាប់ខ្លួនដាក់ពន្ធនាគារអស់រយៈ ៦ ខែ ដោយសារវិបត្តិប្រលោមលោកមួយៈឈ្មោះថា **ទិមាននរក** ។

សូមបញ្ជាក់ថា ប្រលោមលោករឿង "**ចិមានឆរក**" នេះខ្ញុំសរសេរពេលដែលខ្ញុំទៅសំណាក់សុំការងារ នៅរោងចក្រតម្បាញខេត្តកំពង់ចាមពីឆ្នាំ ១៩៦២ ហើយយកទៅលក់ឱ្យបណ្ណាគារមួយ នៅខេត្តបាត់ដំបង ប៉ុន្តែគេផ្អាកទុក... មិនបានបោះពុម្ព ទើបតែបានចេញផ្សាយនៅឆ្នាំ ១៩៦៣ ក៏មានរឿងក្ដី... តែម្ដង ។

ប្រលោមលោកនេះ មួយចំណែក ខ្ញុំបានសរសេររិះគន់ឧត្តមមន្ត្រីម្នាក់ដែលទទួលបន្ទុកពិធីការនៅក្នុងរាជវាំង ហើយមានប្រពន្ធចុងរហូតបង្កឱ្យមានអំពើពុករលួយក្នុងការងារ ។ នេះជារឿងពិត ខ្ញុំហ៊ាននិយាយ ប៉ុន្តែខ្ញុំត្រូវមានទោស ចូលក្នុងបទបរិហារកេរ្តិ៍របស់ពលរដ្ឋម្នាក់ ( **Diffamation d'un citoyien** ) ។

ខ្ញុំបានដឹងរឿងនេះជាងមួយខែដែរ តែខ្ញុំមិនគេចវេះទេ ខ្ញុំហ៊ានសរសេរ ខ្ញុំហ៊ានទទួលខុសត្រូវ គឺព្រមប្រគល់ខ្លួនឱ្យអាជ្ញាធរមានសមត្ថកិច្ច ចាប់នាំខ្លួនពីភ្នំពេញយកទៅដាក់គុកបាត់ដំបង ព្រោះអ្នកដើមចោទបានប្ដឹងរដ្ឋអំណាចអ្នក... នេះ ដោយគេនឹកស្មានថា ខ្ញុំរស់នៅក្នុងខេត្តបាត់ដំបង ។

មានយុវជនជាច្រើន នៅក្នុងខេត្ត បានគាំទ្រខ្ញុំជាខ្លាំងនៅសម័យនោះ ខ្លះផ្ដល់ជាលុយកាក់ សំភារៈសៀវភៅខ្មៅដៃ បាយទឹក ឧបត្ថម្ភខ្ញុំពេលដែលខ្ញុំជាប់គុក ជាហេតុលើកទឹកចិត្តឱ្យខ្ញុំបានសរសេររឿងខ្លះទៀតនៅក្នុងពន្ធនាគារ ។

រួចពីមន្ទីរឃុំឃាំងមកវិញ ខ្ញុំនៅតែបន្តការសរសេរប្រលោមលោកនិងដឹកនាំរឿងខ្សែភាពយន្ត ហើយខ្ញុំក៏មានភរិយានៅពេលនោះ ។

ប្រពន្ធខ្ញុំឈ្មោះ **អ៊ុច-កុលាប** (នាមដើម **តាត-គិមលន**) ជាអ្នកស្រុកជាមួយខ្ញុំដែរ ហើយមានទិស្ស័យស្រឡាញ់សិល្បៈដូចរូបខ្ញុំទាំងស្រុង ។ នៅឆ្នាំនោះ បងប្រុសកំសត់របស់ខ្ញុំ ក៏មានជំងឺស្លាប់ទៅទៀត ហើយខ្ញុំក៏បាននាំប្រពន្ធមករស់នៅភ្នំពេញរហូត ដោយប្រឡូកជីវិតក្នុងអាជីវកម្មជាអ្នកនិពន្ធសុទ្ធសាធ។

នៅជំនាន់នោះ មានអ្នកនិពន្ធច្រើនដែរ ប៉ុន្តែពួកគេ ប្លែកពីខ្ញុំត្រង់គេសុទ្ធ

តែមានការងារស្នូលធ្វើជាបង្អែក ចំណែកខ្ញុំ ជំនាន់សង្គមរាស្ត្រនិយមក៏មិនធ្វើជាអ្នករាជការ ហើយចូលដល់ជំនាន់លន់ណុល ក៏មិនធ្វើជាអីទៀត គឺប្រកបមុខរបរចិញ្ចឹមជីវិត ជាអ្នកនិពន្ធឥតផ្លាស់ប្តូរឡើយ ។

ហេតុនេះហើយ ទើបគេឃើញខ្ញុំទៅជាអ្នកសរសេរច្រើនប្រភេទ ជួនកាលជាអ្នកសរសេរកាសែត ជាអ្នកនិពន្ធប្រលោមលោក ជាអ្នកដឹកនាំរឿងខ្សែភាពយន្ត ជាអ្នកសរសេរ **Scénario** កុន ជាអ្នកនិពន្ធបទភ្លេងទំនុកច្រៀង និងជាអ្នកគូរវាំសទៀតផង ។ ទាល់តែរបៀបនេះ ទើបចិញ្ចឹមគ្រួសារបាន ព្រោះបើសរសេរតែប្រលោមលោកមួយមុខ មិនអាចទប់ទល់នឹងបញ្ហាជីវភាពបានឡើយ ។

នៅសម័យសង្គមរាស្ត្រនិយម ខ្ញុំចេញសៀវភៅបានតិច ព្រោះពេលខ្លះខ្ញុំមានរឿង ម៉្លោះហើយខ្ញុំត្រូវអាក់សកម្មភាពមួយរយៈធំ ដោយគ្មានបណ្ណាគារណាហ៊ានទិញសៀវភៅខ្ញុំបោះពុម្ព ដោយគេខ្លាចមានរឿង ។

ឆ្លៀតឱកាសនោះ ខ្ញុំបានងាកទៅគូរសៀវភៅរឿងរូបភាពបានមួយចំនួន ខ្ញុំនៅតែតស៊ូរហូតទាល់តែមានបណ្ណាគារ ត្រូវការទិញប្រលោមលោកខ្ញុំឡើងវិញ ដោយខ្ញុំមិនអស់សង្ឃឹមសោះឡើយ ។

ដល់មកសម័យលន់ណុល ខ្ញុំបានចេញស្នាដៃជាច្រើន ហើយខ្ញុំងាកពីសរសេរលក់ឱ្យបណ្ណាគារ មកបោះពុម្ពខ្លួនឯង ។ រឿងខ្លះខ្ញុំសរសេរមួយខ្សែចប់ខ្លះពីរខែ ខ្លះ៥ខ្សែ ខ្លះ១៥ខ្សែ ហើយការសរសេរក៏មានខ្លឹមសារគ្រប់ប្រភេទ ព្រោះវាជាសម័យកាលមួយ ដែលប្រទេសជាតិថិតក្នុងភាពច្របូកច្របល់ គ្រងរខ្យល់តាមព្យុះអរិយធម៌បរទេស ។

ភាពអយុត្តិធម៌នៅក្នុងសង្គម ស៊ីសំណូកសូកប៉ាន់ កេងប្រវ័ញ្ច ជិះជាន់ហុតឈាមអង្កៀមឆ្អឹង ភាពពាលាអាវ៉ាសែ ឆ្អឹនក្បាលស៊ុក្បាល ឆ្អឹនកន្ទុយស៊ុកន្ទុយ និងការប្រណាំងប្រជែងក្នាយកបុណ្យស័ក្តិរបស់អ្នកអគ្រើសា។ បានក្លាយទៅកម្មវត្ថុសំខាន់។ សំរាប់ឱ្យខ្ញុំរើសយកមកធ្វើជាប្រធានបទនិពន្ធ ។

ទោះបីយ៉ាងនោះក៏ដោយ ក៏ស្នាដៃខ្ញុំ នៅតែបំពាក់ជាប់ឧត្តមគតិជាតិ ពណ៌សម្បុរជាតិ និងនិន្នាការវណ្ណៈជាប់ជានិច្ច ។

ហើយក៏នៅក្នុងសម័យនោះដែរ ដែលស្នាដៃខ្ញុំ ពាក់ព័ន្ធចំរូងចំរាស់ច្រើន ត្រូវគេប្តឹងឡើងសាលាមិនចប់ ដោយចេះតែសរសេរប៉ះពាល់របៀបរបបគ្រប់គ្រង ។

គួរកត់សំគាល់ថា នៅសម័យនោះហើយ ដែលខ្ញុំបាននិពន្ធបទភ្លេងទំនុកច្រៀង និងថតផ្សាយបានជាច្រើន ព្រោះពេលនោះមនោសញ្ចេតនាជីវិតបានពុះពោរដល់កំរិត គឺឱ្យតែឃើញបែបណា ចង់តែសរសេរបែបនោះ បើនិយាយមិនបានក្នុងកាសែត គឺនិយាយក្នុងប្រលោមលោក ក្នុងកំណាព្យ ក្នុងខ្សែភាពយន្ត ហើយបើគានគឹងពេក ក៏បង្ហូរចេញទៅជាបទភ្លេង ទំនុកច្រៀង... ។

---

ថ្ងៃ ១៧ មេសា ១៩៧៥ ប្រទេសជាតិបានមកដល់ផ្លូវបត់មួយ កណ្តាលល្បុះសំណើចចំអកនៃប្រវត្តិសាស្ត្រ ។ ខ្មែរក្រហមបានផ្តួលរំលំរបបគ្រប់គ្រងរបស់លន់ណុល ហើយប្រជាជនទាំងអស់ត្រូវបណ្តេញចេញពីទីក្រុង ទៅរស់នៅធ្វើពលកម្មយ៉ាងសែនទារុណតាមមូលដ្ឋាន ស្រុកស្រែ ។

ដូចជាប្រជាជនទូទាំងប្រទេសដែរ ខ្ញុំត្រូវចាកចេញពីទីក្រុងភ្នំពេញជាមួយក្រុមគ្រួសារ ក៏ដូចជាចាកចេញពីដងចាំក្តា ទឹកខ្មៅ ទៅធ្វើជាកសិករយ៉ាងលំបាកវេទនា នៅភូមិឈូក ឃុំសណ្តាន់ ស្រុកសណ្តាន់ ខេត្តកំពង់ធំ ។

ខ្ញុំរស់បានដោយសារការផ្លាស់ឈ្មោះ ព្រោះរបបប៉ុលពត មិនត្រាប្រណីចំពោះបញ្ញវន្ត ឬអ្នកនិពន្ធ អ្នកអក្សរសាស្ត្រម្នាក់ណាឡើយ ។ល។...

ពេលទៅរស់ក្នុងមូលដ្ឋានបានប្រាំខែ ខ្ញុំត្រូវបនប៉ុលពតចោទប្រកាន់ថាជាសេអ៊ីអា ហើយយកទៅ ប្រុងបាញ់សម្លាប់ចោលជាមួយប្រពន្ធខ្ញុំ ព្រោះវាបានឆែករកឃើញខ្សែភាពយន្ត ១៦ម.ម បីដុំ ដែលខ្ញុំដេរលាក់ទុកក្នុងស្រោមខ្នើយ ដោយចោទថា ខ្សែហ្វីលនោះ ជាខ្សែគេអូទេវិញ ។

ខ្សែភាពយន្តហ្នឹង ជាខ្សែភាពយន្តចុងក្រោយឈ្មោះ **មុខមួយភ្លេចប្អូន** ដែលខ្ញុំបានថតនិងកាត់ត និងបញ្ចូលសម្លេងហើយស្រេច រៀបនឹងបញ្ចាំងនៅក្នុងអំឡុងខែមេសានោះដែរ តែកម្លាំងខ្មែរក្រហមបានវាយដាច់ភ្នំពេញ ខ្ញុំខកខានមិនបានបញ្ចាំង ហើយនឹងសោកស្ដាយ ក៏យកជាប់នឹងខ្លួនទៅជាមួយ ។

នៅពេលដែលវារុករកឃើញ ខ្ញុំបានពន្យល់ប្រាប់ពួកវាដែរ ថាជាខ្សែហ្វីលធម្មតា តែពួកវាមិនជឿ នៅតែចោទប្រកាន់ ថាជាខ្សែគេអូដែល ។ ទីបំផុតវាក៏បានចាប់ចងខ្ញុំ ឯខ្សែភាពយន្តខ្ញុំយកទៅកំទេចចោល ហើយបំណងវះពោះខ្ញុំយកថ្លើមមើល ថាតើថ្លើមពួកចក្រពត្តិ នោះយ៉ាងណា ? ។

ពេលនោះ ជាយប់ខែភ្លឺចាំងៗ... ខ្ញុំត្រូវពួកវាចងបត់ដៃទៅក្រោយ ហើយឱ្យលុតជង្គង់ ពួកវាជាន់ផ្ទាច់ពីលើខ្នងទៅក្នុងថ្លុកក្របី ឯប្រពន្ធខ្ញុំក៏ត្រូវគេចាប់ចង យកទៅដាក់នៅភ្លឺស្រែម្ខាង ។

នៅនាទីចុងក្រោយ នៃឆាកជីវិតរបស់ខ្ញុំ ស្រាប់តែមានព្រឹត្តិការណ៍មួយ ដែលមិនគួរជឿបាន ធ្វើឱ្យខ្ញុំបានរួចរស់ជីវិតឡើងវិញ ។

គឺ កាលពីថ្ងៃរសៀល មានកម្មាភិបាលប៉ុលពត ៤-៥ នាក់ បានចុះកាណូតពីតំបន់ខេត្តកំពង់ធំ ឡើងទៅភូមិភាគខាងលើ តាមដងស្ទឹងសែន ក្នុងបេសកកម្មទៅបញ្ជាឱ្យប្រជាជនកាប់ឫស្សី ដើម្បីធ្វើឈ្លលដាក់ទៅទន្លេសាប ។

ជាចៃដន្យ កាណូតរបស់ពួកកម្មាភិបាលនោះខូចទៅមុខមិនរួច នៅពេលដែលមកដល់ទន្ទឹមនឹងមាត់ច្រាំងស្ទឹងបឹងឈូក ហើយពួកវាក៏នាំគ្នាចូលទៅសំរាកបរិភោគបាយល្ងាចនៅទីនោះ រង់ចាំថ្ងៃស្អែកជួលជុលកាណូតហើយនឹងបន្តដំណើរទៅមុខទៀត ។

យប់នោះ ពួកកម្មាភិបាលតំបន់ បានទទួលដំណឹងពីគណៈភូមិថា មានគេចាប់ពួក ១៧ មេសាយកទៅសម្លាប់ ពួកកម្មាភិបាលទាំងនោះ អផ្សុកក៏នាំគ្នាដើរទៅមើលលេង ។ ក្រោមពន្លឺព្រាលៗរបស់ភ្លើងចន្ទុះ កម្មាភិបាលតំបន់បានផ្ទៀតសួរទៅកាន់ប្រពន្ធខ្ញុំ ដើម្បីឱ្យប្រពន្ធខ្ញុំប្រាប់ឈ្មោះខ្ញុំពិត ព្រោះពួកគេ

សង្ស័យ ថាខ្ញុំប្រាកដជាលាក់ឈ្មោះ ។ ឆាទីចុងក្រោយ ប្រពន្ធខ្ញុំហាក់ដូចជាមានស្មារតីរឹងប៉ឹង ក៏បានប្រាប់ឈ្មោះខ្ញុំពិត មិនមែនជាឈ្មោះ "ជា" ដែលខ្ញុំបានប្រែនោះឡើយ ។

គ្រាន់តែឮឈ្មោះខ្ញុំមែនទែនភ្លាម កម្មាភិបាលម្នាក់ដែលជាប្រធានក្រុមគេបានទាញយកភ្លើងចន្លុះពីដៃគ្នាវា មកឈ្លបបំភ្លឺមើលមុខខ្ញុំ ដែលពោរពេញដោយញើសនិងទឹកភ្នែក និងមានបាតជើងពេជ្ឈឃាតជាន់ជាប់ពីលើ រួចទើបគេឱ្យខ្ញុំក្រោកឈរឡើង ឱ្យស្រាយចំណងខ្ញុំ ហើយនឹងសួរថា **«តើខ្ញុំស្គាល់គេទេ ? »** ។ ខ្ញុំឆ្លើយថា **មិនស្គាល់ទេ !** ។

ការពិត ខ្ញុំមិនស្គាល់មែន តែពួកនោះបានឆ្លើយទៀតថា គេធ្លាប់មើលប្រលោមលោកខ្ញុំច្រើនរឿង គេលើកពីឈ្មោះរឿង ពីសាច់រឿង និងតួអង្គត្រូវៗទាំងអស់ ។ ដល់ឮដូច្នោះ ទើបខ្ញុំនឹកថា កម្មាភិបាលទាំងនោះ ពីដើមធ្លាប់ធ្វើជាចលនាសម្ងាត់ផ្ទៃក្នុង ជាអ្នកធាក់ស៊ីក្លូ ឬជាជាងកាត់សក់ក៏មិនដឹងបានជាតាមដានសៀវភៅខ្ញុំ ស្ទើរតែទាំងអស់ ។

ទីបំផុត ជននោះបាននិយាយទៅពួកគណៈភូមិថា «ឱ្យដោះលែងខ្ញុំទៅ គាត់មិនមែនជា សេអ៊ីអា អីទេ គាត់គ្រាន់ជាអ្នកនិពន្ធប្រលោមលោកធម្មតា ហើយជាអ្នកនិពន្ធដែលបានសរសេរគាំទ្រវណ្ណៈអធន ប្រឆាំងនឹងវណ្ណៈជិះជាន់ដែរ »។

ដោយមូលហេតុនេះហើយ ដែលខ្ញុំបានរួចពីសេចក្ដីស្លាប់ ប៉ុន្តែនៅពេលដែលក្រុមកម្មាភិបាលនោះ ចេញកាណូតទៅផុតពីភូមិ នៅថ្ងៃស្អែកពួកគណៈភូមិមិនអស់ចិត្ត ក៏យកខ្ញុំនិងប្រពន្ធខ្ញុំទៅដាក់ក្នុងមន្ទីរសន្តិសុខ អស់រយៈពេល ៥ខែ ចោលកូនតូចៗ៥នាក់ នៅរស់ជាមួយអ្នកមូលដ្ឋានយ៉ាងវេទនា ។ល។...

---

នៅក្នុងមន្ទីរសន្តិសុខ ខ្មែរក្រហម ខ្ញុំនិងភរិយាខ្ញុំបានឆ្លងកាត់ឆាកជីវិតប្រេល្វិងជូរចត់ជាទីបំផុត ប៉ុន្តែខ្ញុំសារភាពមុខជំនាញមួយទៀត គឺការតូរប្រឹមទម្រង់

មុខដូច (Portraits) ដើម្បីដោះស្រាយបញ្ហាទំលច្រកនានា ព្រោះពេលនោះពួកកម្មាភិបាល វាចូលចិត្តគូររូបណាស់ ។ល។ល។...

... នៅពេលត្រឡប់ពីរបបប្រល័យពូជសាសន៍មកវិញ ខ្ញុំក៏បានចូលធ្វើការបំរើរដ្ឋអំណាចបដិវត្តន៍ នៅខេត្តកំពង់ធំ ។

ធ្វើជាប្រធានមន្ទីរ ឃោសនាការ វប្បធម៌និងពត៌មានខេត្តកំពង់ធំបានមួយឆ្នាំ ក៏ផ្លាស់មកធ្វើជាអនុប្រធាននាយកដ្ឋានភាពយន្ត នៅភ្នំពេញតាំងពីឆ្នាំ 1981 ។ និងមានតួនាទីក្នុងអង្គការមហាជនមួយទៀត ជាអគ្គលេខាធិការសមាគមអ្នកនិពន្ធកម្ពុជា ។

ចាប់ពីឆ្នាំ 1993 ដល់ 1996 ធ្វើជាអនុប្រធាននាយកដ្ឋានបោះពុម្ពផ្សាយ នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រហូតដល់ចូលនិវត្តន៍ ។

ពីឆ្នាំ 1981 បានសុំបើកផលិតកម្មឯកពណ្ណរង្សីភាពយន្ត ផលិតខ្សែវីដេអូខ្មែរបានមួយចំនួន ហើយចាប់ពីឆ្នាំ 1997 បានសុំច្បាប់ពីសមាគមអ្នកនិពន្ធបទភ្លេងនិងទំនុកច្រៀងខ្មែរ និងដឹកនាំសមាគមនេះ ចូលរួមសកម្មភាពលើកស្ទួយវិស័យភ្លេង ចំរៀងខ្មែរ ទាំងបូរាណនិងសម័យ ។

ទន្ទឹមនឹងស្នាដៃខាងប្រលោមលោក កំណាព្យ និងភាពយន្តវីដេអូ ខ្ញុំបាននិពន្ធបទភ្លេងទំនុកច្រៀងជាច្រើន តាំងពីអំឡុងទសវត្សទី 70 រហូតមកទល់ពេលនេះ...

**គង្គ ប៊ុនឈឿន**

❀

❀ ❀

# បញ្ជាក់បន្ថែម

តាមពិត សៀវភៅនេះ អាចដាក់ឈ្មោះ ជាកម្រងបទភ្លេងទំនុកច្រៀងក៏បានដែរ ប៉ុន្តែមូលហេតុដែលខ្ញុំដាក់ថា កម្រង "**កំណាព្យស្នេហ៍មាស**" វិញនោះ ព្រោះខ្ញុំយល់ឃើញថា គ្រប់អត្ថបទទំនុកច្រៀងសុទ្ធតែចេញមកពីកំណាព្យ គឺកំណាព្យដែលមានអត្ថន័យទោរទន់ទៅរករឿងបេះដូង ច្រើនជាងរឿងដទៃទៀត ។

អ្នកដែលមានរឿងបេះដូង ពេលណាយំក៏ច្រៀង សប្បាយក៏ច្រៀង រហូតដល់ទឹងសម្បារម្លូរម៉ៅ ក្រេវក្រោធក៏ច្រៀងដែរ ដូច្នេះចំរៀងឬ "**កំណាព្យស្នេហ៍មាស**" គ្មានអ្វីឃ្លាតពីគ្នាបានឡើយ ។

សូមបញ្ជាក់ថា បទភ្លេងទំនុកច្រៀងទាំងអស់នេះ សុទ្ធតែមានអាយុ ច្រើនឆ្នាំមកហើយ ប៉ុន្តែនៅតែមានប្រជាប្រិយភាពរហូតមកដល់សព្វថ្ងៃ ។ ដើម្បីរក្សាទុកនូវតំលៃអនុស្សាវរីយ៍ នៃការនិពន្ធបទភ្លេងទំនុកច្រៀងរបស់ខ្ញុំ ខ្ញុំបានដាក់ភ្ជាប់ពីក្រោមបទនិមួយៗ នូវណោតភ្លេងជាប៊ី **A-B-C-D** ដែលបញ្ជាក់ប្រាប់ពី **MELODIE** ពិតប្រាកដរបស់បទនោះ ។

ទាំងរូបខ្ញុំ ទាំងលោក **ស៊ីនស៊ីសាមុត** និងលោក **ម៉ៅ ហ្វូរ** សុទ្ធតែតែងបទដោយប្រើឧបករណ៍ជាប៊ី **MANDOLINE** ជាមធ្យោបាយ ដូច្នេះទោះបីណោតភ្លេងនេះ មិនមានលក្ខណៈសកលដូច **NOTE SOLFÈGES** ក៏ដោយ ក៏វាបញ្ជាក់នូវរបៀបតែងបទដ៏ចំណាស់មួយ ដែលគួររក្សាទុកជាបទពិសោធសំរាប់អ្នកតន្ត្រីវិទូ ដែលចង់សិក្សាស្រាវជ្រាវសាឡើងវិញ ពីការវិវត្តន៍នៃសិល្បៈតូរ្យតន្ត្រីខ្មែរ តាមតំណាក់កាលនិមួយៗដែរ ។

ជាទីបំផុត ខ្ញុំសូមសង្កត់បន្ថែមថា *អ្វីដែលមិនចេញពីបញ្ញាញាណសុទ្ធៗរបស់ខ្ញុំ គឺខ្ញុំមិនដាក់ឈ្មោះជាអ្នកនិពន្ធឡើយ ទោះបីជាខ្ញុំមានឈ្មោះល្បីឬមិន*

*មាន ក៏នៅក្នុងក្របខ័ណ្ឌនៃអត្តសញ្ញាណវប្បធម៌សិល្បៈជាតិពិតប្រាកដ មិនដូចអ្នកនិពន្ធខ្លះ ដោយហេតុចង់មានឈ្មោះល្បីពេក បែរជាយកបញ្ញាញាណរបស់គេ មកក្លែងធ្វើជាបញ្ញាញាណរបស់ឯងនោះឡើយ ។*

សូមអរគុណចំពោះព្រហ្មលិខិត ដែលកំណត់ឱ្យខ្ញុំកើតមកជាកូនអ្នកក្រ ដែលបានមើលឃើញទុក្ខវេទនារបស់ជីវិតច្រើនជាងសប្បាយ ទើបបណ្តាលឱ្យខ្ញុំក្លាយមកជាអ្នកកាន់ផងចាំភ្លា ដ៏អភ័ព្វនេះ !...

គ,ប,ឈ

# កំណាព្យ
# ស្នេហ៍មាស

# អារសាច់ជូនម្ដាយ

**ប្រវត្តិដើម** - កាលពីឆ្នាំ **1966** ខ្ញុំបានសរសេរប្រលោមលោកមួយឈ្មោះថា "**អារសាច់ជូនម្ដាយ**" ផ្សាយក្នុងទំព័រសារពត៌មាន "សុវណ្ណភូមិ" ដែលកាលណោះ ខ្ញុំជាអ្នកនិពន្ធប្រចាំសារពត៌មាននោះ ហើយក្រោយឆ្នាំ **1970** ខ្ញុំក៏ជាអ្នកនិពន្ធនាយក និងជាចាងហ្វាងនយោបាយប្រចាំសារពត៌មាននេះទៀតផង ។

ដោយសាររឿង "**អារសាច់ជូនម្ដាយ**" នេះ ជាប្រលោមលោកផ្នែកជីវិតសោក ដែលទាក់ទាញអារម្មណ៍អ្នកអានទូទៅ ទើបនៅអំឡុងឆ្នាំ **1967-68** លោក **[illegible]** របស់[illegible] ដែលជាចាងហ្វាងផលិតកម្មប្រាសាទមាសភាពយន្ត បានទាក់ទងសុំទិញសិទ្ធិ រឿងអារសាច់ជូនម្ដាយនេះ យកទៅថតជាខ្សែភាពយន្ត ។

ដោយយល់ឃើញថា ខ្ញុំជាម្ចាស់រឿងនេះស្រាប់ លោកសារ៉ាវុធក៏បានសំណូមពរឱ្យខ្ញុំតាក់តែងបទចំរៀង ពីរបទ សំរាប់បញ្ចូលទៅក្នុងខ្សែភាពយន្តនេះដែរ គឺបទ "**អារសាច់ជូនម្ដាយ**" និងបទ "**សសស្នេហ៍ឧត្តម**" ។

ក្រោយពីបានតាក់តែង ទាំងបទ ទាំងទំនុកច្រៀងរួចហើយ ខ្ញុំក៏បានប្រគល់ឱ្យលោក ហាស់-សាឡឹន ធ្វើ **ARRANGEMENT** និងដឹកនាំវង់តន្ត្រីចំរុះមួយ ដែលមានលោក**ស៊ីន-ស៊ីសាមុត** និងនាង **រស់-សេរីសុទ្ធា** ជាអ្នកបកស្រាយមនោសញ្ចេតនា ។

ខ្ញុំនៅចាំបានថា នៅពេលថតបទ អារសាច់ជូនម្ដាយនេះ នៅក្នុង **STUDIO** របស់អ្នកស្រីវណ្ណចន្ទ លោកស៊ីន-ស៊ីសាមុតមានការនឿយហត់ជាខ្លាំង ក្នុងការច្រៀងបទនេះ គឺថតចំនួន **11** ដង ទើបសំរេចយកជាការបាន ដោយ **MELODIE** របស់បទនេះ មានទំនួលតឹងពិបាកច្រៀង ហើយវល់តែខុសនេះ

ខុសនោះមិនពេះចប់ ។ នៅ **CODA** ចុងក្រោយ លោកស៊ីន-ស៊ីសាមុតខំស្រែកទាល់តែហើបជើងពីដី ទើបដល់ **TON** ដែលត្រូវយក ។ ពេលនោះខ្ញុំឃើញខ្នងគាត់បែកញើសរហាម ព្រោះទម្លាប់របស់គាត់ ពេលច្រៀងនៅក្នុង **STUDIO** គាត់មិនដែលពាក់អាវទេ គឺដៃទាំងពីរកាន់ **MANDOLINE** និងគ្រេះ សង្វាក់ជាប់ជានិច្ច ឯភ្នែករំពៃតាមដានមើល **NOTE ABCD** និងទំនុកច្រៀង ដែលដាក់នៅលើ **PORTE-NOTE** កំគខ្មោះ ។

ដោយសារបទនេះ មានខ្លឹមសារពិះគន់ជីវិត នៃស្នេហាប្រកាន់វណ្ណៈ ទើបនៅពេលចាក់ផ្សាយក្នុងខ្សែភាពយន្ត ធ្វើឱ្យអ្នកស្ដាប់គ្រប់មជ្ឈដ្ឋាន ភ្ញាក់ផ្អើល និងចាប់អារម្មណ៍ជាខ្លាំង ហើយល្បីល្បាញជ្រាបចូលក្នុងមនោសញ្ចេតនារបស់ទស្សនិកជនយ៉ាងរហ័សជាទីបំផុត ពិសេសគឺស្រទាប់យុវវ័យ ។

ខ្ញុំសូមសារភាពដោយត្រង់ថា នៅពេលថតចប់ភ្លាម ខ្ញុំមានការបារម្ភក្រែងបទនេះចេញមិនរួច ព្រោះប៉ះពាល់ដល់ភាពគ្រោតគ្រាតរបស់សង្គមមនុស្សនាសម័យនោះ ចំៗពេក ។ ប៉ុន្តែ ដោយហេតុថា ចុងចាក្ការបស់ខ្ញុំមានសច្ចៈធម៌ពិតប្រាកដ ទើបបទនេះបានហួរចេញពីបេះដូងរបស់ខ្ញុំ ទៅបំពេអ្នកស្ដាប់ខ្មែរទាំងអស់ ដោយគ្មានអ្វីរាំងទប់ស្កាត់បានឡើយ ។

តាមរយៈសម្លេងមាសរបស់លោក **ស៊ីន‿ស៊ីសាមុត** បទនេះបានឋិតនៅជានិច្ចក្នុងដួងចិត្តប្រជាជនខ្មែរ រហូតមកទល់ពេលបច្ចុប្បន្ននេះ ។

មិនតែប៉ុណ្ណោះ បទនេះបានធ្វើឱ្យកំពីកំរជួយដល់មនោសញ្ចេតនារបស់យុវវ័យជំនាន់ក្រោយទៀត តាមរយៈការថតបញ្ចូលក្នុងខ្សែវីដេអូរឿង "**ព្រះគុណម៉ែ**" ឬ "**អារសាច់ជូនម្ដាយ**" ដែលខ្ញុំបានរៀបចំផលិតឡើងសារជាថ្មី ដើម្បីឧទ្ទិសដល់ អតីតកាលដ៏គួរឱ្យសោកស្ដាយនោះ ។

មានអ្នកស្ដាប់ខ្លះឆ្ងល់ ហើយសួរខ្ញុំថា ហេតុអ្វីក៏ **INTRODUCTION** របស់បទនេះ មានស្រែកថា "*កូនសូមអារសាច់ជូនម៉ែ*" ផង និង "*កូនសូមអារសាច់ជូនម្ដាយ*" ថែមទៀត ? ។

បណ្ណាល័យ ប៊ុន សេន
...N SEN LIBR...

ខ្ញុំសូមបំភ្លឺ ជូនអ្នកស្តាប់នៅពេលនេះថា មុនដំបូងឃ្លាដែលស្រែកថា "*កូនសូមអារសាច់ជូនម៉ែ !..*" នោះគឺតួអង្គ ស្រែកចំពោះម្តាយរបស់ខ្លួន ! ឯឃ្លាទីពីរ ដែលថា "*អារសាច់ជូនម្តាយ*" នោះ គឺតួអង្គខំស្រែកប្រកាសចំពោះពិភពផែនដីទាំងមូល ។ នេះជា **STYLE** របស់អ្នកនិពន្ធ ដែលធ្វើឱ្យសាច់បទកាន់តែមានមនោសញ្ចេតនាជ្រាលជ្រៅខ្លាំងឡើង និងប្លែកពីគេ... ។

## អារសាច់ជូនម្តាយ

| | | |
|---|---|---|
| **បទភ្លេងទំនុកច្រៀង** | **សម្រួលតន្ត្រី** | **ច្រៀងដោយ** |
| **គង្គ-ប៊ុនឈឿន** | **ហាស់-សារឿន** | **ស៊ីន-ស៊ីសាមុត** |

**INTRO:** កូនសូមអារសាច់ជូនម៉ែ !... អារសាច់ជូនម្តាយ !...

១- សូមលើកគ្រោមដប់ ខ្ទប់ទាំងលោហិត
ក្លិនឈាមនរកជីវិត ប្រឌិតដំណៅវាសនា
ផង្គូវក្នុងជ្រាំ រៅភាំក្នុងទងបុប្ផា
លប់លាងខ្មោះឃ្លាងផ្កាស្វា ប្រហារជូនម៉ែទាំងអស់ ។

២- លោហិតកូនហូរ ផ្ចូរប្រាប់ផែនដី
លាហើយវណ្ណៈរាជសីហ៍ ដែលស្រីបណ្តុះឥតឈ្មោះ
ផ្ទូតលាងខ្ទុះឈាម លប់ស្នាមស្នេហ៍ដែលរបួស
អារសាច់ជូនឈាមយ៉ាងស្មោះ ចំពោះទឹកដោះម្តាយថ្លៃ ។

R- ចាតជើងអ្នកមាន លើស្ពានអ្នកក្រ
ម៉ែប្រាប់ឱ្យកូនត្រដរ តស៊ូយូរឆាប់គង់ផុតអវិចី
ស្នេហ៍ក្មេងចិត្តក្មេង ប្រឡែងតែទុក្ខរកភានរាល់ថ្ងៃ
ស៊ូអារសាច់ជូនម្តាយថ្លៃ លោកិយ៍គង់មិនធរមាន ។

៣- សូរសៀងអង្រឹង កូនដឹងទាំងអស់
ខ្លួនទាបមិនត្រូវឈោងខ្ពស់ ក្រែងគ្រោះទ្រូងស្រីទន្ទ្រាន
ស្នូរភ្លេងកែវស្រា ទាសាសំរាប់គេមាន
ខ្លួនយើងបីដូចតិរច្ឆាន រស់បានតែនឹងទឹកភ្នែក ។

BLUE -

INTRO- CC - C1B3 I CC1 IV CC4 II DD1... IV

I/. C3D CC1 CC3 C1C I B5B5 C1C3 C1B3 I B1B CB3 BB1 II
C1B5 B5B5 - C1C3 C1B5 C1B3 C1B1 I CC1 CB1 BA1 I
A1B3 B1C B3C3 IV

II/. A1B3 CB1 BA1 IV

R- B3B3 CC C1B3 CC1 I CC1 C4C1 CB3 I C1C1 CC1 C4C1
C4D II C3C3 DC3 - DC1 CB3 CB3 CC1 I BB1 CB B1B3 I
CC1 DC3 C1C IV

III/. .......... ( ដូច 2° Couplet ) ............ IV

○○○○○

# យំម្ដងពាន់ដង

បទភ្លេងនិងទំនុកច្រៀង
គន្ធ ប៊ុនឈឿន

សម្រួលតន្ត្រី
យិន ឌីកាន

ច្រៀងដោយ
ណោម គនិន្ទ

(បទនេះថ្មីបើទើបនិពន្ធទំនុកច្រៀងនៅឆ្នាំ 1989 ប៉ុន្តែ MELODIE ដូចបទ អារសាចជូនម្ដាយបញ្ចូលក្នុងខ្សែភាពយន្តរឿង "យំម្ដងពាន់ដង" )

INTRO - ម៉ែ ស្លាប់ ស្លាប់ចោលកូនហើយ !! ស្លាប់...ចោល..កូនហើយ ! !

១- សែនឈឺឆាបឈ្លួល ម្លួលអាក់បំផុត
ទ្រូងអើយដូចត្រូវទឹកក្រុត រោលដុតគ្មានគ្រាប្រណី
ម៉ែស្លាប់ចោលកូន សូន្យនៅកណ្ដាលទ្រូងព្រៃ
មច្ចុរាជកំណាចចង្រៃ ប្រល័យគ្មានក្ដីមេត្តា ។

២- សម្លេងម៉ែស្រែក ស្ទើរបែកផែនដី
ស្រែកសុំយុត្តិធម៌លោកិយ៍ ក្រោមដៃឃាតករឫស្យា

ដំឡូងមួយដុំ ថ្លៃជាងជីវិតមាតា
ថ្លៃជាងជីវិតទារិកា យំទារទឹកដោះម្ដាយថ្លៃ ។

R- ជីវិតច្រើនជុំភ្នំផ្ទះរលាយ របួសស្នាមពីព្រេងនាយ
ក្លាយជាចំណោទ្យ ជីវិតលោកិយ៍
ភ្លេងការភ្លេងកម្ម ចិញ្ច្រាំប្រហារដួងចិត្តភក្ដី
រាំដាវវាយខុនចងដៃ កាត់ផ្ដាច់និស្ស័យស្នេហា ។

៣- ឈាមមិនស្គាល់ឈាម សង្គ្រាមដួងចិត្ត
វង្វេងក្នុងល្បែងជីវិត ប្រមិតដំណើរវាសនា
យំមួយពាន់ដង យំរងខះទឹកនេត្រា
ទោះបីទឹកឃើញកាលណា ក៏នៅតែយំជានិច្ច ។

(ផលិតកម្ម សុវណ្ណតារា ភាពយន្ត)

☺ ☺ ☺ ☺ ☺

## រសស្នេហ៍ឧត្ដម

| | | |
|---|---|---|
| **បទភ្លេងនិពន្ធកម្មច្រៀង** | **សម្រួលតន្ត្រី** | **ច្រៀងដោយ** |
| **គន្ធ ប៊ុនឈឿន** | **ហាស់ សាឡន** | **ស៊ីន ស៊ីសាមុត ប៉ែន រ៉ន សេរីសុទ្ធា** |

**កំណត់សំគាល់** - បទនេះ មានប្រវត្តិដើមដូចគ្នានឹងបទអារសាច់ជូនម្ដាយ ដែរ គឺនិពន្ធឡើងនិងថត ក្នុងឆ្នាំនិងពេលវេលាជាមួយគ្នា សម្រាប់បញ្ចូល ក្នុងរឿងអារសាច់ជូនម្ដាយដូចគ្នា ហើយសុទ្ធតែបានទទួលការនិយមយ៉ាងផុស ផុលពីអ្នកស្នេហាតន្ត្រីគ្រប់មជ្ឈដ្ឋាន ។

១.ស- ដើមត្រែងយោល រលកកញ្ច្រោលរត់ទង្គិចគ្នា
ក្បូនស្នេហ៍ ផែត្រី ចំប៉ិចំប៉ា
សាងស្នេហ៍ ឧត្ដមវាសនា
រចនា អនាគតថ្មី ។

២.ប- ក្លិនជីវិត រៀមបានប្រឌិត ចិត្តស្នេហ៍ជូនស្រី
វណ្ណៈតូចធំ មុំកុំគិតអ្វី
ឱ្យតែជួបត្រើយនិស្ស័យ
បារមីក្តីស្នេហ៍បរិសុទ្ធ ។

R.ស- ចាំចុះប្រុសថ្លៃ ! ចាំចុះប្រុសថ្លៃ
បូជាលុះក្ស័យ ជូនក្តីមោះមុត
ផ្ទូរខ្យាច់វាសនា ស្នេហ៍ត្រាបំផុត
ទោះជាទឹកក្រុត ក៏ផុតមិនបាន ។

៣.ប+ស- ជំនោរថ្មី ជូនពរចងដៃយើងទាំងពីរប្រាណ
ទោះព្យុះបំបែកក៏ហែកមិនបាន
ទោះមារតាមជ្រែករុញច្រាន
ក៏ប្រាណចាំតែស្នេហ៍មួយ ។

**BOLERO - LENT**

I/.B1-DC3 IV B1B1 DD C3D CC1 IV C3C3 DD D4D1 DD1 I
CB3 CC1 C3D I C3C1 CB3 B1B3 IV

II/. - - - - - - - - - - - - C3C1 CB3 B1C. IV

R- CB3 B1B3 I CB3 B1B3 I CB3 B1C C3C1 DC3 IV
C3D D1C3 I DC3 CC1 I C3C3 DD D1C3 DD1 IV

III/. - - - - - - - - - -( ដូច 2$^{0}$ Couplet)- - - - - - - - - IV

(ផលិតកម្ម ប្រាសាទមាសភាពយន្ត)

¤ ¤ ¤ ¤ ¤

## ម្លប់ដូងទី ១០

**ប្រវត្តិបើម** - ខេត្តបាត់ដំបង ជាទឹកដីកំណើតរបស់ខ្ញុំ ដែលបានចិញ្ចឹមរូបខ្ញុំតាំងពីតូចដល់ធំ ក្នុងបរិយាកាសមួយដ៏ស្រងេះស្រងោចពន់ប្រមាណ ។ ឯស្ទឹងសង្កែ ក៏ជាស្ទឹងទឹកខ្មៅសម្រាប់ជីវិតកវិនិពន្ធរបស់ខ្ញុំ ដែលខ្ញុំជ្រលក់សរសេរមិនចេះរីងស្ងួតដែរ មិនតែប៉ុណ្ណោះ វាជាកន្ទែងមួយបណ្ដុះអនុស្សាវរីយ៍រាប់មិនអស់ នៅក្នុងឆាកជីវិតស្នេហាបឋមវ័យរបស់ខ្ញុំ ។

ក្នុងចំណោមដើមដូងទាំងជួរនៅត្រើយខាងលិច មានដើមដូងមួយចិតនៅចំពីមុខកំពង់វត្តវាល និងមានកៅអីថ្មមួយ ដែលខ្ញុំធ្លាប់ទៅអង្គុយបណ្ដែតអារម្មណ៍ នៅរាល់ពេលទឹកជន់ និងទឹកស្រក ។

បទនេះ ចាប់កំណើតឡើង នៅក្នុងកំណត់ហេតុនិពន្ធរបស់ខ្ញុំ តាំងតែពីឆ្នាំ 1969 ម្ល៉េះ ប៉ុន្តែគ្រាន់តែបានកត់ត្រាទុកក្នុងសៀវភៅ មិនទាន់បានបញ្ចេញឱ្យអ្នកចំរៀងណាបកស្រាយនៅឡើយ ។

កាលណោះ នៅចំពេលដែលដំណើរជីវិតរបស់ខ្ញុំ បានចុះដុនដាបមែនទែន ។ ម្ដាយខ្ញុំបានឈឺស្លាប់នៅក្រោមផ្ទះគេ ខ្ញុំលះបង់ការសិក្សា ហើយគ្មានការងារធ្វើ ។ កូនស្រីអ្នកជិតខាងម្នាក់ ដែលខ្ញុំបានលួចស្រឡាញ់ ហើយដែលនាងធ្លាប់សច្ចាស្បថស្បែថា ស្មោះស្ម័គ្រស្រឡាញ់តែខ្ញុំដែរ បែរជាត្រូវនាងបោះបង់ខ្ញុំចោលគ្មានអាល័យ ។

ពេលមួយខ្ញុំបានណាត់ជួបនាងនៅមាត់ស្ទឹងសង្កែ ក្រោម[illegible]ទីជប់ តែនាងមិនមក ទោះជាខ្ញុំបានណាត់សន្យាកាលពីថ្ងៃ ហើយក៏ដោយ ។

ទឹកជន់ ទឹកហូរកាចស្ទឹង បោះពួយនាំពពុះសំណាត់រសាត់ទៅកាន់បឹងទន្លេសាប ដោយគ្មានវិលត្រឡប់ ពាំនាំទាំងស្នេហាអស់សង្ឃឹមរបស់ខ្ញុំទៅជាមួយផង ធ្វើឱ្យបេះដូងខ្ញុំមានរបួស... រហូតមកដល់ឆ្នាំ 1972 ទើបខ្ញុំរៀបចំបទ

នេះឡើងវិញ ដើម្បីថតផ្សាយ ។

លោក **ស៊ីន.ស៊ីសាមុត** ដែលបានច្រៀងបទនេះ គឺច្រៀងផងខ្សឹកខ្សួល ផង ហាក់ដូចជាជួយរួមចំណែកកាន់ទុក្ខអតីតស្នេហារបស់ខ្ញុំ ដែលមានកំណើត ឡើងនៅមាត់ស្ទឹងសង្កែ ហើយត្រូវរលាយទៅវិញ នៅមាត់ស្ទឹងសង្កែនោះដែរ។

បទនេះ ចិតនៅក្នុងកម្រងចំរៀង "**កម្លោះហុងដា កញ្ញាវ៉េស្ប៉ា**" ដែល មានប្រជាប្រិយភាព ចំពោះអ្នកស្នេហាតន្ត្រី រហូតមកដល់ពេលបច្ចុប្បន្ននេះ ឥតមានស្រកស្រុតឡើយ... ។

## ម្លប់ដូងទី ១០

| | | |
|---|---|---|
| **បទភ្លេងនិពន្ធច្រៀង** | **សម្រួលតន្ត្រី** | **ច្រៀងដោយ** |
| **គន្ធ.ប៊ុនឈឿន** | **ហាស់.សាល្មន** | **ស៊ីន.ស៊ីសាមុត** |

១- មើលស្ទឹងសង្កែ មើលខ្សែទឹកហូរ រតាំងវត្តពោធិ
លាយនឹងជំនោរ ថ្ងូចថ្ងូរផ្កាំពេលសាយណ្ហ
រៃយំទ្រហឹង លាស្ទឹងកវីនិពន្ធ
សុរិយាទោរទន់ ពួនក្រោយផ្ទះស្រី ។

២- ដើមដូងទីដប់ ម្លប់គ្របមាត់ស្ទឹង បងឈររំពឹង
ឈរចាំព្រលឹង ស្ងាត់ឈឹងកណ្ដាលរាត្រី
អូនភ្លេចសន្យា ដែលបានវាចាពីថ្ងៃ
ចរម៉ោងប្រាំបី ស្រីមកជួបបង ។

R- ឥឡូវស្ងាត់សូន្យ ដូចក្បូនរសាត់
ទឹកភ្នួចសំណាត់ ហូរលឿនកន្ទង
បុណ្យផ្កាវត្តពោធិ នៅមិនទាន់ឆ្លង
មិនគួរន្ទនល្វង បែរខ្នងសូន្យសោះ ។

៣- ភ្លេងការត្រឹមៗ ពីទួលតាឯក ក្លាយជាខ្ទង់ខែក

ចារីពស់វែក បិទភ្នែករៀបការនឹងប្រុស
បងឈរមាត់ស្ទឹង ប្រឹងយំរងំក្នុងពោះ
លាស្រីស្រោមងោះ ឈ្មោះក្នុងជាខ្វា ។

**BLUE**

I/. CC4 CC2 C1C BB3 I CB3 B1B I B3B1 C1B B3B1 CB3 I B1C IV
BC C2C4 - DC2 C4D C4C2 I C4C C2B4 C1B2 B4B1 IV
II/.---------------------- C4C C2B4 CB2 B1B IV
R- B2B2 B4BB2 I AA2 BB2 I AA2 BB2 BC4 C2C IV
CC2C4 I C4C2 CB4 I CC2 CB4 B2B4 CC2 IV
III/. ----------( ដូច $2^0$ Couplet )---------------- IV

(ថតនៅ STUDIO លោក ចាប-ផុន)

ㅇ ㅇ ㅇ ㅇ ㅇ

## ស្ពានឈើអត់ព្យួ

**ប្រវត្តិបើម** - **MELODIE** របស់បទនេះ ខ្ញុំបានតែងតាំងតែពីឆ្នាំ **1954** ពេលដែលខ្ញុំនៅរៀនវិទ្យាល័យព្រះមុនីវង្ស តែបានដាក់ទំនុកច្រៀងផ្សេងឈ្មោះថា "**ខ្សែឆីកគួច**" ។ ខ្ញុំតែងបទនេះឡើង សំរាប់ប្រគុំលេងមួយដងមួយកាល ព្រោះខ្ញុំក៏ជាសមាជិកនៃវង់តន្ត្រី នៅក្នុងវិទ្យាល័យនោះដែរ ។ កាលពីក្មេង ខ្ញុំចេះកូតវីយ៉ូឡុង ចេះលេងគ្គីតាខ្លះៗ ចេះច្រៀងល្មមស្តាប់បាន និងចេះដេញម៉ង់ដូលីនយ៉ាងស្ទាត់ ។

លុះដល់រវាងឆ្នាំ **1973** ទើបខ្ញុំសើរើរៀបចំ **MELODIE** នេះឡើង ដោយ ដាក់ទំនុកច្រៀងថ្មី ឈ្មោះថា "**ស្ពានឈើអត់ព្យួ**" ។

មូលហេតុ ដែលនាំឱ្យខ្ញុំសម្រេចដាក់ចំណងជើងបទនេះថាដូច្នេះ គឺខ្ញុំរំលឹកដល់ខ្សែជីវិតរបស់ខ្ញុំ កាលពេលមួយដែលត្រូវរសាត់អណ្តែតគ្មានគោលដៅនោះ ។

បន្ទាប់ពីឪពុកម្ដាយស្លាប់ចោលអស់ និងមានបេះដូងប្រេះឆាដោយជីវិតស្នេហាបឋមវ័យនោះ ខ្ញុំក៏សម្រេចចិត្តចង់ចូលបួសជាសាមណេរ ដើម្បីបង្វែរជីវិតពីលោកិយ៍ដ៏អភ័ព្វ ទៅជ្រកកោនក្រោមម្លប់ព្រះធម៌វិញ [illegible] អាចឱ្យខ្ញុំបានខំរក្សាធម៌អារ្យ និងកសាងមគ្គផលសម្រាប់ជាតិមុខ [illegible] ទុក្ខវេទនាដូចជាតិនេះពេក ។

កាលណោះ សម្ដេចព្រះមេគណ **អ៊ុច-ឌួត** ព្រះចៅអធិការវត្តពោធិវាល ព្រមទាំងអាចារ្យ ដូនជីប្រចាំទីអារាមនោះ បានស្មោះស្ម័គ្រព្រមព្រៀងជួយបំបួសខ្ញុំ ដោយបានប្រគល់សៀវភៅធម៌ឱ្យខ្ញុំរៀនសូត្រត្រៀមជាស្រេច សំរាប់ដល់ថ្ងៃកំណត់ ។

ប៉ុន្តែ នៅប្រមាណជាមួយអាទិត្យទៀតដល់ថ្ងៃបំបួស ពេលដែលទឹកស្ទឹងសង្កែកំពុងឡើងជន់ជោរខ្លាំង ខ្ញុំក៏អង្គុយនៅមាត់កំពង់ទឹកវត្តពោធិវាល ដោយអារម្មណ៍អណ្ដែតអណ្ដូង ។ ជាធម្មតា ជាច្រើនថ្ងៃហើយ ដែលខ្ញុំបានកាន់សៀវភៅធម៌ ទៅអង្គុយទន្ទេញនៅទីនោះ [illegible]យប់នេះ ក្រោយពីត្រិះរិះពិចារណាវែងឆ្ងាយ ទៅតាមទិដ្ឋភាពខ្សែ[illegible] ខ្ញុំក៏ផ្លាស់ប្ដូរគំនិត មិនចង់បួសវិញ ។

មិនចង់បួស មិនមែនមានន័យថា ស្អប់ភេទជាបព្វជិតនោះឡើយ ប៉ុន្តែខ្ញុំនៅមានសមានចិត្តស្ម័គ្រក្នុងឆាកជីវិតទៅមុខទៀត កុំឱ្យមនសិការស្ដីបន្ទោសថារត់ចូលទៅបួស ព្រោះតែដោះស្រាយបញ្ហាអស់សង្ឃឹមនោះ ។ ថ្ងៃមួយបើមាននិកាស ខ្ញុំនឹងបួសឡើងវិញ ។...

ក្រោយពីសំរេចចិត្តហ្មត់ចត់ហើយ ខ្ញុំក៏ផ្ញើទុកសៀវភៅធម៌នៅមាត់កំពង់ទឹកនោះ ហើយក៏ឈប់នៅម្ដុំវត្តពោធិវាល ដោយផ្លាស់ទៅនៅឯវត្តភូមិកំផែងជិតផ្សារលើវិញ ។

នៅពេលនោះ មានលោកគ្រូបង្រៀនម្នាក់ មិនទាន់ដល់ពេលចូលនិវត្តន៍ តែចាប់ផ្ដើមពិការភ្នែក បង្រៀនសិស្សមិនបាន ក៏បានទាក់ទងខ្ញុំឱ្យទៅធ្វើជាគ្រូ

បង្រៀនជំនួសគាត់ ហៅថា (**MAÎTRE Suppléant**) បង្រៀននៅទក្សិណសាលាបឋមសិក្សាខេត្ត (**Groupe scolaire Sud**) ។

ធ្វើការបណ្ដោះអាសន្ននៅទីនោះ បានមួយឆ្នាំ ជាចៃដន្យខ្ញុំក៏បានជួបនឹងសង្សារចាស់របស់ខ្ញុំ ដែលកាលពីមុននាងនៅម្ដុំវត្តពោធិវាល តែត្រូវផ្លូវផ្ទះផ្លាស់មកនៅម្ដុំវត្តកំផែងនោះដែរ ។

ទោះបីរឿងរ៉ាវស្នេហារបស់ខ្ញុំ ត្រូវប៉ិចពន្លកឡើងវិញក៏ដោយ ក៏ពន្លកស្នេហានេះ មិនអាចទប់ទល់នឹងព្យុះសង្ឃរាកំណាចបានឡើយ ។ អ្វីៗបានធ្វើឱ្យចិត្តនាងប្រែប្រួលអស់... ស្ទឹងសង្កែរហាក់ដូចជាមិនយោគយល់ដល់ខ្ញុំបន្តិចសោះ... ស្ពានឈើមួយ ដែលខ្ញុំធ្វើទុកសំរាប់ឱ្យនាងឆ្លង នាងបែរជាស្អប់ខ្ពើមហើយទៅឆ្លងស្ពានថ្មវិញ ។...

នេះជាគោលដៅ ដែលនាំឱ្យខ្ញុំសម្រេចចិត្តនិពន្ធបទនេះឡើង ប៉ុន្តែមានអ្នកខ្លះ ដែលមិនបានដឹងចំណងជើងពិតប្រាកដនៃបទនេះ ក៏នាំគ្នាហៅថាជាបទ "**ត្រូមិចត្តកំផែង**" ទៅវិញ ដោយឃើញបទនេះ ចាប់ផ្ដើមឃ្លាឡើង ថាភូមិវត្តកំផែង ... ។

ទន្ទឹមនោះ ក៏មានអ្នកខ្លះឆ្ងល់ហើយសួរខ្ញុំផងដែរ ថាតើឃ្លាដែលនិយាយថា "*បងឈឺត្រូវគណាមដូចអ៊ុកសារ៉េន*" នោះ តើអ៊ុកសារ៉េននោះជាអ្នកណាទៅ ? -ខ្ញុំសូមបញ្ជាក់ថា អ៊ុកសារ៉េន ជាតួអង្គក្នុងរឿងព្រេងបូរាណខ្មែរមួយ គឺរឿងអធែមុនីស៊ីសុវណ្ណ ។ អ៊ុកសារ៉េន ឈឺចិត្តត្រូវគណាម ដោយធ្វើសង្គ្រាមស្នេហាចាញ់ព្រះអធែមុនី ។

# ស្ពានឈើអត់ឮ

| បទភ្លេងនិពន្ធច្រៀង | សម្រួលតន្ត្រី | ច្រៀងដោយ |
|---|---|---|
| គន្ធ.ប៊ុនឈឿន | ហាស់.សាឡន | ស៊ីន.ស៊ីសាមុត |

១- ភូមិវត្តកំផែងខ្ញុំសូមថ្លែងទុក្ខ ស្នេហ៍ខានជួបមុខ
ភាយជាទំនុកតុកកម្មស្នេហ៍ខ្ញុំ
ស្ពានកំសត់ស្បត់ស្នេហ៍ឧត្ដម
ស្បត់រាត្រី ចន្ទ្រាទឹកឃ្មុំ គោយំសុំក្ដីមេត្តា ។

២- និរាលបែកចាន បែកចិត្តទៅហើយ ស្នេ[illegible]អើយ
ស្ទឹងសង្កែអើយ ម្ដេចឡើយបូស្បា
ត្លួចស្នេហ៍ខ្ញុំ ឱ្យលង់មរណា
ត្លួចទាំងចិត្តឱ្យស្ទិតដូចផ្កា ខ្លោចផ្សានិរាម្ភរហួង ។

R- គ្រាប់ខ្សាច់ចាតបឹង រៀមប្រឹងរក្សា
ទុករោយធ្វើជាផ្កាស្លា រៀបការអូនហើយនឹងបង
ស្ពានកំសត់ធ្វើឱ្យអូនឆ្លង
តែកម្មកាចកំណាចកន្ទង នួនល្អងឆ្លងស្ពានថ្មីវិញ ។

៣- បងឈឺក្ដួតឈាមដូចអ៊ុកសារ៉េន ឈឺហួសព្រំដែន
ស្រីចិត្តម៉ឺនសែនទឹកសែនទោម្នេញ
បេះដូងមួយតែអាចដូរទិញ
ដូចទឹកស្ទឹងហូរមិនវិលវិញ ទោម្នេញព្រោះស្រីចិត្តស្រស់ ។

BLUE

I/. B3C C4C1 B3C C1B I A1C B3B3 I B1B B1B3 CD C4C1 III
C4 I C1D C4C1 CB3 - CC1C4 C1C B3B1 I BA1 BB1 B3C IV
II/.- - - - - - - - - - - - - - - - - - - - - - - - - - - - - - - B3C1 CB3 B1B IV
R- B4B4 BB B4B B4C1 I CB4 CC1 C4C I B3C1 CB3 BB1 III

C4 I C1D C4C1 CB3 I CC1C4 C1C B3B1 I B3B1 CA1 BB3 IV

III/. ----------( ថ្មីប 2⁰ Couplet ) --------

# ខ្សែទឹកគួច

បទភ្លេងទំនុកច្រៀង
គង្គ.ប៊ុនឈឿន

សម្រួលតន្ត្រី
កែច.វែម

ច្រៀងដោយ
លីខ.តឹក

**MELODIE** របស់បទនេះ ដូចគ្នានឹងបទ "**ស្ពានឈើអត់ត្ង**" ចាក់ផ្សាយតាមវិទ្យុ នៅឆ្នាំ **1968**

១- ខ្សែទឹកគួចវល់ ខ្វល់អើយស្នេហា
រោគសោកខ្លោចផ្សា ក្រៀមក្រំនិរាវាសនាមួរហ្មង
ខ្សែ ទឹកគួចក្រលួចហូរឆ្វេង
ប្រៀបបីដូចជាដួងចិត្តបង
ដែលវងតែគម្ម ស្នេហា ។

២- បណ្តាំ ផ្តាំផ្ញើ តាមខ្សែទឹកហូរ
ជាសម្លេងថ្ងូរ ផ្តាំថាបងស៊ូប្តូរជន្មជីវា
តែ ឥឡូវ នាងក្បត់វាចា
តួចទាំងចិត្តឱ្យស្វិតដូចផ្កា
ព្រោះថា ជីវិតបងក្រ ។

R- អាច្រាត យប់យន់ ទោរទន់ទៅហើយ
សមុទ្រគ្មានកោះគ្មានត្រើយ ទៅស្ញើយវិលវេជនិករ
ទឹក រលកបក់បោកបន្ត
តើបណ្តាំដែលផ្តាំយ៉ាងល្អ នៅអេឡូវហើយស្រី ? ។

៣- យាមបីយាមប្អូនខ្វះបងទន្ទឹង

យប់ក៏ស្ងាត់ឈឹង មិនឃើញព្រលឹកភ្លងឆ្លើយសម្តី
ឬ បណ្តាំដែលផ្តាំទៅស្រី
ត្រូវខ្សែទឹកគួចឱ្យក្សិណក្ស័យ
ប្រល័យ កណ្តាលជលសារ ? ។

(ប្រគុំដោយវង់តន្ត្រី យោធាភិរម្យ)

☒ ☒ ☒ ☒ ☒

## សម្រស់នាងចែវទូកដរ

**ប្រវត្តិបើម** - ខ្ញុំនិពន្ធបទនេះឡើង ដើម្បីឧទ្ទិសដល់ទឹកដីកំណើតរបស់ខ្មោចម្តាយខ្ញុំ គឺឃុំព្រែកហ្លួង ។ ទោះបីខ្ញុំបានព្រាត់ឃ្លាតមកតាំងពីតូចមកក៏ដោយ ក៏ពេលណាដែលខ្ញុំបានទៅលេងទីនោះម្តងៗ ខ្ញុំតែងឮគេនិយាយថា ខ្ញុំមានបងប្អូនញាតិសន្តាន ហូរហែ ចាប់តាំងពីម្តុំវត្តកែវ ព្រែកខ្ពប រហូតទៅដល់ ស្ទឹងចាស់ ឯណោះ ។...

ដោយហេតុនោះហើយ ទើបនៅពេលដែលខ្ញុំជិះទូកដរ ពីកំពង់ភ្នំមិជ្ឈទាវ ទៅកាន់ភូមិព្រែកហ្លួង ខ្ញុំបានជួបនឹងនារីចែវទូកដរម្នាក់ ដែលមានសម្រស់គួចជាប់ក្នុងក្តីស្រមៃរបស់ខ្ញុំ ។

ធម្មជាតិជាកម្មោះ ឱ្យតែឃើញស្រីក្រមុំមានរូបស្អាត តែងតែមានគិតគួចរវើរវាយទៅរកផ្លូវស្នេហាជាធម្មតា ប៉ុន្តែនារីដែលចែវទូកដរបញ្ជូនខ្ញុំនោះ មិនត្រឹមតែធ្វើឱ្យខ្ញុំលួចស្រឡាញ់ប៉ុណ្ណោះទេ គឺថែមទាំងធ្វើឱ្យខ្ញុំអាណិតអាសូរនាងខ្លាំងណាស់ទៅទៀត ដោយសារនាងគនិយាយមិនរួច ។ ក្រោយពីសាកសួរគេឯងទៅ ទើបដឹងថា នារីនោះមិនមែនជាអ្នកដទៃទេ គឺជាប់ពូជសាច់ឈាមលោហិតជាមួយខ្ញុំដែរ ប៉ុន្តែឆ្ងាយស្ទើរក្លាយជាអ្នកដទៃឯទៀតទៅហើយ... ។

ទោះបីយ៉ាងនេះក្តី ក៏ខ្ញុំនៅតែស្រមៃនឹកដល់ថ្ងៃខែឆ្នាំនោះ ហើយនឹកដល់ទេសភាពនិងជីវិតដ៏សែនស្រពោះស្រពោន នៃភូមិឋានប្រជាជននៅតាមដងស្ទឹង

រហូតដល់បណ្តាលឱ្យខ្ញុំប្រមូលចងក្រងមនោសញ្ចេតនា រៀបចំបទនេះឡើង គឺដើម្បីរំលឹកដល់ថ្ងៃមួយ ដែលខ្ញុំជិះទូកដរទៅលេងស្រុក ជួបនឹងនារីកំសត់ អត់ចេះនិយាយនោះឯង ។

គួរបញ្ជាក់ផងដែរថា អ្នកដែលធ្លាប់ទៅលេងភូមិដូនទាវ ក្នុងខេត្តបាត់ដំបង ទើបស្គាល់ទូកដរនេះច្បាស់ គឺជាទូកតូច ចែវ១ ឬចែវ២ មានដំបូលសំរាប់ដឹកអ្នកដំណើរចុះឡើងតាមដងស្ទឹង ហើយគិតជាគំលៃឈ្នួលតាមជិតឆ្ងាយ ។

ប៉ុន្តែ មានផលិតកម្មវីដេអូខ្លះ មានការភ័ន្តច្រឡំ ពេលយកបទនេះទៅថតជាចំរៀងកាយវិការ ឬការ៉ាអូខេ បែរជាដាក់ឱ្យតួសម្តែង ចែវឬអុំទូកឥតដំបូល ហើយឆ្លងពីម្ខាងស្ទឹងទៅម្ខាង ទៅវិញ ! នោះគេមិនមែនហៅថា ទូកដរទេ គឺគេហៅថាទូកចម្លង ។

ជាមួយនោះដែរ មានអ្នកនិពន្ធបទចំរៀងខ្លះ ចង់និយាយពីជីវិតអ្នកចែវទូកដរ គឺទូកដរឥតដំបូល ហើយឆ្លងទន្លេ ។ នេះជាភាពគ្មានប្រាកដនិយមឡើយ ការពិតទូកឥតដំបូល ដែលឆ្លងពីត្រើយម្ខាងទៅត្រើយម្ខាង មិនមែនហៅថា ទូកដរទេ គឺជាទូកចម្លង ។

## សម្រស់នាងចែវទូកដរ

**បទភ្លេងនំទុកច្រៀង** — **សម្រួលតន្ត្រី** — **ច្រៀងដោយ**

**គង្គ.ប៊ុនឈឿន** — **ហាស់.សាឡុន** — **ស៊ីន.ស៊ីសាមុត**

១- ជិះទូកតាមស្ទឹង ប្រឹងលបមើលស្រី
ធម្មជាតិស្រស់ខៀវខ្ចី ក្តាំងងារព្រៃកស្តី ព្រៃវាលអន្ទក់ [១]

---

១-អ្នកដែលស្គាល់ភូមិសាស្ត្រទឹកដីនេះ គេអាចថាខ្ញុំរៀបរាប់រីលរល់ចុះឡើង នូវឈ្មោះភូមិដែលខ្ញុំជិះទូកឆ្លងកាត់នោះ ។ ប៉ុន្តែ នេះគ្រាន់ជាការរៀបសំរួលទៅតាមបច្ចេកទេសកំណាព្យតែប៉ុណ្ណោះ មិនមែនរៀករាប់ត្រូវហែតាមលំដាប់លំដោយនោះទេ ។

ស្ទឹងចាស់ ព្រៃកហ្វូង ទ្រូងជាប់ជំរឆក់
ក្រោមភ្លៀងរលឹមកក់ៗ ជួបផ្កាខ្ញីល្អក់ ភើតភាយ ។

២- បងជាទេសចរ ពិះទូកដររ៉ូន
គន់មើលផ្កាស្រពោន ដៃតូចស្រឡូនគាស់ទឹកបែកខ្វាយ
កុលាប វត្តកែវ ល្អគន់មិនណាយ
ភ័ក្ត្រស្រស់សក់វែងរំសាយ បងតែងចុតហ្វាយសុំស្នេហ៍ ។

R- តែកម្មអាក្រក់ ដក់ត្រាំផ្លូងចិត្ត
ដូចមេឃងងឹត ព្រាត់ពីដួងខែ
កុលាបរើតស្រស់ មានសម្ផស្សស្នេហ៍
ផលកម្មបំបែរ ឱ្យគនិយាយមិនរួច ។

៣- បងអារឈាមស្រោច ក្នុងស្ទឹងសង្កែ
ក្រោមពន្លឺដួងខែ ល្បងឱ្យជួបស្នេហ៍កុលាបផ្កាល់ខ្លួច
កុលាប វត្តកែវនេត្រាមុតស្រួច
សូមឱ្យបាននិយាយរួច ឱ្យដឹងថាបងលួចស្នេហ៍ ។

**BLUE**

I/. B1D C4C1 CB4 C1C I DD1 DC4 B4 I C1C B4B1 B4D C4C1 II
D C4D2 I B4C1 C4D D1D I C1B4 C1B3 B4B1-B3B B1C4 I DC1 IV
II/. - - - - - - - - - - - - - - - - -C1B4 C1B3 B4B1-B3B B1C C1C4B4 IV
R- CCC1B1 B4C C1C4 IV DC4 C1C4 B1C B4C1 IV
CCC1B1 B4B1 B4C II C1C B4B1 I BB1 B4C B4B IV
III/. - - - - - - - - - -( ដូច 2° Couplet ) - - - - - - - - - - - IV

⌘ ⌘ ⌘ ⌘ ⌘

## ១ ស្ពានអូរតាគី

**ប្រវត្តិមើម** - ដូចខ្ញុំបានបញ្ជាក់ នៅក្នុងជីវប្រវត្តិសង្ខេបរបស់ខ្ញុំហើយ បើតាមការពិតជាក់ស្តែង ដែលខ្មោចឪពុកម្តាយខ្ញុំបាននិយាយប្រាប់ គឺខ្ញុំមានកំណើតនៅភូមិបឹងព្រីង ឃុំថ្មគោល ស្រុកបាត់ដំបងឯណោះទេ ។ ប៉ុន្តែគ្រាន់តែកើតបានពីរបីឆ្នាំប៉ុណ្ណោះ ឪពុកម្តាយខ្ញុំត្រូវប្តូរទីតាំងចេញពីទីនោះមកវិញ ។ ដោយសារស្រុកទេស វិលវល់ភ័ន្តប្រែចុះឡើង ខ្ញុំក៏សំរេចយកឃុំចំការសំរោង ជាទីតាំងកំណើតជាក់លាក់ ព្រោះកន្លែងនោះខ្ញុំបានធ្លាប់រស់នៅយូរជាងគេ ហើយក៏មានអនុស្សាវរីយ៍ច្រើនជាងគេក្នុងឆាកជីវិត ។ ទោះជាយ៉ាងនេះក្តី ក៏ខ្ញុំនៅតែនឹកឃើញដល់ភូមិបឹងព្រីង ដែលជាទីតាំងធ្វើស្រែចាំង នៅក្នុងសម័យអាណានិគមនោះដែរ ។

នៅតាមដងផ្លូវ ចាប់តាំងពីស្ពានអូរតាគី រហូតទៅដល់មង្គលបុរី សេរីសោភ័ណ សុទ្ធជាកន្លែងដែលបានកត់ត្រាទុក នូវអនុស្សាវរីយ៍ និងរឿងរ៉ាវផ្សេងៗ ដែលជីវិតស្នេហាបឋមវ័យរបស់ខ្ញុំបានជួបប្រទះ ។

ជាមួយនេះផងដែរ ខ្ញុំបានដក់ចិត្តផិតអារម្មណ៍ ទៅលើជីវិតកម្មកររថភ្លើង ដែលធ្វើវាសនាលើផ្លូវដែកដ៏កំសត់ទុរគត ។

ខ្ញុំយល់ថា ជីវិតកម្មកររថភ្លើងពិតមែនតែក្រខ្សត់ តែមានចិត្តស្មោះត្រង់ភ្លឹង ដូចជាផ្លូវដែក ហើយរឹងប៉ឹងមាំមួន ភក្តីភាពចំពោះស្នេហាជាទីបំផុត ។ ប៉ុន្តែជីវិតឆ្អិនក្បាលស៊ីក្បាល ឆ្អិនកន្ទុយស៊ីកន្ទុយ របស់អ្នករត់ពន្ធផ្សារងងឹត បានធ្វើឱ្យស្នេហារបស់កម្មកររថភ្លើង ប្រែក្រឡះទៅវិញ ។...

ថ្វីបើបទនេះ គ្មានពាក្យបឹងព្រីងមួយម៉ាត់នៅជាមួយ ប៉ុន្តែគឺខ្ញុំមានគោលដៅ រំលឹកទៅដល់ភូមិឋានទាំងនោះ ចាប់តាំងពីស្ពានអូរតាគីឡើងទៅ ព្រោះស្ពាននេះជាទីតាំងពិតប្រាកដនៃជីវិតស្នេហារបស់ខ្ញុំ ដែលបើទុកណាជាមិនបាន

សំរេចដួចបំណង ក៏បានឋិតនៅក្នុងក្ដីស្រមៃគ្មានព្រំដែនមួយ ដែលពោរពេញដោយក្ដីអស់សង្ឃឹម... ។

បទនេះ ចាប់និពន្ធនិងថតនៅក្នុងអំឡុងពេលវេលា ដូចជាបទប៉ុន្មានខាងមុខនេះដែរ ព្រោះសុទ្ធតែឋិតនៅក្នុងកម្រងកាសែ្សត **កម្លោះហុនដាកញ្ញារប៉េសេ** ដូចគ្នា ហើយនៅតែមានប្រជាប្រិយភាព រហូតមកដល់សព្វថ្ងៃនេះ...

# ស្ពានអូរតាគី

**បទភ្លេងនំនុកច្រៀង**
**គន្ធ ប៊ុនឈឿន**

**សម្រួលតន្ត្រី**
**ហាស់ សាឡន**

**ច្រៀងដោយ**
**ស៊ីន ស៊ីសាមុត**

**INTRO -** ស្ពានអូរតាគី បើអ្នកដឹងរឿងខ្ញុំ...
សូមជួយលាក់ផង កុំប្រាប់អ្នកណាឱ្យសោះ !...

១- សំរក់ទឹកខ្មៅ លើដំបៅចាស់
ទឹកភ្នែកសែនខ្លាស់ ស្ពានអូរតាគី
កាលបងនិងអូនសាងក្ដីស្នេហ៍ កាលបងនិងអូនសាងក្ដីស្នេហ៍
ក្រោមដើមគគីរ ក្នុងខួមទុតិត ។

២- អូនតាមម្ដាយទៅ មង្គលបុរី
គ្មានផ្ញើសំបុត្រ ឱ្យបងមួយម៉ាត់
បងជាកម្មកររថភ្លើងកំសត់ បងជាកម្មកររថភ្លើងកំសត់
លួចផ្ញើសំបុត្រ តាមអ្នករត់ពន្ធ ។

R- ស្រាប់តែ អូនមានថ្មីហើយ
ពីរឆ្នាំហើយ ទុក្ខស្នេហ៍សែនធ្ងន់
ម្ដាយអូនជេរធ្វើតាមអ្នករត់ពន្ធ ម្ដាយអូនជេរធ្វើតាមអ្នករត់ពន្ធ
មើលងាយអឹកធន់ ថាបងក្រខ្លាំង ។

៣- ស្ពានអូរតាគី ស្ពានអូរតាកែ
និពពាលខែ និងស្រែពាក់ង

បើដឹងរឿងខ្ញុំសូមជួយបិទបាំង បើដឹងរឿងខ្ញុំសូមជួយបិទបាំង
ធ្វើជារនាំង បាំងស្នេហ៍នេះផង ។

**SARAVANN**

I/. C4C4 C1C4 B4C C4C1 **IV** B4C C1D C4C1 C4C **IV**
BB1 B4C C1C B1B4 - BB1 B4C C1C B4B1 -
C4C4 C1C B4B1 B4C1 **IV**

II/. C4C4 C1C B4B1 BB4 **IV**

R- B4C B4B1 BB1 **IV** BB1 B4C C1C4 DC1 **IV**
DD C1D C1C4 DC - C1C1 B4C1 B4C C1B1 -
BB1 B4C C1C B4C4 **IV**

III/. ------------- ( ដូច $2^0$ Couplet ) --------- **IV**

ঙ ঙ ঙ ঙ ঙ

## លាហើយ ! សោភីនី !

**ប្រវត្តិមើម** - បទនេះ ខ្ញុំបាននិពន្ធឡើងក្នុងកំឡុងឆ្នាំ **1966** តាមសំណូមពររបស់ផលិតកម្មប្រាសាទមាសភាពយន្ត ដើម្បីដាក់បញ្ចូលក្នុងខ្សែភាពយន្តរឿង "**ទិវ៉ៃស្នេហមរណៈ** ! " ។ ការពិតរឿង "**ទិវ៉ៃស្នេហមរណៈ**" នេះ មានបទដើមរបស់គេមួយហើយឈ្មោះថា "**ស្នេហមរណៈ**" ដែលច្រៀងដោយលោក **ស៊ុះម៉ាត់** ។ ប៉ុន្តែ ដោយរឿងនេះ មានទម្ងន់ទៅលើបេះដូងនាង សោភីនី ទើបម្ចាស់ផលិតកម្មសំរេចឱ្យខ្ញុំ តែងមួយបទទៀត សំរាប់សង្កត់បន្ថែមផ្ទៃរឿង ឱ្យកាន់តែល្អឡើង ។

សូមបញ្ជាក់ថា បទលាហើយសោភីនីនេះ ជាស្នាដៃលើកដំបូងរបស់ខ្ញុំក្នុងការនិពន្ធបទភ្លេងទំនុកច្រៀង ហើយក៏ជាមូលហេតុលើកទី១ ដែលនាំឱ្យខ្ញុំស្គាល់លោក **ស៊ីន-ស៊ីសាមុត** ដែរ ។ ខ្ញុំនៅចាំបានថា ពេលដែលខ្ញុំតែងបទនេះរួចហើយ ខ្ញុំក៏ស្ពាត់ទៅជួបលោក **ស៊ីន-ស៊ីសាមុត** នៅផ្ទះគាត់ឯទួលទំពូងដែលជាយូរមកហើយ ខ្ញុំមិនដែលបានជួបនិយាយគ្នាជាមួយគាត់ទាល់តែសោះ។

ពេលនោះលោក **ស៊ិន.ស៊ីសាមុត** មិនទាន់សង់វីឡាថ្មី ដែលមានឈ្មោះ ថា**វីឡាសុគ្រាត**នោះឡើយ គឺគាត់រស់នៅក្នុងផ្ទះឈើមួយតូច ប៉ុន្តែខ្ញុំបានឃើញ គំនរឥដ្ឋនិងក្បឿងជាច្រើននៅក្បែរនោះ បញ្ជាក់ថាគាត់រៀបចំសង់ផ្ទះថ្មី ។

ខ្ញុំទៅជួបគាត់នៅថ្ងៃអាទិត្យ វេលារសៀល ដែលពេលនោះគាត់កំពុង លើក ALTÈRE ហាត់សាច់ដុំនៅក្បែរផ្ទះ ដោយមានលោក **មាស់.សាឡុន** លោក**ម៉ែរម៉ុន** និងលោក **ស្វាយ.សំអឿ** កំពុងជជែកគ្នាលេងនៅទីនោះដែរ។

អ្នកចំរៀងឯកនេះ មិនដែលប្រកាន់ឫកទេ ចំពោះភ្ញៀវ គឺមានទឹកចិត្តស្និទ្ធស្នាល រាក់ទាក់រួសរាយយ៉ាងខ្លាំងបំផុត ហេតុនេះហើយ ទើបទំនាក់ទំនងរវាងខ្ញុំនិង លោក**ស៊ិនស៊ីសាមុត** ព្រមទាំងសហការីដទៃទៀត រីកចំរើនឡើងដោយ ឆាប់រហ័សនិងល្អប្រសើរជាទីបំផុត ព្រោះយើងយល់ថា សុទ្ធជាអ្នកមានអាជីព ជំនាញដូចគ្នា ។

អនុស្សាវរីយ៍ ដែលខ្ញុំនៅនឹកឃើញ ស្ទើរតែរាល់ថ្ងៃនេះ គឺកាល ណោះលោកស៊ិនស៊ីសាមុត បានយកចិត្តទុកដាក់ហាត់ច្រៀងបទរបស់ខ្ញុំ ដោយ មិនបីសអើពើនឿយហត់ ព្រោះតែចង់ប្រញាប់ចូលថតនៅ STUDIO ឱ្យបានសំរេច តាមថ្ងៃកំណត់ ។ បទនេះ ខ្ញុំបានឱ្យលោក **កែប.អែម** ប្តីនាង **សុ.សាវឿន** ធ្វើ ARRANGEMENT ហើយបានថតនៅ STUDIO (FILM-FARK) ។

ខ្ញុំមិនភ្លេចទេ ពេលដែលលោកហាត់ថតបទនេះ គឺគាត់រាងផ្តាសាយបន្តិច សម្លេងរាងក្រេង្ញនៅចុងច្រមុះ ប៉ុន្តែក្រោយដែលលទ្ធផលចេញមក បទលា ហើយសោភីនីនេះ បានទទួលការពេញនិយមជាខ្លាំង សម្លេងចុងច្រមុះ ធ្វើឱ្យ បទនេះកាន់តែពិរោះ ឡើងដល់កំរិតមនោសញ្ចេតនា ដែលចង់បាន ។...

ដោយសារបទនេះហើយ ដែលធ្វើឱ្យគេស្គាល់ឈ្មោះខ្ញុំនៅក្នុងពិភពតន្ត្រី ហើយក៏ជាមធ្យោបាយធ្វើអោយ ចំណងមិត្តភាពរបស់ខ្ញុំ រវាងលោក**ស៊ិនស៊ីសា មុត** កាន់តែរឹងមាំឡើងជាលំដាប់ឥតស្រាកស្រុត រហូតដល់ថ្ងៃបែកគ្នានៅថ្ងៃ 17 មេសា 1975 ...

# លាហើយសោភីនី !

| បណ្តូលទំនុកច្រៀង | សម្រួលតន្ត្រី | ច្រៀងដោយ |
|---|---|---|
| គន្ធ.ម៉ិនឈឿន | កែច.វ៉ែម | ស៊ិន.ស៊ីសាមុត |

១- ...ទ្បាអើយ ! ឈឺចុកណាស់ស្នាមចាស់អប្រិយ៍
ឈាមអតីតអរិចិ ស្រក់ចុះចាកដៃនៃអ្នកនឹងបង
ឥឡូវ ភ្លេងការប្រហារបំណង
ខាំហែកបំបែកបង្អង ជ្រែកដើមទ្រូងជាអលប្អី ។

២- អណ្តាតមានតែមួយ ភាសារយពាន់
ទឹកប្រាក់វណ្ណៈបំភាន់ បិទមុខដើរជាន់អនុស្សាវរីយ៍
ស្លាប់ទៅ កុំរស់ ស្រីពស់ក្បាលពីរ
លាហើយ លាសោភីនី លាធរណី ស្នេហ៍អនត្តា ។

R- ភ្លេចឈាម រហាមយំស្រែកជង្អក់
លាស្រីចិត្តឋានធរក រស់ក្នុងស្រោមទេវតា
ខ្លាចហើយ រាងហើយ ភ្លេងការ
បេះដូងពេជ្ឈឃាតបូស្សា ព្រាយតណ្ហាជ្រួសាររលោភយស ។

៣- និស្ស័រ ទ្រគង ឈ្មោះឈ្មោះគ្នាអុំ
គេបានសើចខ្ញុំបានយំ ទឹកភ្នែកហែកភ្នំយំទាររំលោះ
ទុកចងដៃឱ្យត្រាក្រោយបង្អស់
លាស្រីចិត្តអសប្បុរស លាដោយស្មោះលាលុះអវសាន្ត ។

**BLUE-FOLK**

I/. B1C1-CB4C C4C1 C1C1 - D1DC4 C4C1 C1C1 - CB4C C4C1 C1C1 II
B1B5-B3B1B3 C1B5 B5B5- C3DC3 C1B5 B5B5-B3B1B3 B1B5 CC1 II

II/. - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - B3B1B3 B1B4 B3B1 II

R- B1C I B4B3 B1B3 B4C I B1D C4C1 B4C I BB1B3 C[illegible] II
C1C1 - C4D C4B4 C1C C4C1 I C4D C1C3 C4D - CC[illegible] II

III/. - - - - - - - - - - - - - - - ( ដូច 2° Couplet ) - - - - - - - II

# រំដួលដងស្ទឹងសង្កែ

**ប្រវត្តិបើម** - អ្នកដែលធ្លាប់ស្គាល់ខ្ញុំភាគច្រើន គេតែងនិយាយថា ខ្ញុំចូលចិត្តតែងបទចំរៀង ដែលពណ៌នាទេសភាពនៅស្ទឹងសង្កែ និងរឿងរ៉ាវជីវិតនៅខេត្តបាត់ដំបង ។ មែន ការនិយាយបែបនេះ ឥតខុសទេ ព្រោះខ្ញុំមានដើមកំណើតនៅខេត្តបាត់ដំបង ខ្ញុំចេះតែមានមនោសញ្ចេតនានឹករលឹកទៅដល់ទឹកដីកំណើតជានិច្ច (NOSTALGIE) ទោះបីជាខ្ញុំឃ្លាតមកយូរឆ្នាំហើយក៏ដោយ ។

ដូច្នេះ ការដែលខ្ញុំនិយាយពីរឿងស្នេហានៅខេត្តបាត់ដំបង គឺមួយផ្នែកគឺជាការរំលឹកនូវអនុស្សាវរីយ៍ នៃជីវិតស្នេហាបឋមវ័យរបស់ខ្ញុំ និងមួយផ្នែកទៀត គឺរំលឹកដល់ទឹកដីកំណើតតែប៉ុណ្ណោះ ។

ទន្ទឹមនោះ ខ្ញុំតែងតែគិតថា បើខ្ញុំស្គាល់ខេត្តនេះច្បាស់ជាងគេ និងមានអនុស្សាវរីយ៍ច្រើនជាងគេ តើឱ្យខ្ញុំសរសេរពីខេត្តឬប្រទេសណា ដែលខ្ញុំមិនស្នូវ និងមិនដែលស្គាល់ ? ។

បទ **រំដួលស្ទឹងសង្កែ** នេះ គឺជាសក្ខីភាពនៃការរំលឹកឡើងវិញ កាលខ្ញុំនៅពីក្មេង ។ ពីឆ្នាំ **1945** មកទល់ **1953** ខ្ញុំរស់នៅលើទូកក្នុងដងស្ទឹងសង្កែ ចតនៅទល់មុខរោងភាពយន្តអេដែន (បច្ចុប្បន្នរោងកុននេះគ្មានទៀត) ។

ពេលដែលខ្ញុំជិះទូកដងស្ទឹង ឬដើរលើស្ពានទៅរៀន[illegible]កាល ខ្ញុំតែងតែចាប់អារម្មណ៍នឹងទេសភាពក្នុងស្ទឹងសង្កែ ពេលរដូវទឹកជំនន់ ក៏ដូចជាពេលទឹកសំរក ។

កាលណោះ ខ្ញុំតែងយល់ថា ពិភពលោកដ៏ល្អប្រណីត ប្រហែលមានតែក្នុងបាតស្ទឹងសង្កែប៉ុណ្ណោះទេ ។ មើលចុះ ស្នាមទឹកហូរវិញ។ កាត់វាលខ្សាច់ដ៏ស្រស់ប្រផ្ទរ ខ្ញុំបាននាំមិត្តភ័ក្តិយកក្រអារអួសត្រី និងនាំគ្នាយកក្អមដាក់កប់ក្នុងខ្សាច់ ហើយចោះប្រហោង ដើម្បីច្រោះយកទឹកស្អាតត្រជាក់ ។ មិនតែ

ប៉ុណ្ណោះ ខ្ញុំឧស្សាហ៍ចាប់យកត្រីក្រិម មកប្រជល់គ្នាលេងនៅទីនោះ ។

ខ្ញុំមិនអាចភ្លេចបានទេ នូវសម្រស់របស់យុវនារីម្នាក់ ដែលបានចុះមុជទឹកនិងដើររើសក្រុំ នៅបាតស្ទឹងនាពេលថ្ងៃលិច ។ ឥឡូវនេះ ទោះបីផ្សែងជីវិតបានបក់ផាត់រំលាយអតីតកាល ទាំងនេះទៅហើយក្ដី ក៏អំណាចនៃក្ដីរលឹកបានធ្វើឱ្យទឹកខ្មៅខ្ញុំ ស្រក់ហូរស្រែកហៅភ័ក្ត្រាដ៏ស្រស់ប្រិមប្រិយ៍នោះ ឱ្យមានជីវិតរស់ឡើងវិញ ។

សូមបញ្ជាក់ថា បទនេះតែងនៅឆ្នាំ 1974 ថតឱ្យ**ផលិតកម្មពស់មាស** ។ ពេលចាក់ផ្សាយជាលើកដំបូង លោក**ញ៉ឹក-ឌិម** ដែលជាវិចិត្រករឯកខ្មែរជំនាន់នោះ មានប្រតិកម្មជាខ្លាំង រករឿងទឹងសម្បារនឹងលោក**ស៊ីនស៊ីសាមុត** ដោយចោទថាលោក**ស៊ីនស៊ីសាមុត** ច្រៀងដៀមដាមឱ្យលោកត្រង់ឃ្លាថា *"វិចិត្រករអើយកុំចាប់គូរអី នៅក្នុងលោកីយ៍ស្រីល្អគ្មានទេ !"* ។

ក្រោយមកទើបលោក**ញ៉ឹក-ឌិម** អន់ទឹងវិញ ព្រោះដឹងថាបទនេះជាបទរបស់ខ្ញុំ ដែលខ្ញុំគ្មានបំណងរិះគន់ឱ្យលោកទេ [illegible]ដើម្បីរំលឹកដល់អនុស្សាវរីយ៍ពីអតីតកាលរបស់ខ្ញុំតែប៉ុណ្ណោះ [illegible] **រំដួលដងស្ទឹងសង្កែ** នៅក្នុងក្ដីស្រមៃរបស់ខ្ញុំ... ។

## រំដួលដងស្ទឹងសង្កែ

**បទភ្លេងនំនុកច្រៀង** **សម្រួលតន្ត្រី** **ច្រៀងដោយ**
**គង្គ-ប៊ុនឈឿន** **ម៉ែរ-ប៊ុន** **ស៊ីន-ស៊ីសាមុត**

១- មហាសង្ក្រាន្ត ប្រានឆ្នាំមួយទៅ
ទ្រូងសែនហួងសៅ ទឹកព្រួយក្រែងពៅ ឆាប់ភ្លេចរឿងដើម
រឿងចាត់ដំបង ចងទងដង្ហើម
កាលជួបស្រីឆ្នើម រដូវសន្សើមផ្ការីកស្គុះស្គាយ ។

២- អូនដើររើសក្រុំ ក្នុងស្ទឹងសង្កែ
ភ័ក្រ្តដូចផ្គងខែ ថ្ពាល់ខួចមានស្នេហ៍ នេត្រាពណ្ណរាយ
ហត្ថាខ្ចីល្អក់ សក់ខ្មៅរំសាយ
ល្អគន់មិនណាយ ក្លិនខ្លួនឆោមឆាយ រាយសំណាញ់ស្នេហ៍ ។

R- វិចិត្រករអើយ កុំបាច់គូរអី
នៅក្នុងលោកីយ៍ ស្រីល្អគ្មានទេ
មានតែរំដួល ដងស្ទឹងសង្កែ
ដែលខ្ញុំលួចស្នេហ៍ ទោះរយឆ្នាំខែ ក៏នៅចាំចង ។

៣- ឥឡូវ រដូវផ្ការីកវិលវិញ
ទ្រូងសែនទោម្នេញ ព្យុះកម្មបក់ដេញ ចាត់ផ្កាមួយទង
ត្រីក្រិមអូនស្លាប់ នៅក្នុងដបបង
លិខិតខ្លួនល្អង បងទុកទ្រាប់ខ្នង ដេកស្លាប់ក្នុងផ្នូរ ។

**BOLERO-LENT**

I/. DC4 C3C1 CB3 CC1 II CB3 CC1-C3C4 DC1 DC1 CB3 IV
CC1 CB3 CB3 BB1 II BB1 B3C- B3C C1C3 DC3 C1C IV
II/.------------------------ -B3C C1C3 DC3 CC1 IV
R- C4C4 - C1C4 I C1C4 DD1 I C1D1 DC4 DC1 C4D IV
C3C3 CC1 B3C C4C1 - B3C C1C4 - C1C1 C4D C4D D1D4 IV
III/. --------( ដូច $2^0$ Couplet ) ------ IV

(ផលិតកម្ម ពស់មាស)

☹ ☹ ☹ ☹ ☹

# មេឃាភ្នំពេញ តារាចាត់ដំបង

បទភ្លេងនិពន្ធទំនុកច្រៀង គន្ធ ម៉ិនឈឿន
សម្រួលតន្ត្រី ហាស់ សាឡុន
ច្រៀងដោយ ស៊ិន ស៊ីសាមុត រស់ សេរីសុទ្ធា

(បទនេះថតនៅឆ្នាំ 1973 ក្នុងកម្រងកាសែត កម្មោះហុងដា កញ្ញាប៉េសេ)

១.ប- បងសូមលាសិន លាសិន លាបាត់ដំបង
លាស្ពានធ្លាប់ឆ្លង លាផងស្ទឹងធ្លាប់កំសាន្ត
ស- បើបងឃ្លាតទៅ ប្រុសពៅកុំភ្លេច វាលបែកចាន
ដែលយើងធ្លាប់ ដើរកំសាន្ត
ប- សូមកែវកល្យាណ កុំព្រួយឡើយណា ! ។
២.ប- បងឃ្លាតមែនពិត តែចិត្តចងចាំលើថ្ងៃ
នឹកដល់រាត្រី រាត្រីប្រាំបីមេសា
ស- បងទៅភ្នំពេញ ពោរពេញទៅដោយដួងតារា
ប- ភ្នំពេញមានតែមេឃា ឯដួងតារានៅបាត់ដំបង ។

R ប- កុលាបជាយដែន បងសែននឹកឃើញមិនភ្លេច
នឹកដល់ពេលជួបគ្នាថ្ងៃលិច ទោះដើរឬធ្វេចនឹកតែនួនល្អង
មេឃាភ្នំពេញ ដួងតារាបាត់ដំបង
ស- បើពិតដូចពាក្យបង សូមប្រុសនួនល្អង កុំភ្លេចឡើយណា ! ។
៣.ប- បងសូមលាហើយ លាហើយលាទាំងទឹកភ្នែក
ថ្ងៃនេះថ្ងៃស្អែក បងបែកទៅបំពេញកិច្ច
ស- បើបងឃ្លាតទៅ ពៅកុំភ្លេចកុលាបទងពេជ្រ
ប- បងចងចាំជានិច្ច (ស) សូមបងកុំភ្លេចរាត្រីភិរម្យ ។

**REAM VONG**

I/. C1D C1C4 I C1C4 CC1 C4B4 III C4C1 CB4 I CB4 CB4 BB1 III
C4C4 C4C4 I DC4 DC4 DC1C - B4CC1 CB4B1-
B4B4 B1B1 BA1 BB1 III
II/.- - - - - - - - - - - - - - - - C1C B4B1 B A1B B1B4 III
R- C2C2 C2C2 I C4D D2D C4C2 - C4C2D D2D C4C2-
C4C4 B4B4 CC1 C2C4 III DDDD I D2D C4C1 C4C4 -
B1BD C4C1C1 - C4C B4B1 BA1 BB1 III
III/. - - - - - - - - - - ( ដូច $2^0$ Couplet ) - - - - - - - III

## ជ្រោះពេជ្រចិន្តា

**ប្រវត្តិបទ**- **MELODIE** របស់បទនេះ ខ្ញុំបានតែងយូរហើយ គឺតាំងតែពីនៅរៀនម្ល៉េះ ។ កាលណោះ ខ្ញុំតែងតែយកបទនេះទុក **Solo MANDOLINE** សំរាប់ពេលប្រគុំតន្ត្រីម្តងៗ ។

រហូតមកដល់ឆ្នាំ **1974** ពេលដែលក្រុមហ៊ុន **ឡាក់-ស៊ា** តម្រូវឱ្យខ្ញុំធ្វើបទដាក់កាស្សែត ទើបខ្ញុំបានយកបទនេះ មកច្នៃរៀបចំឡើងវិញ ដោយដាក់ឈ្មោះថា **ជ្រោះពេជ្រចិន្តា** ។

ខ្ញុំសរសេរបទនេះ គឺដើម្បីរំលឹកដល់រមណីយដ្ឋានទេសចរមួយនៅខេត្តបាត់ដំបង តាមផ្លូវទៅស្រុករតនមណ្ឌល (ប៉ៃលិន) ។

កាលណោះ ក្រោយពីខ្ញុំរួចទុក្ខទោស ព្រោះវិបត្តិប្រលោមលោករឿង **ពិមាននរក** នោះមក ខ្ញុំបានទៅលេងជ្រោះពេជ្រចិន្តាជាមួយឪពុកក្មេក និងបងប្រុសខ្ញុំ ដើម្បីជាការរំហើយកាយ ឱ្យរួចពីភាពតប់ប្រមល់ផង និងដើម្បីរកផ្កាអរគីដេ

ព្រៃផង ។

ខ្ញុំឃើញ**ជ្រោះពេជ្រចិន្តា** ក៏នឹកអរគុណដល់ធម្មជាតិ ដែលឆ្លះរចនាដងព្រៃនោះ ឱ្យទៅជារមណីយដ្ឋានមួយ ប្រកបដោយសោភ័ណភាព សែនស្រងេះស្រងោចខ្លោចផ្សា ។

ដោយសារលំអរបស់ទីនោះ បានចាក់ផ្ទុះមុតជ្រៅទៅក្នុងបេះដូងរបស់អ្នកទេសចរជាច្រើននោះហើយ ទើបខ្ញុំប្រសិទ្ធិនាមបទនេះថា **ជ្រោះពេជ្រចិន្តា** ។

នៅពេលថតបទនេះ ខ្ញុំនឹកអាណិតនាង **រស់-សេរីសុទ្ធា** ពន់ពេកណាស់ ព្រោះនាងច្រៀងបណ្ដើរ មានដំណក់ទឹកដក់ដាមក្នុងរង្វង់ភ្នែកបណ្ដើរ នេះក៏ព្រោះនាងនឹកស្រណោះ នៅកន្លែងនោះ អនុស្សាវរីយ៍ដែលនាងធ្លាប់ទៅលេងកំសាន្ត កាលពីនៅក្មេង ។

ដោយពិតនោះ នាង **រស់-សេរីសុទ្ធា** ក៏ជាអ្នកស្រុកបាត់ដំបងដូចខ្ញុំដែរ គឺផ្ទះនាងនៅភូមិវត្តគ ហួសពីផ្សាលើទៅបន្តិច ។

នៅក្នុងបទនេះ ក្រៅពីសម្លេងដ៏ក្រអួនក្រអៅរបស់អ្នកចំរៀងស្រីនេះ ក៏នៅមានសម្លេងត្រុំប៉ែតមាស របស់លោក **ម៉ិច-សាឈឿន** ដែល **SOLO** អមបណ្ដើរតាម សែនលន្ទង់លន្ទោចរហូតមកដល់សព្វថ្ងៃ ។

# ជ្រោះពេជ្រចិន្តា

| | | |
|---|---|---|
| **បទភ្លេងនិពន្ធកច្រៀង** | **សម្រួលតន្ត្រី** | **ច្រៀងដោយ** |
| **គន្ធ-ម៉ុនឈឿន** | **ហាស់-សាឡុន** | **រស់-សេរីសុទ្ធា** |

១- ភ្នំវែងអន្លាយ រាយផ្កាព័ទ្ធវង់
ដែនដីព្រៃជ្រៅជ្រោះជ្រង ទឹកហូរលងដងបុព្វតា
ខ្ញុំមអ្នកបង់បត់ កត់ចាំរាសនា
កត់ឈ្មោះជ្រោះពេជ្រចិន្តា ល្អាងទឹកនេត្រាគ្មានត្រើយ ។

២- ទឹកជ្រោះបែកផ្សែង ប្រឡែងនឹងថ្ម
អូនយំរងំបន្ត ទឹកភ្នែកស្រក់ហូរគ្មានស្បើយ
ហេតុអ្វីកម្មកាត់ ឱ្យព្រាត់បងហើយ
អូននឹករូបបងគ្មានស្បើយ យំកើយលើផ្នូរជីវ៉ា ។

R- អូនជាក្រមុំ ក្រុងបាត់ដំបង
ជួបនឹងប្រុសបង នៅពេជ្រចិន្តា
យើងបានស្នេហ៍ស្និទ្ធ ផ្តេកផ្តិតសត្យា
រើសយកថ្ងៃជា ពួនផ្លូវតែមួយ ។

៣- តែកម្មកំណាច ឱ្យយើងព្រាត់គ្នា
ព្រាត់ព្រោះមិត្តចិត្តប្ញស្សា ប្រហារស្នេហ៍ឱ្យរំជួយ
ដូចផ្ការលួស ព្យុះបោករលួយ
ជាតិក្រោយសូមព្រះលោកជួយ ជួបនឹងបងមួយកុំឃ្លាត ។

**BLUE**

I/. B3C1 C4D1 C4C3 B3C1 I C4C3 C1C4 C3B4 I
B1B3 B4C1 B4B3 IV A1A3 A4B1 B3B4 B1B3 I
B3C1 C1C0 C1C3 I C4C3 C1B3 B1A3 IV

II/. ---------------- C4C3 B3C4 C3C1 IV

R- B3C4 I C3C1 I B3C C3C1 I CC1 CB B3C1 CB3 IV
C4C4 I DC4 I C1D1 DC4 I DC1 CC4 C1C B1B3 IV

III/. ------------( ដូច $2^0$ Couplet )---------- IV

* * * * *

## ទឹកភ្នែកឪពុក

**ប្រវត្តិរឿង** - បទនេះ ខ្ញុំមានអនុស្សាវរីយ៍កំសត់កម្រជាងគេនៅក្នុងឆាកជីវិត ព្រោះជាបទដែលខ្ញុំសរសេរសំរាប់បញ្ចូលក្នុងខ្សែភាពយន្ត រឿង **ទឹកភ្នែកឪពុក**

រឿងនេះ ខ្ញុំបានថតនៅឆ្នាំ **1964** ជាពេលដែលខ្ញុំបានជួបស្នេហ៍ជាមួយប្រពន្ធខ្ញុំ ព្រោះពេលនោះ នាងក៏ដើរជាតួឯកនៅក្នុងរឿងនេះដែរ ។

គួររំលឹកឡើងវិញខ្លះថា ក្រោយពេលដែលខ្ញុំចេញពីមន្ទីរឃុំឃាំង ព្រោះវិបត្តិប្រលោមលោកឈ្មោះ **ទិមាននរក** នោះមក គ្មានបណ្ណាគារណាហ៊ានទទួលសៀវភៅខ្ញុំយកទៅបោះពុម្ពឡើយ ដោយគេខ្លាចមានរឿង ទើបខ្ញុំមានការលំបាកជាខ្លាំងក្នុងជីវភាពរស់នៅ ។

តែគាប់ជួនពេលនោះ **ផលិតកម្មចក្រខារឡូតាពយន្ត** បានផ្តល់ជាសំភារៈនិងលុយកាក់ខ្លះ ឱ្យខ្ញុំមករៀបចំថត រឿង**ទឹកភ្នែកឪពុក**នេះ ។ គឺរឿងនេះហើយដែលបងប្រុសខ្ញុំឈ្មោះ **គន្ធ-ប៊ុនឆោម** ត្រូវស្លាប់ពាក់កណ្តាលរឿងដោយសារមានជំងឺ ហើយពេលនោះ គាត់ក៏ជាតួកំប្លែង និងជាអ្នកកាន់កាម៉េរ៉ាថតរឿងនោះទៀតផង ។

ចំពោះមុខសភាពការណ៍នេះ ខ្ញុំត្រូវបង្ខំចិត្តរកលុយមកថតបន្តរឿងនេះឱ្យចប់ ហើយសូម្បីតែពេលដែលយកបទទឹកភ្នែកឪពុកនេះទៅថត ក៏ថស្លចពុំទាន់មានលុយឱ្យថ្លៃឈ្នួលអ្នកចំរៀង អ្នកភ្លេង និងថ្លៃ **STUDIO** ដែរ គឺជំពាក់គេសិន ។ ពេលនោះ ខ្ញុំខំសម្ងំ គូរសៀវភៅរូបភាពបានពីរបីរឿងយកទៅលក់ឱ្យគេ ទើបយកលុយមកសងថ្លៃថតបទ **ទឹកភ្នែកឪពុក** នេះ ។

+មានប្រផ្នូលជាមេរៀនក្នុងជីវិតថា រឿងអ្វីក៏ដោយ បើដាក់ចំណងជើងថាទឹកភ្នែកនៅពីមុខ មុខជាជួបប្រទះតែទឹកភ្នែកតាំងពីដើមដល់ចប់ ។ ប៉ុន្តែបទនេះ ពេលដែលចាក់ផ្សាយភ្លាម បានទទួលការនិយមជាខ្លាំងពីគ្រប់មជ្ឈដ្ឋាន ដោយសារពាក្យពេចន៍ទំនុកច្រៀង និង **MELODIE** ធ្វើឱ្យអ្នកស្តាប់អណ្តែតអណ្តូងទៅដល់ពិភពមួយ ដែលស្មានមិនត្រូវ ។

ខ្ញុំក៏មិនភ្លេចគុណដែរ ចំពោះលោក **ទោរ៉ាយ-ហួរ** ដែលជាមិត្តសម្លាញ់រួមអាជីពដូចគ្នា ដែលបានទំនាក់ទំនងនិងជួយសម្រួលការឱ្យខ្ញុំបានថតបទ ទឹកភ្នែកឪពុកនេះ ព្រោះពេលនោះ ខ្ញុំគ្មានស្គាល់អ្នកភ្លេង ឬអ្នកចំរៀងណាម្នាក់ឡើយ។

បទនេះ រៀបចំថតមុនបទ **លាហើយសោភីនី** ទៅទៀត ។...

# ទឹកភ្នែកឪពុក

**បទភ្លេងនិពន្ធចម្រៀង** **សម្រួលតន្ត្រី** **ច្រៀងដោយ**
**គន្ធ..ម៉ុនឈឿន** **ម៉ែ..ម៉ុន** **ស៊ិន..ស៊ីសាមុត**

១- ជើងមេឃវែងឆ្ងាយ ឆ្ងាយពីរូបខ្ញុំ
ប្រៀបបានព្រាណអុំ ឃ្លាតឆ្ងាយចោលខ្ញុំ ក្រៀមក្រំសៅហ្មង
សល់តែបុត្រី បីលើដៃបង ខ្សឹកខ្សួលកន្ទង
យំរកន្ទនល្អង ឱ្យបងខ្លោចផ្សា ។

២- និទារិកា វាសនាឥតន័យ
អ្នកកុំយំថ្វី សូម្បីបក្សីគង់ខំនិទ្រា
ទ្រាំទៅតាមខ្សែជីវិតកំព្រា វាលវង្គសង្សារ
មហាធំធេង វង្វេងកោះត្រើយ ។

R- គាចសាហាវ ព្រហ្មលិខិត
គ្មានអាណិត ដល់ចិត្តស្នេហ៍ខ្ញុំឡើយ
ឱស ឱ !... ធ្វើម្ដេចមច្ចុរាជអើយ
មិនមកផ្ដាច់ជីវិតឱ្យហើយ ឱ្យផុតត្រើយព្យុះកម្មវេរា ។

៣- បើចាំមរណា ឃ្លាតឃ្លាចោលស្ងួន
ម្ល៉េះសម្បូរបក្ខន គ្មានអ្វីជ្រកឆ្ងួន ជ្រកកោនឡើយណា៎
ល្ហើយចុះស្ងួទ្រាំ ចាំភពមេត្តា
ផ្ដល់ព្រេងវាសនា ជួយយកអាសារសង្សារយើងអើយ ។

**BLUE**

I/. C4C1 CB4 CA1 BB1 I B4B1 BC1 I DC4 DD1 DC4 C3C1 IV
B4B1 BC4 ḊC1 CB4 I C1C- B3B1 I BA1 BB1 B4B1 A1B IV
II/.------------------------------BA1 BB1 B3B1 BB4 IV
R- B1BB4 CC4C1 II CC1C4 - DC4C1 I CB4 II CB1 I CB1 - BB1

B3B4 - CCC C4C1 C1C1 - C4 C4C4 D2 DDD **IV**

**III/.** ------------ ( ជួច 2° Couplet ) ------------ **IV**

(ផលិតកម្ម ចក្រវាឡ ភាពយន្ត)

* * * * *

## អនុស្សាវរីយ៍ខ្ពង់ភ្នំសំពៅ -

**ប្រវត្តិបទ** - បទនេះ និពន្ធនិងថតនៅក្នុងអំឡុងឆ្នាំ **1973** ដើម្បីឧទ្ទិសដល់ ភូមិឋានភ្នំសំពៅ ដែលជារមណីយដ្ឋានទេសចរ ដ៏សំខាន់មួយសំរាប់ប្រជាជន នៅក្នុងខេត្តបាត់ដំបង ។

កាលពីក្មេង ខ្ញុំតែងតែទៅលេងភ្នំនេះ នូវរាល់ពេលបុណ្យភ្ជុំបិណ្ឌ ឬ បុណ្យចូលឆ្នាំខ្មែរ ហើយ[illegible]ត្រាទុកនូវអនុស្សាវរីយ៍ជាច្រើន ក្នុងជីវិតស្នេហាបឋមវ័យ ។

ដោយពិតនោះ ភាពប្រជាប្រិយល្បីល្បាញរបស់ភ្នំសំពៅ ដោយសារភ្នំនេះ មានប្រវត្តិអតីតកាលនិងភូមិសាស្ត្រ ទាក់ទងក្នុងរឿងព្រេងនិទានខ្មែរ ដែលគេ ដឹងឮជាទូទៅ គឺរឿង**នាងរំសាយសក់ និងចៅកុល** ។

ភ្នំជាច្រើន ដែលនៅរាយជាប់ៗគ្នា ដូចជាភ្នំក្រពើ ភ្នំសំពៅ ភ្នំនាង រំសាយសក់ ភ្នំទ្រុងមាន់ទ្រុងទា ភ្នំតាម៉ែន តាគត់ តាគ្រែ រួមទាំងភ្នំបន្ទាយ នាង ដែលនៅខាងស្រុកមង្គលបុរី សុទ្ធតែមានជាប់ទាក់ទង នៅក្នុងរឿងព្រេង នេះទាំងអស់ ។

ដោយឡែក នៅលើខ្នងភ្នំសំពៅ មានល្អាងជាច្រើន ដែលប្រៀបដូចជា ផ្នែកផ្សេងៗ នៃសំពៅរបស់ចៅរាជកុបេ ដែលនាំយកគ្រឿងបណ្ណាការ បើក ឆ្លងសមុទ្រ ទៅរៀបការជាមួយនាងរំសាយសក់ នៅនគរតក្កសិលា ។ អ្នក ស្រុកតែងតែនិយាយពីភាពអាថ៌កំបាំង និងអស្ចារ្យផ្សេងៗ របស់ល្អាងល្ហោន

ល្ហាងគក់ទ្រូង ល្ហាងតែងខ្លួន ។ល។ រហូតដល់អាស្រមអ្នកបព្វជិត អ្នកខ្លួនវត្ត និងដូនជីក្មេងៗ ដែលទៅស្វែងរកសច្ចធម៌ និងសេចក្តីស្ងប់នៅលើខ្នងភ្នំនេះ ។

ប៉ុន្តែ អ្វីដែលគួរឱ្យចាប់អារម្មណ៍បំផុត គឺនៅលើខ្នងភ្នំសំពៅ សំបូរណ៍ទៅដោយដើមម្រះព្រៅដុះពាសពេញ ចោលក្លិនប្រហើរក្រអូបឈ្ងុយ ដូចជាក្លិនរបស់សម្ល[ខ្មែរ]មួយមុខ ដែលមានរសជាតិជាប្រពៃណី ។

ទិដ្ឋភាពនិងរឿងរ៉ាវទាំងអស់នេះ បានក្លាយទៅជារឿងកំសត់ព្រាត់ស្នេហ៍ ដែលបកស្រាយដោយនាង **រស់ សេរីសុទ្ធា** ទៅវិញ ហើយបានទទួលការនិយមជាខ្លាំងពីអ្នកស្តាប់ទូទាំងប្រទេស ។

សព្វថ្ងៃ អ្នកដែលមានរឿងរំជួលចិត្ត នៅលើខ្នងភ្នំសំពៅ បានទុកបទនេះជានិមិត្តរូប ហើយបានកំណត់យកក្លិនផ្កាម្រះព្រៅ ជាក្លិនមួយដែលមិនអាចរលាយសាបសូន្យបាន ។

ដោយសារបទនេះ ផ្តើមឃ្លាថា "**បោចផ្កាម្រះព្រៅ**" ទើបគេនិយមហៅឈ្មោះបទថា "បោចផ្កាម្រះព្រៅ" ទៅតាមនោះ តែតាមពិតចំណងជើងដើមពិតប្រាកដ គឺបទ "**អនុស្សាវរីយ៍ខ្នងភ្នំសំពៅ**" នោះវិញទេ ។

## អនុស្សាវរីយ៍ខ្នងភ្នំសំពៅ

| | | |
|---|---|---|
| **បណ្ណាល័យនិពន្ធទំនុកច្រៀង** | **សម្រួលតន្ត្រី** | **ច្រៀងដោយ** |
| **គន្ធ ម៉ិនឈឿន** | **ហាស់ សាឡន** | **រស់ សេរីសុទ្ធា** |

១- បោចផ្កាម្រះព្រៅ បាចទៅក្នុងខ្យល់
រសាត់ទៅដល់ ខ្នងភ្នំក្រពើ
ភ្នំរំសាយសក់ ហាក់គ្មានអើពើ
យើងឈរពីលើ គន់មើលល្ហាងអណ្តូងប្រេង ។

២- ចូលល្ហាងតែងខ្លួន ពួនចាក់គម្ពីរ
អារុណរាត្រី វត្តដូនជីក្មេង

ល្ហងល្ហោង គក់ទ្រូង រងចាំគ្រឿងស្នេហ៍
យើងចាយហើយគេង ស្តាប់ភ្លេងជួនល្ហងផ្កាស្វា ។

R- អូនចាំទាំងអស់ អនុស្សាវរីយ៍
កាលយើងទាំងពីរ ក្រេបរសស្នេហា
ឥឡូវបាត់សូន្យ ឃើញតែផ្នូរា
ឯល្ហងផ្កាស្វា ក្លាយជាមរណៈ ។

៣- ពន្លកម្រះព្រៅ ដុះឡើងវិញហើយ
បាត់តែត្រាណត្រើយ ទ្រូងអូនអួលអាក់
ផ្នូរមួយយើងសាង ទុកស្លាប់ពីរនាក់
នៅតែប្រឡាក់ ស្នាមឆ្លាក់ឈ្មោះអូននិងបង ។

**BLUE**

I/. C4D C4C B4C B4B I B2B1 A2B B2B4 C0C IV
C4C4 CC C4C2 CB4 I B1B2 B4C I C0C B4B2 BB1 IV

II/. - - - - - - - - - - - - - - - - B1B2 B4C I C0C B4B2 B1B IV

R- BC4 I C0C I C0C B4B2 I B4B B4B2 B4B B4C IV
CD0 I DC4 I DC4 C2C4 I C2C2 C4C4 C2B2 BC2 IV

III/. - - - - - - - - - ( ដូច 2° Couplet ) - - - - - - - - - -
(អមដោយភ្លេង **Solo Trompette** របស់លោក គង្គ ប៊ុនឈឿន)

* * * * *

# នាងដើរទៅណា ?

| បទភ្លេងទំនុកច្រៀង | សម្រួលតន្ត្រី | ច្រៀងដោយ |
| --- | --- | --- |
| គង្គ-ប៊ុនឈឿន | ហាស់-សាឡន | ស៊ីន-ស៊ីសាមុត ប៉ែន-រ៉ន |

(បទនេះនិពន្ធនិងថតនៅឆ្នាំ 1973 នៅក្នុងកម្រងកាសែត កម្មោះហុងដា កញ្ញាប៉េសេ)

១.ប- នាងអើយ នាងអើយនាង នាងដើរទៅណា ?
រូបស្អាតដូចកូនទេវតា
ស- ខ្ញុំយាត្រាទៅលេងផ្ទូនទាវ
ប- ប្អូនសក់ សៀតផ្កា ដូចលាវ ទៅផ្ទូនទាវមានការអ្វី ? ។
២.ស- ផ្ទូនទាវ គេធ្វើបុណ្យបញ្ចុះសីមា
និងមានរាំវង់ លក់ផ្កា នៅទីធ្លា វត្តឯករង្សី
ប- ត្រូវហើយ ត្រូវហើយចរណៃ
បងសូមស្រី ទៅរាំដែរ ។
R.ប- អ៊ូ ! អ៊ូ ! អ៊ូ ! អ៊ូ ! អ៊ូ !.. អ៊ូ ! អ៊ូ ! អ៊ូ ! អ៊ូ !
អ៊ូ ! អ៊ូ ! អ៊ូ ! អ៊ូ ! អ៊ូ !.. អ៊ូ ! អ៊ូ ! អ៊ូ ! អ៊ូ !
ស- អ៊ូ ! អ៊ូ ! អ៊ូ ! អ៊ូ ! អ៊ូ !.. អ៊ូ ! អ៊ូ ! អ៊ូ ! អ៊ូ !
អ៊ូ ! អ៊ូ ! អ៊ូ ! អ៊ូ ! អ៊ូ !.. អ៊ូ ! អ៊ូ ! អ៊ូ ! អ៊ូ !
៣.ស-ក្រមុំភូមិវត្តក្តុល និងវត្តស្លាកែត
ឮល្បីល្បាញគ្រប់ទំណួខេត្ត ពេលខែចែត្រ ចេញដើរហូរហែ
ប- ជួបកម្លោះស្រុកសង្កែ តាមសុំស្នេហ៍ ញ៉ែតាមផ្លូវ ។

**BOLERO-FOX**

I/. B3C1 - B3C1B3 C1B3 C1C4 I C4C1 C4C1 B3B3 -
C1 C4C1 C4C1 C4D1 I D1C4 D1C4 C1C1 - C4 C1B4 C1 B4B3 III
II/. - - - - - - - - - - - - - - - - - - D1C4 D1C4 C1C1 - C4 C1B4 C1 B4B3 III

R/. D1 I D6D4 DD1 I D6D4 DD1 - D4D1 CC4 - DC4 CC1

D1 I D6D4 DD1 I D6D4 DD1 - D4D1 CC4 - DC4 CC1

III/. ----------( ដូច 2° Couplet )---------

(ថតនៅ STUDIO ចាបធុន)

● ● ● ● ●

# វិញ្ញាណផ្លូវខ្ញុំ

**ប្រវត្តិបើម** - ខ្ញុំបានស្គាល់នាង **សុ សាវឿន** តាំងពីក្នុងអំឡុងឆ្នាំ 1965 គឺពេលដែលនាងទៅច្រៀងក្នុងវង់**តន្ត្រីយោធាតិរម្យ** ដែលមានលោក **កែច អែម** ជាប្តី និងជាអ្នកផ្លុំត្រុំប៉ែត ដ៏ល្បីម្នាក់ប្រចាំនៅក្នុងវង់ភ្លេងនោះទៀតផង ។

ពេលនោះ លោក**កែច អែម** បានសុំឱ្យខ្ញុំជួយតែងបទចំរៀងខ្លះៗសំរាប់ឱ្យនាង **សុ សាវឿន** ច្រៀង ព្រោះកាលណោះនាង **សុ សាវឿន** មិនសូវជាល្បីល្បាញប៉ុន្មានឡើយ ។

បទមុនគេដែលខ្ញុំបានតែងឱ្យនាងច្រៀងគឺឈ្មោះថាបទ **វិញ្ញាណផ្លូវខ្ញុំ** នេះឯង ហើយជាបទដែលមានលក្ខណៈសាច់រឿងប្លែក គឺស្ត្រីអភ័ព្វស្នេហ៍ដែលស្លាប់ទៅហើយ អាចស្រែកច្រៀងពីក្នុងផ្នូរមកប្រាប់សង្សារវិញបាន ។

បទនេះ មិនមែននៅក្នុងកម្រងកាស្សែត ឬសំរាប់បញ្ចូលទៅក្នុងខ្សែភាពយន្តណាមួយទេ គ្រាន់តែផ្សាយតាមវិទ្យុប៉ុណ្ណោះ ប៉ុន្តែក្រោយដែលចេញផ្សាយទៅ បានធ្វើឱ្យអ្នកស្តាប់គ្រប់មជ្ឈដ្ឋាន មានការភ្ញាក់ផ្អើលជាខ្លាំង ហើយនាង **សុ សាវឿន** កាន់តែមានឈ្មោះល្បី ចាប់តាំងពីពេលនោះមកដែរ ។

ក្រោយមក ដោយសារបទនេះល្បីខ្លាំងពេក ទើបមានក្រុមហ៊ុនថតថាសមួយបានមកទាក់ទងសុំទិញថតបញ្ចូលទៅក្នុងថាស និងក្នុងកាស្សែត ហើយពេលដែលនាង **សុ សាវឿន** ចេញទៅសំដែងច្រៀងនៅទីណា អ្នកស្តាប់តែងតែសំណូមពរឱ្យច្រៀងបទនេះ មិនដែលលោះខានឡើយ រហូតដល់មានគេ

ទិញរង្វាន់អនុស្សាវរីយ៍ឱ្យនាងជាច្រើនទៀតផង ។

ទំនុកច្រៀង របស់បទនេះ បញ្ជាក់ឡើងពីទំនួញអភ័ព្វស្នេហ៍របស់នារីម្នាក់នៅស្រុកអូរជ្រៅ (កាលណោះនៅក្នុងខេត្តបាត់ដំបង) ដែលទោះបីជានាងស្លាប់ទៅហើយក្តី ក៏អង្វរឱ្យប្តីដែលនៅរស់ ជួយថែរក្សាចិញ្ចឹមកូនផង ។

**MELODIE** របស់បទនេះ ខ្លោចផ្សាមែនទែន ដែលអមដោយសម្លេងវីយូឡុងរបស់លោក **មាស.សាម៉ន** ធ្វើឱ្យខ្ញុំនៅតែនឹកគិតដល់អ្នកចំរៀងកំប្លែងរូបនេះជានិច្ច គឺមិនត្រឹមតែចេះច្រៀងប៉ុណ្ណោះទេ គឺថែមទាំង ចេះគួតវីយ៉ូ ឡុង ដ៏ពិរោះលន្វង់លន្វោចទៀតផង ។

# វិញ្ញាណផ្ទូរខ្ញុំ

| | | |
|---|---|---|
| **បងឆ្លេងទំនុកច្រៀង** | **សម្រួលតន្ត្រី** | **ច្រៀងដោយ** |
| **គង្គ.ប៊ុនឈឿន** | **កែវ.អែម** | **ស៊ុ.សាវឿន** |

**INTRO-** អនិច្ចាកម្មចាស់ !.... ឈឺណាស់ មិនទាន់បាត់ស្នាម !!

១- វេនស្នេហ៍ វេនកម្ម ចិញ្ច្រាំដួងចិត្ត
ដំណើជីវិត រួតរិតបែកស្រាំ កម្មនាំមរណា
អណ្តាតស្វាមី លក់ក្តីមេត្តា
បេះដូងបូស្សា ប្រហារភ្លេងការកាត់ត្រើយ ។

២- ផ្ទូរលាន់រងុំ អូនយំក្នុងផ្នូរ
អតីតៈស្រែកថ្ងូរ កូនយំទ្រហោរថ្ងូររកនឹហើយ
ចិត្តបងដាច់ណាស់ ម្ចាស់ស្នេហ៍អូនអើយ
កូនយើងធំហើយ ម្តេចឡើយព្រងើយនឹងគ្នា ។

R- ធ្វូបបីសរសៃ ឆេះអស់
បងគ្មានស្រណោះ សោះកូនកំព្រា
បងដេកលើព្រំ អូនយំរងា

ខ្វងខែកស្រែកទារ កម្មពៀរលោកិយ៍ ។

៣- និ ! ស្រុកអូរជ្រៅ វណ្ណៅទឹកភ្នែក
សូមជួយរំលែក ជួយប្រកាសស្រែក ហែកលោកទាំងបី
ធ្វើបុណ្យដាក់ចាត្រ ឱ្យស្អាតជាតិថ្មី
ជាតិនេះអប្រិយ៍ កុំឱ្យជួបប្ដីកាមគុណ ។

**SLOW**

I/. BB4 CC1 C2D0 DC4 I D2D2 C4C4 I C1C C4B4 C1C C4C1 IV
BB1 B4C C4C B4B1 I BB1 B4B I BB4 CC1 I C2C4 IV

II/. ------------------------ CC C1B I B1B4 IV

R- CC C1B - B4B4 I B4B1 BB4 C1C C4C1 IV
C4C1 C4D I C4C1 C4C4 I BB1 B4C B4C1 - B4C IV

III/ -----------( ដូច 2° Couplet )--------

(ប្រគុំដោយវង់តន្ត្រី យោធាភិរម្យ)

*****

## ដានជើងក្របី

| | | |
|---|---|---|
| បទភ្លេងនិពន្ធប្រៀង | សម្រួលតន្ត្រី | ច្រៀងដោយ |
| គន្ធ ប៊ុនឈឿន | កែវ អ៊ែម | ឆ្នូច សេង |

(បទនេះផតផ្សាយតាមវិទ្យុ និពន្ធនៅឆ្នាំ 1966 )

១- ដានជើងក្របី វិស័យដូចដានលិខិត
ដានជាន់ដាន លំអានជីវិត
នេះហើយគួរគិត ជីវិតលោកិយ៍
វិលចុះវិលឡើង និរន្ត-និរន្តរអចិន្ត្រៃយ៍
ស្ទួន្យចាស់ថ្នាស់ថ្មី ពិតតាមសំដីនៃព្រះសាស្ដា ។

R- ជីវិតមនុស្សអើយ

ម្ដេចឡើយ វង់ទុក្ខខ្មោចផ្សា
វាលវង្វេងសង្សារ
គ្មានមនុស្សសត្វណា ជៀសផុតស្នូចឡើយ ។

**BLUE MARCHE**

I/. C4C4 C4C4 I DC4 C3C1 CB3 -
A1CB3 CB B1B3 - CB B1B3 B4C C4C II
B3C C1C4 - C3C1 DC1 CB3 B3B3 -
C1C B3B1 - BA1 BB1 - BB1 B3C II
R- BB1B3C I C4C1 CB3 B3B3 -
C1C1B3B1 - BA1 BB1 - CB3 B1B II
- - - - - - ( BIS ) - - - - - - -
(ប្រគុំដោយវង់តន្ត្រី យោធាភិរម្យ)

*****

## ដួងចិត្តវិប្បយោគ

| បទភ្លេងទំនុកច្រៀង | សម្រួលតន្ត្រី | ច្រៀងដោយ |
|---|---|---|
| គង្គ ម៉ុនឈឿន | ម៉ែរ ម៉ុន | ស៊ីន ស៊ីសាមុត |

(បទនេះនិពន្ធនិងចេញផ្សាយក្នុងវិទ្យុតាំងពីឆ្នាំ 1965)

១- ដួងចិត្តមួរហ្មង បង់ផ្លូវស្នេហ៍ពីនិរា
ក្នុងដួងចិត្តវិប្បយោគខ្មោចផ្សា ខ្ទះខាតហត្ថាធ្លាប់ថ្នមត្រកង
រាងហើយ ស្នេហាអើយ កៀកកើយតែក្ដីមួរហ្មង
សូមផុតទុក្ខផង លុះលង់ក្រោមព្រះធរណី ។
២- ដួងចិត្តស្រែកថ្ងូរ សួរសៀងគួរឱ្យស្រណោះ
លោកយើងនេះ ដូចល្ខោនគ្មានខុស ឆរពោកបន្ទុះស្ទុះស្លាប់ជីវិ
ពីនេះទៅឃ្លាតឆ្ងាយ ដូចផ្កាយនិងព្រះធរណី

ចែកជាអាប្បី ទឹកហូរស្រក់ទឹកនេត្រា ។

៥- ទឹកភ្នែកបងស្នេហ៍ ដែលនៅមានទុក្ខ

ខ្លួនសុំអភ័យទោស ពិតតាមបណ្ដាំព្រះសាស្ដា

អធិដ្ឋានប្រាថ្នា កុំអ្វីឡើយ

ឱ្យអូនពិសោធន៍ បេះភាគ់ខ្លី ។

៦- ផ្លូវបីផ្លូវបៀង ប៉ះផ្កាស្នេហ៍ទៅហើយអើយ

ផ្កាស្រពោនឆ្លងលោកហើយ បក់ហើយហួសចាត់ហាក់កាត់អាល័យ

ស្រអែមផ្លូវស្រមោល ពេលអាលក្នុងផ្លូងហឫទ័យ

លុះជីវិតក្ស័យ សន្សំតែទឹកនេត្រា ។

**SLOW**

I/. C5C2 C2C2 - D0C5 D0C2 C5C0 - B5C0C2 C0B5 B4B2
C0B2 C0B0 B2B4 B5C0 I C5D2 D0 C5C2 I
B5B2 B0B2 B4B5 - C2 - C5 - D0 - B5 I B2B5 C5C2 C2C2 II

II/. - - - - - - - - - - - - - - - - - - - - - - - - - - - - - B2D0 C5C2 C0B5 II

R- C2C4C5D2 - C2C4C5D0 I C5B5 C2C5 I
B2B4B5B2 - B4B0B2C2 I C2C4 C2C4 C5D0 - C2 C0C0 C0 -
C2C0 B5C0 C2C4 C5D0 II

* * * * *

## បណ្ដាំទៅផ្កាស្រពោន

| បទភ្លេងនិពន្ធច្រៀង | សម្រួលតន្ត្រី | ច្រៀងដោយ |
|---|---|---|
| គន្ធ មុនឈឿន | កែវ អែម | តុប តេង |

(បទនេះដកស្រង់ពីប្រលោមលោករឿង ផ្កាស្រពោនត្រង់វគ្គ ប៊ុនធឿន សរសេរសំបុត្រទៅប្រាប់នាងវិធាវី)

១- អូនអើយ សេចក្ដីស្នេហានៃបង

មិនចង់ឱ្យធ្នូនល្អង ស្នេហ៍ស្នងនាងមានទុក្ខា
បង ធ្លាក់ខ្លួនក្រហើយពុំងា
ដល់ពេលចេញធ្វើការ មិនបានប្រាក់ខែប៉ុន្មាន ។

២- ហេតុនេះចូរអូន កុំប្រទូស្តរាយ
និងបំណងអ្នកម្តាយ ណាំឆោមស្រស់កល្យាណ
ព្រោះ លោកចង់ឱ្យអូនមានបាន
មិនចង់ឱ្យកល្យាណ រំខានមានទុក្ខទេស្ងួន ។

R- សូមស្ងួន អូនកុំខឹងឡើយ
ពេលនេះកម្មយើងដល់ហើយ ទើបយើងមិនបានជួបជួន
កុំយំអី នាំតែស្គមខ្លួន
ជាតិនេះមិនបានជួបជួន ជាតិក្រោយសូមជួបជាថ្មី ។

៣- វីអើយ បងនៅស្រឡាញ់ជានិច្ច
តែសូមអូនបំភ្លេច កុំទុកបងជាប្តី
ព្រមរៀបការ ទទួលពរជ័យ
បងសូមភ្ជាប់និស្ស័យ រូបស្រីដួចប្អូនបង្កើត ។

**BLUE**

I/. B1B1 C1C1 C4C1 CC1 I CB4C1 CB4 I B4C C1D C4C1 III
C I B1B3 B4C1 CB4 I B3B1B3 B1B I A1B B1C B4B1 IV
II/.------------------- BB1B3 B1B I A1B B1C B1B4 IV
R- C1C4 I DD1 C1C4 I C1C4 DC4 C3C1 I C1C1 CC3 DC1 III
C I C1C CC1 B1B4 - CB4 C1B1 BB4 - B1B4 CC1 C4C IV
III/. -------- ( ដូច $2^0$ Couplet ) ------

(ចតផ្សាយតាមវិទ្យុជាតិ)

# នេះឬជីវិត ?

**ប្រវត្តិបើច**- បទនេះ ខ្ញុំនិពន្ធនៅរវាងចុងឆ្នាំ 1970 ក្រោយដែលរដ្ឋប្រហារ ១៨ មិនាបានកន្លងផុតទៅ ។ កាលណោះ មានផលិតកម្មមួយឈ្មោះ **គខជ័យភាពយន្ត** ដែលដឹកនាំដោយអ្នកស្រី **សំអាត [illegible]** បានពឹងពាក់ឱ្យខ្ញុំសរសេរបទនេះ សំរាប់ដាក់បញ្ចូលទៅក្នុងខ្សែភាពយន្តរបស់គាត់ ឈ្មោះថា **នេះឬជីវិត ?** ។

តាមពិត បទនេះ តាមសាច់ទំនុកច្រៀង គឺត្រូវតួស្រីជាអ្នកច្រៀង តែដើម្បីសង្កត់សាច់រឿងឱ្យកាន់តែធ្ងន់ថែមទៀត ទើបយើងមិនកំណត់ឱ្យតួច្រៀងផ្ទាល់ គឺយកសម្លេងអ្នកចំរៀងឯក **ស៊ីនស៊ីសាមុត** បណ្តែតជា FOND វិញ ។

ថ្វីបើបទនេះ មិនបានថតនៅក្នុងកម្រងកាស្សែតណាមួយ ក្រៅពីចាក់ផ្សាយតាមវិទ្យុ តែវាមានឥទ្ធិពលអាចសណ្តំបេះដូងនរីខ្ទទៅ ដែលមានរឿងកំសត់កម្រ ព្រាត់ប្រាសនិរាសគូជីវិត តាមរយៈសម្លេងមាសរបស់អ្នកចំរៀងឯក **ស៊ីនស៊ីសាមុត** ធ្វើឱ្យអ្នកស្តាប់រណ្តំអួលអាក់ជាប់ជានិច្ច ។

បទនេះ មិនបានថតនៅ STUDIO អ្នកស្រីវណ្ណច័ន្ទ STUDIO របស់លោក ចាបធុន ឬ STUDIO នៅក្រសួងឃោសនាការជាតិនោះទេ ដោយបន្ទាន់ពេក លោក**ស៊ីនស៊ីសាមុត** ក៏បាននាំខ្ញុំទៅថតនៅ STUDIO របស់ FILM-FARK ប្រគុំដោយវង់**តន្ត្រីឃោសនាតិរម្យ** ។

ប៉ុន្តែ ដោយសារសភាពការណ៍ភ័ន្តច្រែរបស់ប្រទេសជាតិ បទនេះឃើញមានចាក់ផ្សាយដោយកម្រណាស់ មិនដឹងជាកាស្សែតដើមនៅសល់ឬរលប់រលាយបាត់ទៅណាអស់ហើយ ។

ក្នុងន័យ សោកស្តាយនូវបទចំរៀងដ៏សំខាន់នេះហើយ ទើបនៅឆ្នាំ 1989 **ផលិតកម្មរស្មីមេគង្គភាពយន្ត** បានឱ្យខ្ញុំរៀបចំបទនេះសារជាថ្មី ដើម្បីបញ្ចូលទៅ

ក្នុងខ្សែវីដេអូមួយរឿង ឈ្មោះថា **សែនឆារុណា** ដែលមានឲ្យបខ្ញុំជាអ្នកដឹកនាំរឿងផ្ទាល់ ប៉ុន្តែផ្ទាស់មកឱ្យនាង **សុខ សុខុម** ច្រៀងវិញ ។ បទនេះ នៅតែទទួលការពេញនិយម ពីអ្នកស្តាប់ជាខ្លាំង ហើយនៅតែរក្សាអនុស្សាវរីយ៍តាមទឹកដមសម្លេងមាសរបស់លោក **ស៊ីន ស៊ីសាមុត** ដដែល... ។

## នេះឬជីវិត ?

**បទភ្លេងនិពន្ធច្រៀង** | **សម្រួលតន្ត្រី** | **ច្រៀងដោយ**
**គន្ធ ប៊ុនឈឿន** | **កែវ អែម** | **ស៊ីន ស៊ីសាមុត**

១- ស្ងួ ដើរចេញទ្រូងពេញដោយទុក្ខ
ជាជាងអោនក្រាបលាក់មុខ
ឱ្យប្តីសោយសុខ សើត្រើយវាសនា
ល្ងោនស្នេហ៍សង្គ្រាម ហូរឈាមដាបលោកបូស្សា
កងចក្រឬផ្កា ចារចងជាអន្ទាក់ ? ។

២- កូន ក្នុងផ្ទៃ ស្មាដៃឃាតករ
ទឹកក្រុត ផុតទ្រូងអ្នកក្រ
យកឈាមលាយស្គរ ស្គរជាច្រវាក់
នេះឬជីវិត ងងឹតដោយមាសបុណ្យស័ក្តិ
អណ្តាតផ្ទាប់ប្រាក់ ពាក់ស្រោមស្នេហ៍ឃោរឃៅ ។

R- ឱ ព្រៃភ្នំ អ្នកកុំចំអក
បើជាតិនេះប្រែជាខក ក៏ខកព្រោះក្តីល្ងង់ខ្លៅ
ស្ងួ លប់លាងស្នាមជំពៅ
មិនឱ្យធ្លាក់ជ្រោះជ្រៅ សំណៅអវិចីស្នេហា ។

៣- ទ្រាំ ស្ងួទ្រាំពាំខ្មោះជីវិត
ផ្ទេចភ្នែកខ្ញើមភពងងឹត រំលាយអតីតដែលឥតខ្លឹមសារ

បើគេត្រឡប់ គួររាប់ទុកជាគម្រោ

ដូចពាក្យលោកថា អារសាច់ជូនខ្លា ទើបនៅស្រុកបាន ។

**SLOW**

I/. C4 I DC4 C2C C2C4 I CB2 CB1 B2B - CC1 CB3 BB2 B2B2 II
B2B4 B2B I C4C2 DC4 CC - C2C4 I B2B4 I B4 CC2 B4C III

II/.--------------------- C2C4 I B2B4 I B1 BB1 A2B III

R- A - A2A4 B2B4 A2B I A2B B2B4 C2C I C4C2 DC4 CC III
D0 I D2D0 C4 C2C4 - C4 D0C2 C B2B4 I B4B4 B1B CC2 III

III/. ----------( ដូច $2^0$ Couplet )------- IV

✿ ✿ ✿ ✿ ✿

# ទាសករស្នេហា

| បទភ្លេងនិពន្ធទំនុកច្រៀង | សម្រួលតន្ត្រី | ច្រៀងដោយ |
|---|---|---|
| គន្ធ ម៉ិនឈឿន | កែម ឆែម | គុជ គេត |

(បទនេះនិពន្ធនៅឆ្នាំ 1970 ផ្សាយតាមវិទ្យុ)

១- បុណ្យវាសនា ខ្ញុំឈោងមិនដល់
បានជានិម័ល នាងមិនមេត្តា
ចាំ ទ្រាំរង់ចាំ គ្រប់គ្រា
ទាំងដួចចិត្តវងា ពុំមានក្ដីនឿយណាយ ។

២- រស់ខ្ញុំរស់ ដោយក្ដីសង្ឃឹម
ប្រៀបថ្នឹម បានទៅនឹងសត្វទន្សាយ
ដែល រង់ចាំច័ន្ទឯនាយ
ទាំងដួងចិត្តខ្វល់ខ្វាយ ក្រហាយតែក្នុងហឫទ័យ ។

R- និទេពធីតា !

ដឹងទេថា បងនេះជាទាសាស្រី

បើមិនប្រណី

គង់តែក្ស័យ ជីវិតខ្ញុំមិនខាន ។

៣- រង់ ខ្ញុំរង់ដោយចិត្តអង្វរ

សូមទ្ទួនល្អង អាណិតប្រោសប្រទាន

ក្លិន ស្រស់សម្ផស្សកល្យាណ

រួមជាគូភ្ញុំផាន កើយប្រាណលុះគ្រាក្សិណក្ស័យ ។

**BOLERO**

I/. B3 - CB1 BB1 B3C II C1 C4C1 - CB3 B1B3 BB1 III

B1 - B3 B1B3 CB1 I B1 BA1 BA - A1 AA1 BA III

II/. ---------------- B1 BA1 BA - B3B1 BA1 AB III

R- B - B3 - C - D I C4 C1C - B3B1 BB1 B2B3 III

C4 - C1 - CB3 I A1 CB3 - CB3 B1B3 BB1 III

III/. --------- ( ដូច $2^0$ Couplet ) ---------- III

❀ ❀ ❀ ❀ ❀

## ស្ពានកំពង់ហ្លួង

**ប្រវត្តិដើម** - បទនេះ ខ្ញុំបាននិពន្ធនិងថត នៅក្នុងឆ្នាំជាមួយគ្នានឹងបទវិញ្ញាណផ្ទរខ្ញុំដែរ ប៉ុន្តែខ្លឹមសាររបស់ទំនុកច្រៀង គឺយោលទៅតាមសំណូមពររបស់នាង **សុ-សាវឿន** ព្រោះនាងចង់ឱ្យខ្ញុំសរសេរពីភូមិកំណើតរបស់នាង គឺភូមិកំពង់ហ្លួង ។

អ្វីទាំងអស់ ដែលជាជីវិតស្នេហាបឋមវ័យរបស់នាង**សុសាវឿន** បានត្រូវប្រមូលផ្តុំមកបកស្រាយ នៅក្នុងបទចំរៀងនេះ ពិសេសគឺទីតាំងដ៏សំខាន់ ដែលធ្វើឱ្យស្នេហារបស់នាង ចាប់កំណើតឡើងនិងរលាយទៅវិញ នៅលើស្ពាន

កំពង់ហ្លួងនេះឯង ។

បទនេះ ប្រគុំដោយវង់តន្រ្តី **យោធាភូមិភាគ** ថតនៅ STUDIO វិទ្យុជាតិ ប៉ុន្តែក្រោយពីចាក់ផ្សាយទៅ មានប្រជាប្រិយភាពល្បីល្បាញខ្លាំងក្លា ទើបក្រុមហ៊ុនថតថាស បានទិញយកទៅថតបញ្ចូលក្នុងថាស និងផ្សាយក្នុងកាសែ្សត ។

សព្វថ្ងៃ មិនត្រឹមតែនាងសូសាវឿន យកទៅច្រៀងនៅប្រទេសបារាំងប៉ុណ្ណោះទេ សូម្បីតែក្នុងស្រុកខ្មែរ ក៏គេនិយមយកបទនេះទៅច្រៀងស្ទើរគ្រប់ទិសទីដែរ ខ្លះក៏ច្រៀងតាមទំនុកដើមទាំងស្រុង ខ្លះក៏យកទៅកែប្រែទំនុកច្រៀងថ្មីវិញ ។

ប៉ុន្តែ គួរឱ្យស្តាយណាស់ ក្រុមហ៊ុនថតការ៉ាអូខេខ្លះ បានយកបទនេះទៅថតដោយសរសេរខុសទំនុកច្រៀងច្រើនអន្លើ ប្រហែលជាស្តាប់អ្នកចំរៀងដើមមិនច្បាស់ក៏មិនដឹង ។ល។

អាស្រ័យហេតុនេះ ចាប់ពីពេលនេះទៅ សូមអស់លោកអ្នកនាងកញ្ញាដែលច្រៀង កុំឱ្យមានការភ័ន្តច្រឡំ **Paroles** តទៅទៀត ហើយខ្ញុំសូមឧទ្ទិសបទនេះដល់វិញ្ញាណខ័ន្ធលោក **កែប-អែម** ដែលលោកបានខ្នះខ្នែងជួយជ្រោមជ្រែងធ្វើ **Arrangement** បទ និងរៀបចំប្រគុំរហូតទាល់តែបានសំរេច ចេញជារូបរាង ទុកគេរមតីករហូតមកដល់បច្ចុប្បន្ននេះ ។

ស្ពានកំពង់ហ្លួង គឺជាស្ពានស្នេហារវាងលោក **កែប-អែម** និងនាង **សូ-សាវឿន** ដែលចិតនៅជាអមតៈ ក្នុងបេះដូងប្រជាជនខ្មែរគ្រប់ពេលជំនាន់ ។...

## ស្ពានកំពង់ហ្លួង

| | | |
|---|---|---|
| **បទភ្លេងទំនុកច្រៀង** | **សម្រួលតន្រ្តី** | **ច្រៀងដោយ** |
| **គង្គ-ប៊ុនឈឿន ៖** | **កែប-អែម** | **សូ-សាវឿន** |

១- សុរិយាលាព្រៃ រៃយំហោកប្រាណ
ក្លិនក្រៃបរះរោយលើស្ពាន ជាឋានវិមានស្នេហ៍ខ្ញុំ

[illegible] សោករណ្តំ
[illegible] សុំក្តីមេត្តា ។

២- រាត្រី ដែលយើងជួបគ្នាដំបូង
លើស្ពាននៅកំពង់ហ្លួង ផ្កាយព្រោងព្រាតលើមេឃា
ពេលដែលយើងបែក ស្ពានស្រែកអង្វរសួរថា
តើម្ចាស់ខ្ញុំទៅឋានណា ប្រាថ្នាសូមជួបជាថ្មី ។

R- ឱ កំពង់ហ្លួង ដួងមាសផាស់កម្ម
កន្សែងចិញ្ចៀនស្រែកផ្តាំ ចារចាំចិត្តចងនិងថ្ងៃ
បើបងរៀបការ ប្រាថ្នាគូថ្មី
បងអើយកុំភ្លេចហៅស្រី ចងដៃប្រុសថ្ងៃកុំខាន ។

៣- គូពុំបានព្រៀង ច្រៀងតែកម្មផល
លេបផ្សែងទុក្ខសោកកង្វល់ ដែលផ្តល់ឱ្យយើងចែកឋាន
. កាត់សាច់មួយដុំ ប្រាថ្នាសុំឱ្យសុខសាន្ត
បើជាតិនេះប្រែខកខាន ជាតិក្រោយសូមបានជួបអើយ ។

**BLUE**

I/. C4C2 C1C B3C C1C4 I C1C2 DC1 CB3 I BB3 CB3 BB1 II
CB3 B1B I B3C C4C1 C1C1 - B3 C1C B3 B1B3 I BB3 CB1 BA1 IV
II/. ---------------------------------- BB1 CB3 B1B IV
R- B1B1 B1B1 BB4 B3B1 I B1B4 CB4 CC1 - C2C1 CC4 I CB3 III
B3B3 CC C4D C4B3 I BA1 BC B3B3 - [illegible] BB1 IV
III/. ------------ ( ដូច 2$^{0}$ Couplet ) ---------- IV

● ● ● ● ●

# ស្បៃអក្សរា ចំប៉ាបាណន់

**ប្រវត្តិបើម** - បទនេះ ដកស្រង់ចេញពីប្រលោមលោក មួយឈ្មោះថារឿង **ស្បៃអក្សរា ចំប៉ាបាណន់** ដែលខ្ញុំបានសរសេរចុងក្រោយគេ នៅរវាងដើមឆ្នាំ 1975 ហើយបានបោះពុម្ពផ្សាយរួច ទើបពួកខ្មែរក្រហមបានវាយចូលភ្នំពេញ។

គោលដៅរបស់ចំរៀង គឺចង់រៀបរាប់ពីជីវិត កម្លោះម្នាក់ជាកូនអ្នកក្រ បាន លបលួចស្នេហាជាមួយកូនក្រមុំម្ចាស់ស្រុកបាណន់ រហូតដល់ត្រូវគេយកទៅ វាយធ្វើបាបយ៉ាងសែនទារុណ ។ល។

រឿងនេះ ជារឿងពិត កាលពីសម័យអតីតកាលមួយ កាលដែលសេចក្តី ស្នេហាបានឋិតនៅក្នុងកំពែងវណ្ណៈ យ៉ាងតឹងរឹងជាទីបំផុត ម៉្លោះហើយអ្នកក្រ គោកយ៉ាក មិនអាចផ្សងស្នេហ៍ជាមួយអ្នកមានអំណាច និងមានទ្រព្យសម្បត្តិ ហូរហៀរបានឡើយ ។

ស្រុកបាណន់ ជាស្រុកមួយ ក្នុងចំណោមស្រុកជាច្រើនរបស់ខេត្តបាត់ដំបង ហើយឋិតនៅភាគខាងលើ ដើមស្ទឹងសង្កែ ដែលបានលាក់ទុករឿងពីអតីតកាល មួយយ៉ាងរន្ធត់ខ្លោចផ្សា ធ្វើឱ្យអ្នកស្រុកនៅទីនោះចងចាំ ស្ទើរក្លាយទៅជារឿង ព្រេងនិទាន... ។

កាលណោះ ក្រុមហ៊ុន **[illegible]** បានតម្រូវធ្វើបទចំរៀងមួយកាសែ្សត ទៀតដែរ ហើយខ្ញុំក៏សំរេចដាក់ឈ្មោះកាសែ្សតនោះថា **ស្បៃអក្សរា ចំប៉ាបាណន់** តាមចំណងជើង ប្រលោមលោករបស់ខ្ញុំ ។

ប៉ុន្តែ គួរឱ្យស្តាយក្រៃលែង ក្រោយដែលកាសែ្សតនេះផលិតសំរេចហើយ រៀបចំចេញផ្សាយ ស្រាប់តែព្រឹត្តិការណ៍នយោបាយរបស់ប្រទេសជាតិ នៅថ្ងៃ 17 មេសា 1975 បានបង្ខំឱ្យអ្វីៗ ប្រែប្រួលផ្លាស់ប្តូរអស់រលីង ។

កាសែ្សតថ្មីនេះ មិនដឹងជាត្រូវបំផ្លាញចោលអស់ ឬក៏ត្រូវម្ចាស់ក្រុមហ៊ុន

នាំយកទៅជាមួយ ? ព្រោះថ្ងៃក្រោយមក ខ្ញុំបានទទួលដំណឹងពីជនម្នាក់ថា **ឡាក់ សេា** បានភៀសខ្លួនទៅប្រទេសវៀតណាម តែមិនដឹងនៅមានជីវិតរហូតដល់សព្វថ្ងៃឬយ៉ាងណា ឯកាស្សែត **ស្នេហ៍អក្ខរាចំប៉ាបាណន់** មិនដឹងជាអន្តរាយយ៉ាងណាទៅហើយដែរ ។

ដោយសោកស្តាយនូវ **Melodie** របស់បទនេះ ទើបនៅពេលដែលខ្ញុំបានថតវីដេអូរឿង "**ព្រះគុណម៉ែ**" កាលពីឆ្នាំ **1989** ខ្ញុំក៏យក **Melodie** របស់បទនេះ មកដាក់ទំនុកថ្មី សំរាប់បញ្ចូលក្នុងផ្ទៃរឿង ដោយតម្រូវឱ្យនាង **សុខ សុខុម** ច្រៀងវិញ គឺបទ "**ព្រះគុណម៉ែ**" ។...

# ស្នេហ៍អក្ខរា ចំប៉ាបាណន់

| **បងគ្រូចងទំនុកច្រៀង** | **សម្រួលតន្ត្រី** | **ច្រៀងដោយ** |
|---|---|---|
| **គន្ធ ប៊ុនឈឿន** | **ម៉ក់ ឈួន** | **ស៊ិន ស៊ីសាមុត** |

១- តេដាក់ឈ្មោះខ្ញុំ នៅភ្នំបាណន់
វាយបណ្តើរដូចចោរប្លន់ ព្រោះស្នេហ៍តូចតន់បណ្តូលដួងចិត្ត
តេវាយដំ បង្ខំចូលទ្រុងលោហិត
រឿងនេះមិនមែនប្រឌិត ជារឿងពិតសែនសោកា ។

២- អូនកូនម្ចាស់ស្រុក បងគុកចាំបឹង
ខួបខែល្អចស្នេហ៍ព្រលឹង ហែកយកស្លាបជ្រឹងសរសេរអក្ខរា
តេងទន្ទឹង រំពឹងរង់ចាំវាសនា
ក្បង់ទឹកបឹងលប់ភ័ក្ត្រា ទឹកថាចំចាំប្រណី ។

R- ការពិត អូនគិតបងដែរ
ទោះអូនជាដួងខែ គង់ស្នេហ៍កូនទន្សាយព្រៃ
អូនបារលិខិត ដួងចិត្តលើស្បៃ
ចងជាប់ទឹងជើងជ្រឹងភក្តី ថាអូនអាល័យប្តីយ៉ាងស្មោះ ។

៣- ចំប៉ាបាណន់ សាយណ្ហបងលា
ថ្ងៃនេះបងព្រាត់ពុំងា យកស្បៃអត្ថាគ្របជាប់ខ្នោះ
ផែនដីនេះ មាសប្រាក់ វណ្ណៈ កេរ្តិ៍ឈ្មោះ
ឯបងគ្មានអ្វីទាំងអស់ មានតែឈ្មោះប៊ីម៉ាត់ទេ ។

SLOW
[illegible] C1B3 B1B1 BB3 I B3B C1C B3C1 - C1C1 C1C4 C1C4 DC1 III
[illegible] DC4 CD C4C1 C4C I AA1 BB1 B3C I B3C4 C1C B3B1 IV
- - - - - - - - - - - - - - - - - - - - - - - - - - - C4C1 CB1 B3B IV
R- AA1 BB1 B3C1 I C4 C1C4 C1C I C1B3 CB1 BA1 IV
B3C1 B3C1 B3C C1B1 - CB3 B1B3 B1 BA1 - AA1 BB1 CB3 B3B3 IV
III/.- - - - - - - - - - - ( ដូច 2° Couplet ) - - - - - - - - - IV

# ព្រះគុណម៉ែ

| បទភ្លេងនិពន្ធប្រែប្រួល | សម្រួលតន្ត្រី | ច្រៀងដោយ |
| --- | --- | --- |
| គង្គ-ប៊ុនឈឿន | យិន-ឌីកាន | សុខ-សុខុម |

(បទនេះ ទោះបីទើបតែងទំនុកថ្មី សំរាប់ដាក់បញ្ចូលក្នុងរឿងវីដេអូ "ព្រះគុណម៉ែ" ដែលមានលំនាំដូចរឿង "អារសាច់ជូនម្តាយ" និងទើបថតនៅឆ្នាំ 1989 ក្តី តែ Melodie របស់បទនេះជា Melodie របស់បទដើម ស្បៃអត្ថា ចំប៉ាបាណន់ ពីឆ្នាំ 1975 )

១- សូមក្រាបលាបង ផ្សងទៅតាមម្តាយ
បងអើយទោះអូនឃ្លាតឆ្ងាយ ក៏ឃ្លាតតែកាយ ចិត្តចងចាំនៅ
មើលមុខអូនឱ្យច្បាស់ ណាំប្រុសពាលពៅ
ព្រោះអូនឃ្លាតពីបងទៅ គ្មានពេលវិលជួបកល្យាណ ។
២- គុណនិងកិត្តិយស ពាំងជ្រោះវណ្ណៈ
ទោះបីរូបប្តីស្រោបប្រាក់ ពេលនេះជឿជាក់មិនអាចស្នេហ៍បាន

ព្រះគុណម្ដាយ ថ្លៃជាងត្បូងពេជ្រវិមាន
ឱ្យអូនចោលគាត់ម្ដេចបាន កល្យាណកុំខឹងនឹងស្រី ។

R- តើបងឬអូនត្រូវយំ ?
រឿងអកព្រាត់ទ្រនំ ស្រែកយំមួយម៉ឺនអាល័យ
ឆាកល្ខោនជីវិត ឥតប្រណី
បិទភ្នែកសត្វលោកឱ្យរីងរៃ នេះឬលោកីយ៍គ្មានក្ដីស្រណោះ ។

៣- វាលវដ្ដសង្សារ ប្រហារគ្មានក្រែង
ផុតស្នេហ៍ក្នុងភ្លើងគ្មានផ្សែង ទោះយំទោះថ្លែងក៏មិនចេះអស់
លាបងទៅ ទាំងកូនដែលនៅក្នុងពោះ
ថ្ងៃក្រោយបើវានៅរស់ សូមជួយសន្ដោសកូនផង ។

(ផលិតកម្ម ឆពណ្ណរង្សី ភាពយន្ត)

✲ ✲ ✲ ✲ ✲

## សែនស្ដាយផ្កាល់ស្ដាំ

**ប្រវត្តិបើម** - កាលពីឆ្នាំ **1972** ខ្ញុំបានសរសេរប្រលោមលោកមួយ ឈ្មោះថា "**សែនស្ដាយផ្កាល់ស្ដាំ**" ដែលពណ៌នាតាមជីវិតស្នេហាពិតរបស់យុវជនម្នាក់ ឈ្មោះ **សុខ-បណ្ឌិត** ។

យុវជននេះ បានទៅជួបខ្ញុំដល់ផ្ទះ ហើយត្អូញត្អែរពីខ្សែជីវិតអភ័ព្វរបស់គេ ដោយសំណូ[illegible]សំណូមពរទៀត ឱ្យខ្ញុំជួយសរសេររឿងគេ ព្រោះគេមានការឈឺចាប់[illegible] ដែលគេស្រឡាញ់នោះ ។

បើតាម[illegible]ឱប ដែលយុវជននោះបាននិយាយប្រាប់ ឃើញថា គួរឱ្យអាណិតណាស់ ព្រោះសង្សារដែលគេស្រឡាញ់ពេញចិត្ត ដែលបានសច្ចាថាស្មោះត្រង់ជាមួយគ្នា បែរជាត្រូវប្រេះឆាបាក់បែក ដោយសារតែរឿងចាស់ទុំ

ទៅវិញ ។

ដោយហេតុនេះហើយ ទើបខ្ញុំយល់ថា ប្រវត្តិស្នេហានេះ គួរតែរចនាជាប្រលោមលោក ដើម្បីឱ្យយុវជនទូទៅបានដឹងដែរ ប៉ុន្តែខ្ញុំបានបញ្ជាក់ថា "នៅពេលបោះពុម្ពរឿងនេះចេញទៅ អ្នកឯងត្រូវតែហ៊ានទទួលខុសត្រូវចំពោះវិបត្តិផ្សេងៗ ព្រោះវាមិនមែនជារឿងម្នាក់ឯងនោះទេ !..." ។

**សុខ-បណ្ឌិត** ឆ្លើយអះអាងថា បើមានហេតុការណ៍អ្វីគេទទួលខុសត្រូវទៅមុខ ព្រោះរឿងនេះជារឿងពិត ហើយសង្សារគេនាងក៏ចង់ឱ្យសរសេររឿងនេះដែរ ។ ខ្ញុំក៏សំរេចចិត្តសរសេររឿងនេះ ដោយដាក់ចំណងជើងថា "**សែនស្តាយផ្កាល់ស្តាំ**" តែប្រើក្របក្រៅជារូបគំនូរ ឈ្មោះតួក៏ដូរផ្សេង និងបានតែងបទ សែនស្តាយផ្កាល់ស្តាំ បញ្ចូលទៅក្នុងរឿងនេះដែរ ។

ក្រោយពេលបោះពុម្ពរួច រឿងក៏ល្បីល្បាញខ្ទរខ្ទារ ព្រោះមានចំរៀងពិរោះ ប៉ុន្តែខ្ញុំត្រូវមានរឿងក្តី ដោយត្រូវគ្រួសារខាងសង្សារ **សុខ-បណ្ឌិត** ប្តឹងឡើងតុលាការ ។ ខ្ញុំភ្ញាក់ផ្អើលពេលនោះ ព្រោះ**សុខ-បណ្ឌិត**បានគេចមុខបាត់រកមិនឃើញសោះ ។

តាមពាក្យបណ្តឹង គឺគេចោទថាខ្ញុំបរិហារកេរ្តិ៍កូនក្រមុំនិងគ្រួសារគេ ហើយប្តឹងទារជំងឺចិត្តពីរលានរៀល នាសម័យនោះ ។ ប៉ុន្តែពេលឆ្លើយនៅចំពោះមុខតុលាការ ខ្ញុំបានរួចខ្លួនទាំងអស់ ដោយសាររូបក្របក្រៅ មិនមែនរូបថតពិត ឯឈ្មោះតួអង្គក៏ប្រឌិតទាំងអស់ដែរ ហើយមិនបានបញ្ជាក់ថាសរសេរតាមគំនិតរបស់យុវជនសុខបណ្ឌិតនោះទេ គឺសរសេរតាមគំនិតវោហារបស់ខ្ញុំទាំងស្រុង ។

ទោះបីខ្ញុំមានជោគជ័យនៅតុលាការក៏ដោយ ក៏គួរឱ្យប្រហោងពោះដែរ ហើយក៏ជាមេរៀនមួយសម្រាប់ថ្ងៃក្រោយ ខ្ញុំលែងហ៊ានទទួលរឿងពិតរបៀបនេះមកសរសេរទៀតហើយ ។ សូមបញ្ជាក់ថា នៅសម័យនោះ មានគេចូលចិត្តយករឿងពិតមកឱ្យខ្ញុំសរសេរណាស់ ខ្លះជួលទាំងខ្ញុំឱ្យសរសេររឿងគេទៀតផង

ព្រោះគេឃើញខ្ញុំកាលសរសេររឿង "**ពលនោរអភ័ព្វ**" របស់**អាប់ឌុលសារី** នោះលក់ដាច់ខ្លាំងពេក ។ សមពេលនោះសង្គមយើងច្របូកច្របល់ ម្នាក់ៗសុទ្ធតែមានរឿងឈឺចាប់ផ្ទាល់ខ្លួន ចង់តែទម្លាយប្រាប់អ្នកដទៃឱ្យដឹង ។...

# សែនស្តាយថ្កាល់ស្តាំ

| | | |
|---|---|---|
| **បទភ្លេងនិងទំនុកច្រៀង** | **សម្រួលតន្ត្រី** | **ច្រៀងដោយ** |
| **គង្គ-ប៊ុនឈឿន** | **មែរ-ប៊ុន** | **ស៊ិន-ស៊ីសាមុត** |

១- ចាស់ទុំ ចូលស្តីស្រីអូនប្រកែក
ទីបស្នេហ៍រហែក បេះដូងប្រេះបែកព្រែកព្រាត់គង្គា
បង្អួងព្រាត់សេក មេឃព្រាត់ចំន្រ្ទា
សិង្ហពាក់ស្បែកលា ឥសីក្លាយជាអ្នកសង្គ្រាមជ័យ ។

២- បងកាត់ទងស្លូត ដោតទង់ក្រពើ
ថ្កាល់ស្តាំថ្កាល់លើ- មន្តស្នេហ៍ព្រៃឈើក្នុងខួមនិស្ស័យ
ពេលបងរៀបការ ទើបថាអាល័យ
ចោទទាំងគ្មានន័យ ថាបងប្រល័យស្នេហ៍អូនគ្មានស្តាយ ។

R- ហួសហើយ ! ហួសហើយ !.. ព្រលឹង
ថ្កាល់ធ្លាប់ក្រេបក្រោមជ្រៃមាត់បឹង
មិនអាច ថ្លឹងស្មើពាក្យម្តាយ
ផ្ទូរស្នេហ៍ ដែលសាងទុកកប់រូបកាយ
បងនិងឆោមឆាយ ឥឡូវប្រែក្លាយជាផ្នូរអប្រិយ៍ ។

៣- បងសែនរន្ធត់ ចង់ផុតរោងការ
វិលរកជីវ៉ា ក្រេបរសស្នេហាថ្កាល់ស្តាំជាថ្មី
តែទាស់មនុស្សយើង គេយកសំដី
បងសូមលាស្រី រៀបការក្នុងន័យកិត្តិយសត្រកូល ។

**BLUE**

I/. BB4 C0C2 C4C0 CB4 I C0C B4B3 I C0C B4B3 B4C0 C2C4 IV
BB4 C0C2 C4B4 C0C2 I C4C2 C0C I B4B3 B4C2 I C0C IV

II/. - - - - - - - - - - - - - - - - - - C4C2 C0C I B4B3 B4C2 C0C BB4 IV

R- BB4 CC1 C4C1 I B4 CC1 CC1 C2C4 I BC4 C2C0 CB4 IV
B4C2 I B4C B4C C0C2 I C4 D0B4 C0C2 - C4B4 C4C2 C0B C0C IV

III/. - - - - - - - - - - - - - ( ដូច $2^0$ Couplet ) - - - - - - - - - - - - - IV

(ផលិតកម្មពស់មាស)

❄ ❄ ❄ ❄ ❄

# ប្រទីបនៃធម៌

| បទភ្លេងទំនុកច្រៀង | សម្រួលតន្ត្រី | ច្រៀងដោយ |
|---|---|---|
| គន្ធ.ប៊ុនឈឿន | កែវ.វែម | តូច.តេង |

(បទនេះនិពន្ធនិងផតផ្សាយនៅក្នុងវិទ្យុជាតិពីឆ្នាំ 1967 ឯ Melodie ខ្ញុំបានយក មកច្នៃប្ដូរទំនុកដាក់ជាបទ សែនស្ដាយផ្កាល់ស្ពាំ នៅឆ្នាំ 1972 )

១- កណ្ដាលសាសនា បានវិលមកដល់
ឃើញមនុស្សអំពល់ វិលវល់សាងបាបគួរវេទនា
ខ្វះខាតគុណធម៌ ភ្លេចភ្នាំងកាយា
នេះគឺមាគ៌ា នាំយើងរាល់គ្នា ជួបទុក្ខ ។

២- អ្នកដែលធ្វើល្អ ហាក់ដូចមានមារ
មកតាមផ្ដន្ទា ឱ្យយល់ទោសាតបគុណនិងសុខ
ប្រៀបដូចទេវតា ជួយខ្លាពីភក់
ឱ្យផុតក្ដីទុក្ខ ផលតបនឹងសុខគឺនេរគុណ ។

R- សិស្សល្អ ក៏ព្រោះមានគ្រូ
កូនល្អគលាស់ ព្រោះម្ដាយខំស៊ូ

ថៃទាំទ្រាំនៅអត់ធន់
ហេតុនេះគួរខំរក្សាជីពជន្ម
ហើយឆឹងជាមុន ទូវបាបទូវបុណ្យគុណទោសទាំងឡាយ ។
៣- ដើម្បីរំលត់ ការបង្ហូរឈាម
បំបាត់សង្គ្រាម គួរយើងដើរតាមព្រះពុទ្ធគ្រួសគ្រាយ
រំលត់លោភៈទោសៈញាប់ញ័រ ពីចិត្តនិងកាយ
នោះទើបសប្បាយក្នុងសន្តិភាព ។

( ចង្វាក់ BLUE )

★ ★ ★ ★ ★

## ជួបតែគ្រា ជួបស្នេហ៍

**ប្រវត្តិបើច** - បទនេះ ខ្ញុំនិពន្ធនិងថតនៅក្នុងឆ្នាំ 1973 សំរាប់បញ្ចូលក្នុងខ្សែភាពយន្ត រឿង "**មាន់ខោចពីរជេខ មខនៅរកអូន**" របស់ផលិតកម្មលោក **យិន-ឃឿន** ហៅ **គ្រត់ជី** ។

ពេលតែងបទនេះ ខ្ញុំមានជំងឺ Surmenace ខ្វះឈាម ខ្សោយបេះដូង មិនអាចចេញទៅធ្វើការនៅក្រៅផ្ទះបានឡើយ ព្រោះចេះតែវិលមុខ ។ ខ្ញុំនៅសំរាកព្យាបាលនិងធ្វើការក្នុងផ្ទះ អស់រយៈជាច្រើនខែ ឯការទំនាក់ទំនងនៅខាងក្រៅ ខ្ញុំបានប្រគល់ភារៈកិច្ចឱ្យប្រពន្ធខ្ញុំ ជាអ្នកចាត់ចែងជំនួសទាំងអស់ ។

ដូចជាការថតបទនេះជាដើម គឺប្រពន្ធខ្ញុំបានសំរេចឱ្យលោក **ស៊ីនស៊ីសាមុត** ច្រៀងជាមួយអ្នកនាង **រស់សេរីសុទ្ធា** ប៉ុន្តែនៅពេលដល់ថ្ងៃកំណត់ថត លោក **ស៊ីនស៊ីសាមុត** មានទុក្ខធុរៈដ៏ធ្ងន់ធ្ងរ ដោយសារប្រពន្ធលោកមានជំងឺ ត្រូវនាំទៅមន្ទីរពេទ្យ លោកក៏អាក់ខានមិនបានមកច្រៀង នៅពេលដែលប្រពន្ធខ្ញុំទៅហៅដល់ផ្ទះនោះ ។

ដោយពេលវេលាកំណត់ថត មិនអាចពន្យាទៅថ្ងៃមុខទៀតបាន ប្រពន្ធខ្ញុំក៏សំរេចប្តូរអ្នកចំរៀង ដោយយកលោក **អ៊ីុច-ណារី** ច្រៀងជាមួយនាង **រស់-សេរីសុទ្ធា** វិញ ។

ចំពោះលោក **អ៊ីុច-ណារី** ពិតមែនតែជាអ្នកចំរៀងស្រករក្រោយពីលោក **ស៊ីន-ស៊ីសាមុត** តែគ្រប់មជ្ឈដ្ឋានអ្នកស្តាប់ បានវាយតំលៃថា សម្លេងលោកមានទឹកដមពិសេសណាស់ ហើយអាចជំនួសលោក **ស៊ីនស៊ីសាមុត** បានមួយផងមួយកាលដែរ ។

ទោះបីយ៉ាងនេះក្តី ក៏លោក**អ៊ីុច-ណារី** មិនដែលជោរអំនួត និងមោទនភាពចំពោះទេពកោសល្យរបស់លោកឡើយ លោកនៅតែគោរពលោក **ស៊ីនស៊ីសាមុត** ជាគ្រូនិងជាគំរូមច្បង ហើយដាក់ខ្លួនរៀនសូត្ររបៀបច្រៀង តាមសិល្បករឯកនេះជានិច្ច ។

លោក **អ៊ីុច-ណារី** បានស្លាប់ទៅមែន តែកិត្តិស័ព្ទជាអ្នកចំរៀងរបស់លោកនៅតែល្បីល្បាញខ្ទរខ្ទារមិនចេះសាបសូន្យឡើយ... ។

# ជួបគ៉ាំគ្រ ជួបស្នេហ៍

| | | |
|---|---|---|
| **បទភ្លេងនិពន្ធច្រៀង** | **សម្រួលតន្ត្រី** | **ច្រៀងដោយ** |
| **គង្គ-ប៊ុនឈឿន** | **ហាស់-សាឡុន** | **អ៊ីុច-ណារី រស់-សេរីសុទ្ធា** |

INTRO ស- និសម្លេងខ្ញុំយពិរោះមែន ! ទ្រូងខ្ញុំអួលណែនសែនខ្លោចផ្សា
តើម្ចាស់ខ្ញុំយនោះជាអ្នកណា ចង់ស្គាល់ភក្ត្រាដូចម្តេចទៅ ?

១.ប- ចង់ឃើញ ចង់ស្គាល់បងមកដល់ហើយ
និស្រស់ត្រាណត្រើយ កន្ថើយដល់ណាទៀតពៅ ?

ស- ថយចេញសិនកុំមកពាំងផ្លូវ យើងទាំងពីរធ្លាប់មានអាស្រូវ

ប- ឆោមឆ្នៅកុំទឹករៀងរើម ។

២.ស- ប្រុសហើយនឹងស្រី មិនត្រូវបាត់ខ្លួន

ប- ខុសទេពុំងា ប្អូនថាត្រូវការសន្សើម
ដួចរូបបងត្រូវការស្រីឆ្នើម គ្មានរូបអូនគឺគ្មានជង្រើម
គ្មានទាំងសន្សើមដួងថៃ ។

R.ស- ប្រុសខិល រអិលមាត់ដូចលាបខ្លាញ់
គួរឱ្យខ្លាញ់ ខ្លាញ់ ខ្លាញ់ ជាប់ក្នុងហឫទ័យ

ប- បងសូមយកខ្ញុំធ្វើជាសាក្សី លុះត្រាដេកដី ស្ម័គ្រស្រីជានិច្ច ។

៣.ស- បើស្ម័គ្រត្រូវស្មោះ បងកុំដោះដៃ

ប- ស្ម័គ្រអូនលុះក្ស័យ រាល់ថ្ងៃគ្មានប្រែគេច អោនថ្លាល់មកបងសូម

បន្តិច សូមក្រេបក្លិនមាសឆ្អិនដូចពេជ្រ បំភ្លេចរឿងចាស់អាស្រូវ។

R.ស- កុំទាន់ប៉ះពាល់ណាំពៅមាសឆ្អិន ថយចេញសិន
ព្រោះអូនមានម៉ែមានឪ

ប- យើងធ្លាប់ស្គាល់គ្នាយូរមកហើយពៅ ចុះម្តេចឥឡូវពាលពៅដោះដៃ

៤.ស- អូននឹកឃើញហើយអនុស្សាវរីយ៍ [illegible]យើងទាំងពីរប្រលងចំរៀង
អាយ៉ៃ អូនចាញ់បង បង[illegible] (ម) បើនឹកឃើញអូនកុំសង្ស័យ
ចាប់ដៃគ្នាសាងវាសនា

ប+ស- ចាប់ដៃគ្នាសាងវាសនា ! ចាប់ដៃគ្នាសាងវាសនា...

**BLUE - FOLK**

I/. C4C4 C2C1 CC1 C2C4 II C2D0 DC4 I CC2 C4C2 C1C III
C4 I C2D C4C2 C1C - B3 BC1 C4C1 CB3 I BB1 CB4 B3B1 IV
II/. - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - BB1 CB3 B1B II
R- BC I B4B2 B4B2 B1B II B B2B - C4B4 CC1 C2C4 II
CC4 I C2C C2C B2B4 I CB B2B4 - BB1 B3C1 CB3 IV
III/. - - - - - - - - - - ( ដូច 2° Couplet ) - - - - - - - - - - IV

✪ ✪ ✪ ✪ ✪

# កម្លោះហុងដា កញ្ញាប៉េសេ

បទភ្លេងនំនុកច្រៀង
គន្ធ ប៊ុនឈឿន

សម្រួលតន្ត្រី
ហាស់ សាឡុន

ច្រៀងដោយ
ស៊ិន ស៊ីសាមុត ប៉ែន រ៉ន
ស៊ឹម ឧច តាត សំណាង

(បទនេះនិពន្ធនិងថតនៅឆ្នាំ 1973 ក្រុមហ៊ុន ឡាក់-ស៊ា )

១.ប- កម្លោះហ៊ីហារ ជិះហុងដា មើលស្រីៗ
ផ្ទៃលផ្សារចាស់ ផ្ទៃលផ្សារថ្មី ផ្ទៃលផ្សារស្តូរ ផ្សារអូរឫស្សី
ឃើញស្រីៗជិះប៉េសេ !
ហេឡូ ! អ្នកនាងជិះទៅណា អ្នកនាងមានការឬទំនេរ
ឬទៅលេងមាត់ទន្លេ ឬអ្នកនាងចង់មើលកុនខ្មែរ
មានតែចូលរោងភ្នំពេជ្រ ។

២.ស- ក្រមុំយេយេ ! ជិះប៉េសេភ្ញីរលេច
ផ្ទៃលអា STAR MAJESTIC អាស៊ុរិយា អាម្ពុជពេជ្រ
ហើយគេចទៅអាហោម្ជជាតិ
រោងណាក៏មិនចង់មើលដែរ ចង់មើលតែមនុស្សដើរព្រោងព្រាត
ខ្លះបណ្តើរគ្នាប្រកៀត ខ្លះមុខជួរហ្សញគ្មានរសជាតិ
ហាក់ឃ្លាតឃ្លាពីគូស្នេហ៍ ។

៣.ប+ស-កម្លោះហុងដា និងនាងកញ្ញាប៉េសេ
ជិះឆៀងឆាបមាត់ទន្លេ "ឆ្លើយឆ្លោះផ្លូងប៉ុនប៉ងសូមស្នេហ៍
ដូចសត្វរំពេពេញវ័យ
ស- បើស្នេហ៍សូមចូលដល់ម៉ែឪ កុំស្នេហ៍តាមផ្លូវបណ្តាចរណៃ
ប- សូមកុំព្រួយណាំចរណៃ ថ្វីបើបងជាប្រុសសម័យ
តែកាន់ប្រពៃណីខ្មែរ ។

**BOLERO**

I/. B3B4 B5C **IV** C1 CB3 C C1C **IV**
C1 CB3 C C1C - B3 B1B B1B3 CB1 - B3 B1B A1 BB3 **IV**
BB1 BB2 B2 B1B **IV** BB1 BB2 B1 BC **IV**
C1 CB3 C C1C4 - C1 CB B1B3 CB1 - B3B1 B3A A1B **IV**

II/. ------------ ( ដូច 1° Couplet ) -------

☆ ☆ ☆ ☆ ☆

# ចំរៀងមរណៈ

**ប្រវត្តិបើម** - បទនេះ ខ្ញុំនិពន្ធឡើងនៅក្នុងឆ្នាំ **1973** ដើម្បីឧទ្ទិសដល់មរណៈភាពរបស់មិត្តខ្ញុំម្នាក់ឈ្មោះ **សោម-ថោន** ហៅ **មនោផល** ដែលជាអតីតអ្នកចំរៀងប្រជាប្រិយម្នាក់ដែរ ប៉ុន្តែត្រូវរងគ្រោះគួរឱ្យរន្ធត់ពន់ប្រមាណ ។

ក្រោយរដ្ឋប្រហារ **18** មិនា **1970** លោក **សោម-ថោន** បានលាចាកជីវភាពជាអ្នកចំរៀង និងជាចាងហ្វាងកាសែត សមរភូមិ ហើយបានចូលបំរើក្នុងកងទ័ព នៃកងពលធំលេខ **13** របស់ព្រះអង្គម្ចាស់នរោត្តម ច័ន្ទរង្សី ដែលបោះទីតាំងនៅបន្ទាយច្បារមន ក្នុងខេត្តកំពង់ស្ពឺ ។

ថ្ងៃមួយ ដែលលោកបាននាំប្រពន្ធកូន ជិះឡានចេញពីភ្នំពេញយកលុយទៅបើកឱ្យពលទាហាននៅបន្ទាយច្បារមននោះ ព្រោះលោកជាអ្នកកាន់ខាងលុយកាក់ប្រាក់ខែ ស្រាប់តែមកដល់កន្លែងស្ងាត់មួយ មានពួកឧទ្ទាមចេញមកចាំស្ទាក់ផ្លូវ ហើយបាញ់ចំរុះទៅលើឡានរបស់លោក ដើម្បីប្លន់យកលុយបណ្តាលឱ្យលោកទទួលគ្រោះថ្នាក់ ស្លាប់នៅកណ្តាលផ្លូវគួរឱ្យអនោចអធម៌ក្រៃលែង ។

ពេលនោះ កូនប្រុសតូចរបស់លោក និងប្រពន្ធ បានប្រមៀលខ្លួនទៅពួននៅក្នុងស្នាមភ្លោះ ក្រាបពីក្រោមសាកសពទាហានពីរបីនាក់ទៀត ដែល

ស្លាប់ដែរ នាំឱ្យបាឡូចខ្លួនដោយទឹកដោះម្តាយថ្ងៃ ព្រោះពួកឧទ្ទាមយល់ច្រឡំថា ជនទាំងពីរនេះបានស្លាប់ទៅហើយ ។

នេះជាសោកនាដកម្មមួយ ដែលមិនអាចបំភ្លេចបានឡើយ ។ បីបួនខែក្រោយមក បន្ទាប់ពីមរណភាពរបស់លោក **សោម ថោង** ហៅ **មនោផល** ជាស្វាមី អ្នកស្រី **ច័ន្ទ ស៊ីម៉ុន** ជាភរិយា បានមកសំណូមពរឱ្យខ្ញុំជួយសរសេររឿងពិតរបស់ប្តីនាងនិងរូបនាង ដើម្បីរក្សាទុកអនុស្សាវរីយ៍ដ៏សែនសោកកំសត់នេះ ។ ខ្ញុំក៏បានតាក់តែងជាប្រលោមលោកមួយ ឈ្មោះថា "**រឿងពិតរបស់ខ្ញុំ**" ហើយបានបញ្ចូលចំរៀងពីរបទ ដើម្បីធ្វើឱ្យផ្ទៃរឿងកាន់តែក្តុកក្តួលណាស់ទៅទៀត ។ បទទី១ គឺបទ **ចំរៀងមរណៈ** ដែលអ្នកផងចេះតែច្រឡំថាជាបទ *ខ្វង់ខែកហែកលោក* ហើយនាំគ្នាហៅបែបហ្នឹងរហូតមក ឯបទទី២ គឺបទ **សែនឈឺចិត្ត** ដែលមានប្រជាប្រិយភាពល្បីល្បាញសុះសាយរហូតមកដល់ពេលឥឡូវ ។

ប៉ុន្តែ អ្នកធ្វើចំរៀងកាយវិការ ឬ ការ៉ាអូខេ ដែលមិនបានដឹងរឿងពិតពេលថតមិនបានយករូបភាព មកដាក់ឱ្យត្រូវតាមទំនុកច្រៀងឡើយ គឺចេះតែធ្វើផ្សំ លំៗឱ្យតែបាន ។...

## ចំរៀងមរណៈ

| បទភ្លេងនិងទំនុកច្រៀង | សម្រួលតន្ត្រី | ច្រៀងដោយ |
|---|---|---|
| គង្គ ប៊ុនឈឿន | ហាស់ សាឡន | ស៊ីន ស៊ីសាមុត |

១- ខ្វង់ខែកហែកលោក ទួញសោកស្រណោះ
ស្តាយរូបសម្ផស្ស ស្តាយឈ្មោះជីវ៉ា
ភ្លេងកម្មនាំកាយ ឱ្យឆ្ងាយភ្លេងការ
ឆ្ងាយទាំងបុត្រា ស្នេហាភក្តី ។

២- ស្ទឹងកំពង់ស្ពឺ បងព្ឈួចយំ
អាប្រាតភ្លៀងធំ ម៉ុំភរិយាក្តី

ទំនប់ព្រែកត្នោត ធ្លុះធ្លាយដោតតល់ជ្រៃ
មិនគួរលោកិយ ប្រល័យមនោផល ។

R- ចំរៀងមរណៈ ព្រួញប្រាក់នាយព្រាន
លើកបាញ់បំពាន សុភមង្គល
បាញ់មួយទុកមួយ ឱ្យព្រួយសោកសល់
នឹកឡើងកង្វល់ ខ្វល់តែទឹកភ្នែក ។

៣- រៀបការកំសត់ នៅបាត់ដំបង
ឥឡូវបង្អង់ ជីវិតបាក់បែក
នេះគឺរឿងខ្ញុំ ទ្រទំទឹកភ្នែក
យំប្រាប់ជើងមេឃ រំលែកទុក្ខផង ។

**BLUE**

I/. DD2 C4D I C3C4 D2D IV C4C4 CC3 DC4 - C3C IV
B4B4 - CB1 - CC3 C4C I DD2 C4D C3C4 D2D IV

II/. ------------------- DD2 C4D C3C4 DC IV

R- DD C4D - D2D1 - C4D I C4C4 C3C4 C3D D2D IV
DD2 DD2 DC C3C4 I DD C2C2 C1C B1B4 IV

III/. ------------- ( ដូច $2^0$ Couplet ) --------- IV

☆ ☆ ☆ ☆ ☆

## ប្រពន្ធខាំញិច

បទភ្លេងធំនុកច្រៀង សម្រួលតន្ត្រី ច្រៀងដោយ
គន្ធ_ម៉ិនឈឿន ម៉ក់_ឈួន ស៊ីន_ស៊ីសាមុត ស៊ុម_ឆុម
(បទនេះនិពន្ធនិងថតនៅវាំងឆ្នាំ 1971 [illegible] រហូតមកដល់ សព្វថ្ងៃនេះ)

១.ប- ថ្ងៃនេះពិសេសអស្ចារ្យ ចូលផ្ទះកាលណាប្រពន្ធខាំញិច

ខ្វេះខ្វាំ ទាញខាំអា **MIXE** ខ្វេះខ្វាំ ទាញខាំអា **MIXE**
ខ្ញុំខំរត់គេចខ្លាចវា **DANGEREUX** ។

២.ប- ក្លូនទាស្រែកយំដូចហ៊ឹង ខ្វះលោតដាំទឹង ខ្វះទៀតឡើកី
ប្រពន្ធជាន់ខ្ញុំពីលើ ប្រពន្ធជាន់ខ្ញុំពីលើ
ខ្ញុំធ្វើភ្នែកស្លឹ ខ្លាចដាច់សាច់សំយ៉ុង ។

R.ប- **Ma Femme, Laissez-moi, Ma Femme**
អូនកុំចិញ្ច្រាំ បងធ្វើ **Jambon**

ស- ឯណាទាឡើកា **Roton**
បងយកចូលកុង ឬឲ្យស្រីញី ? ។

៣.ប- ទេ ! ទេ ! ចោរឆក់ទេតើ ពេលដែលបងដើរ **après-midi**
បងស្មោះនឹងឆោមឆាវ បងស្មោះនិងឆោមឆាវ
បងគ្មានស្រីញី ទេណាកែវព្រលឹង ។

**RAM VONG**

I/. BB4 CC1 DC4 - DC4 C1C - C1C B4B1 II
B4B4 CB4 B1B I B4B4 CB4 B1B4 - B4CCC - C1 B4C1 CC II
II/. - - - - - - - - - - - - - - - - - - - - - - - - - - B4C CC - C B4C1 CB4 II
R- CC - C1 B4C I CC - C1C B4C B4C C1C4 II
C1C1 C1 C4C1 CB4 I B4B1 B4C - B4C C4C1 II
III/. - - - - - - - - - ( ដូច 2⁰ Couplet ) - - - - - - - - - II

* * * * *

# សែនឈឺចិត្ត

| | | |
|---|---|---|
| **បទភ្លេងនិពន្ធទំនុកច្រៀង** | **សម្រួលតន្ត្រី** | **ច្រៀងដោយ** |
| **គន្ធ ម៉ិនឈឿន** | **ហាស់ សារុន** | **រស់ សេរីសុទ្ធា** |

(បទនេះនិពន្ធនិងថតជាមួយគ្នានឹងបទ ចំរៀងមរណៈ ដកស្រង់ចេញពី ប្រលោមលោក "រឿងពិតរបស់ខ្ញុំ" ដែលរៀបរាប់ពីឆាកជីវិតកំសត់របស់ លោក សោម-ថោង ហៅ មនោផល និងនាង ច័ន្ទ ស៊ីម៉ុន សព្វថ្ងៃរស់ នៅសហរដ្ឋអាមេរិក)

១- ម្តាយក្មេកមកលេង បងក្មែងថាជាប់បង់គេ
គ្មានពេលទំនេរ នឹងនៅជួបនិយាយលេង
ស្រាប់តែទៅជិះ ស៊ីក្លូជាមួយស្រីផ្សេង
ហើយឆ្លើយបង្វែង ថាប្រពន្ធចុងចៅហ្វាយ ។

២- កាលនៅក្រក្រី ប្តីស្មោះតែនឹងមាន់ស្រែ
ឥឡូវបងប្រែ ទៅស្នេហ៍នាងហង្សឆើតឆាយ
នាំមកបញ្ឆី ឱ្យឈឺផ្សាក្តៅក្រហាយ
ទាំងកូនទាំងម្តាយ ទ្រូងសែនឈឺចាប់ក្រំឈាម ។

R- អូនដាក់កូនចោល កូនស្រែកទ្រហោរ
រត់ដេញស៊ីក្លូ ទាំងទឹកភ្នែកហូររហាម
បងធ្វើព្រងើយ កៀកស្រីត្រេកកាម
ម្តាយខ្ញុំប្រឹងហាម ស្មានថាខ្ញុំវិលស្មារតី ។

៣- នាងបដាចារ រងគ្រោះព្រោះខ្វែងឆក់កូន
រីឯរូបអូន ចំបែងព្រោះខ្វែងឆក់ប្តី
ខ្ញុំយំអោបកូន ប្រុសស្ងួនអោបថើបស្រីថ្មី
ទាត់មួយរាត្រី រូបស្រីស្ទើរក្ស័យសង្ខារ ។

**BOLERO - LENT**

I/. C1C1 D1D1 I C1D1 C1C4 C1C1 I C1C1 D1D1 I C1D1 C1C4 DD II
DC3 C1C I CC1 B3C B3B3 II C4D D1C1 I D1D1 DD1 C4D II
II/. ------------------------------ DC3 C1C3 CC1 II
R- C1C1C1C1 I C1C4 - C1C1 II C1C1C1C1 I C4C1 C4D D1D1 II
D1D C4D I D1D C1C1 I CC1 CB3 I CB3 B1B B1B3 II
III/.------------ ( ដូច $2^0$ Couplet ) ----------- II

* * * * *

# ស្នាមក្រេមជាប់ថ្ពាល់

| បទភ្លេងនិងទំនុកច្រៀង | សម្រួលតន្ត្រី | ច្រៀងដោយ |
|---|---|---|
| គន្ធ.ម៉ុនឈឿន | ហាស់.សាឡុន | ស៊ីន.ស៊ីសាមុត ប៉ែន.រ៉ន |

(បទនេះនិពន្ធនិងថតនៅក្នុងឆ្នាំ 1973 នៅក្នុងកម្រងកាសែត កម្មោះ ហុងងា កញ្ញាប៉េសេ)

១.ស- បងឯងទើបមកពីណា មុខមាត់ដូចឆ្មា ឬមកពីវិឡាជី ?
បងឯងទើបមកពីណា មុខមាត់ដូចឆ្មា ឬមកពីវិឡាជី ?
ប- បងទើបវិលមកពីផ្សារ ទៅទិញតៅកឺ
មកធ្វើកម្មករ នឿយហត់ ។
២.ស- ចេះឆ្លើយបែបហ្នឹងទៅរួច ការពិតបងលួច ទៅមានស្រីញីស្ងាត់។
ចេះឆ្លើយបែបហ្នឹងទៅរួច ការពិតបងលួច ទៅមានស្រីញីស្ងាត់។
ប- បងទើបមកពីមើលភ្លេង ប៉េះក្រូចពោធិសាត់
នឿយហត់ណាស់កែវព្រលឹង ។
R.ស- ស្នាមក្រេមជាប់ថ្ពាល់
នេះជាបន្ទាល់ ថាបងស្នេហ៍ស្និទស្រីផ្សេង
ក្លិនទឹកអប់ប្លែក ស្មានខ្ញុំមិនដឹង

ប- ខុសទេព្រលឹង ក្និនហ្នឹងក្និនភ្លេចទេថ្ងៃ ។

៣.ស- ឆ្នាំមុនលក់ភ្លេចអស់ហើយ ព្រះម្ចាស់ថ្លៃហើយ បងបែរជាទៅមានស្រី
ឆ្នាំមុនលក់ភ្លេចអស់ហើយ ព្រះម្ចាស់ថ្លៃហើយ បងបែរជាទៅមានស្រី

ប- ឆ្នាំមុនបងខុសម្ដងមែន ឆ្នាំនេះកុំភ័យ
បងលៃទិញពេជ្រឱ្យអូន !... ។

**SARAVANN**

I/. DD1 DD1 C3D **II** DC3 C1C - C1C C1C B3B1 **IV**
DD1 DD1 C3D **II** DC3 C1C - C1C C1C B3B1 **IV**
B1B3 CB1 CB3 **I** B1B3 CC1 - CC1 C3D1 C3D **IV**
II/.---------------------- C3C1 CB3 B1C **IV**
R- CB3 B1B3 **I** A3B1 B3C **I** C3C3 DD D1C3 **II**
C3D D1B3 CC3 DC1 **I** CC3 DC1 - C4C1 CB3 CB1 **IV**
III/.------------- ( ដូច $2^0$ Couplet ) --------- **IV**

* * * * *

## ស្នេក ! អូនលាបងហើយ !

**បទភ្លេងនិពន្ធកម្រៀង** **សម្រួលតន្ត្រី** **ច្រៀងដោយ**
**គន្ធ-ប៊ុនឈឿន** **ម៉ក់-ឈួន** **ម៉ែន-រ៉ន**

(បទនេះនិពន្ធនិងថតនៅឆ្នាំ 1974 នៅក្នុងកម្រងកាសែ្សត សៀមអប្សរា ចំចាំចាណន់)

១- ផ្កាយក្រពើ រះលើខ្នមស្រែ
សម្លេងទ្រខ្មែរ ក្រោមខែរនោចខ្មោចផ្សា
ស្នែកអូនលាហើយ លាហើយ លាព្រៃភ្នំខ្វា
លាទាំងជ្រោះពេជ្រចិន្តា ខ្មោចផ្សាជាងនាងកង្រី ។

២- លាភ្នំក្ដោង ធ្លាប់ឈោងបេះផ្កា

ភ្នំទ្រុងមាន់ទា តាម៉ែន តាគត់ តាគ្រែ
ស្វែកអូនណាហើយ ត្រពាំងដែលធ្លាប់ស្ទូចត្រី
លាអក្ខរាចារថ្មីៗ សាក្សីជាប់ដើមរុក្ខា ។

R- ស្នូរយន្តហោះ ទ្រគោះឱ្យទឹកភ្នែកខ្ញុំ
ដែលឈឺក្តៅថ្ពុំ បេះដូងក្រមុំចំការ
ស្ពាយវាលធំវែង កន្លែងដែលធ្លាប់ចរចារ
ក្រោមម្លប់រុក្ខា គេសាជ្រលក់ផងអូរ ។

៣- អូនព្រាត់នេះ ទាំងប្រេះឱរា
ព្រោះតែមាតា ប្រាថ្នាកិត្តិយសថ្លៃថ្នូរ
អក្ខរាលាបង អូនធ្វើនឹងក្មេងឃ្វាលគោ
បើសិនយើងពិតជាគូ ព្រាត់យូរឆាប់គង់ជួបវិញ ។

**BLUE**

I/. B1 BA1 BB1 BB4 II C1C4 C4C4 I DC4 C1C B4C1 II
C1C4 DD I C4C1 CB4 C1C - B4 B1B4 B1 BB1 I BB1 B4B1 A1B IV
II/. - - - - - - - - - - - - - - - - - - - - - - - B4 B1B4 B1 BB1 I B4C C1C B1B4 II
R- CCC - C1C C4C1 C1C1 II C1C4 C4C4 - DC4 C1C B4B1 II
B4B1 B4B I B1B A1B B1B4 I C1C4 I DB1 I B4C4 C1C B4C IV
III/.- - - - - - - - - - - - - - - - - ( ដូច $2^{0}$ Couplet ) - - - - - - - - - - IV

* * * * *

## អូរជ្រៅ រណ្ដៅស្នេហ៍ចាស់

| បទភ្លេងទំនុកច្រៀង | សម្រួលតន្ត្រី | ច្រៀងដោយ |
|---|---|---|
| គង្គ ប៊ុនឈឿន | ហាស់ សាឡុន | រស់ សេរីសុទ្ធា |

(បទនេះនិពន្ធនិងថតនៅឆ្នាំ 1973 ក្នុងកម្រងកាសែត កម្ពោះហុងដា កញ្ញាប៉េសេ)

១- ទឹកហើញទេពៅ អូរជ្រៅរណ្ដៅស្នេហ៍ចាស់
អូនឈឺចុកណែន ព្រោះតែរូបបង

ដោះដៃប្រែខ្លួង ទៅមានគូថ្មី ។

២- កាលអូននិងបង យើងឆ្លងទៅលេងស្រុកថៃ
មាត់អូរត្រជាក់ ក្រោមម្លប់ឫស្សី
ស្តាប់សម្លេងរៃ បំភ្លេចំរៀង ។

R- តើអូនខុសអី បានជាប្រុសថ្លៃ បំភ្លេចអូនចោល
ភ្លេចទាំងស្រមោល ស្នេហាស្រស់ខ្ចី ក្នុងរាត្រីភ្លៀង
ឬមួយបងខឹង ព្រោះអូនឡើងច្រៀង
កាលបុណ្យជប់លៀង ពួកជាងរថភ្លើង ។

៣- កំហុសតូចមួយ ថ្នើមត្រូយមិនគួរលើកឡើង
អូនសែនអាក់អួល ក្តៅឈួលដូចភ្លើង
ស្តាយក្តិនស្នេហ៍យើង មិនគួររលាយ ។

**FOX**

I/. B3C C1B3 B1B BB1 B2B3 II
B3B1 B3C II B3B1 BA1 II
B1B A1B II A4A1 AA1 II

II/. B1B A1B II AA1 AA4 II

R- B3C CC C1C B3C1 C1C B3C II B3B3 B3B3 C1C B3C B3B B1B3 II
CCCC II B3B1 BA1 II B1B A1A II AA1 AA4 II

III/.- - - - - - - - - - - - ( ដូច $2^{0}$ Couplet ) - - - - - - - - - - II

* * * * *

## សម្លេងចាប ប្រាប់ស្នេហ៍មាស់

**ប្រវត្តិបើច** - បទនេះ ខ្ញុំនិពន្ធនិងថតនៅអំឡុងឆ្នាំ 1972 ដើម្បីរំលឹកដល់អនុស្សាវរីយ៍ កាលខ្ញុំនៅពីក្មេង ដែលរស់នៅក្នុងភូមិចំការសំរោង ។

ខ្ញុំនៅចាំបានថា ពេលដែលម្តាយខ្ញុំមិនទាន់ស្លាប់ គាត់តែងតែដើរបេះបន្លែ

បង្កានៅក្បែរផ្ទះ យកទៅលក់ដើម្បីចិញ្ចឹមខ្ញុំ ព្រោះពេលនោះខ្ញុំនៅរៀន ។ តែខ្ញុំក៏មិនដែលទំនេរដែរ ពេលណារួចរាល់ការងារពីការរៀនសូត្រ ឬទៅជួយដងទឹកស្រោចដើមក្រូចឱ្យគេរាល់ថ្ងៃព្រហស្បតិ៍និងថ្ងៃអាទិត្យ ខ្ញុំតែងតែទៅជួយម្ដាយខ្ញុំ ផ្លួចដាំរែកបុនអន្ទែនាំងនោះ យកទៅដាក់រ៉ឺម៉កដឹកទៅលក់នៅឯផ្សារ។

ផ្លូវដែលខ្ញុំរែកបន្លែចុះឡើង និងផ្លូវដែលខ្ញុំតែងដើរទៅរៀន ត្រូវដើរកាត់ខ្ទមឫស្សីមួយជាប់របងផ្ទះ កូនក្រមុំគេម្នាក់ ដែលខ្ញុំបានលួចស្នេហ៍ដោយលាក់កំបាំង ។ យើងទាំងពីរ បានយល់ចិត្តយល់ថ្លើមគ្នាហើយ។យើងតែងតែធ្លាប់ណាត់ជួបគ្នា នៅក្បែរវត្តពោធិវង្សទៀតផង ។

ជាធម្មតា ខ្ញុំតែងតែទៅឃ្លាលគោ នៅក្បែរខ្ទមឫស្សីនោះ ហើយបានជួបនាងជាញឹកញាប់ និងបានផ្លាស់ប្ដូរពាក្យសច្ចាស្បថស្បែទៅវិញទៅមក ថានឹងស្រឡាញ់គ្នាយ៉ាងស្មោះត្រង់ រហូតដល់ទីបំផុត ។

ប៉ុន្តែ ស្នេហានៅក្នុងវ័យសិក្សា ប្រៀបដូចជាពពុះទឹក ឬប្រៀបដូចជាសុបិននៅរដូវប្រាំង... ក្រៀមក្រោះ... ស្រងេះស្រងោច... លន្លង់លន្លោច ។ ការពិត គឺខ្ញុំជាកូនអ្នកក្រ ឯនាងជាកូនអ្នកមាន ធ្វើម្ដេចឡើយឪពុកម្ដាយនាងយល់ព្រមឱ្យនាងមកយកខ្ញុំកើត ។ កម្លាំងស្នេហ៍ ដែលផ្ទុយនឹងក្រិត្យក្រមបេះដូងយុវវ័យនេះ បានធ្វើឱ្យខ្ញុំក្រៀមក្រំ តូចចិត្ត រហូតទាល់តែមានជំងឺទៅដេកពេទ្យ គឺមន្ទីរពេទ្យធំ បាត់ដំបង នៅពេលដែលបានដឹងថា ឪពុកម្ដាយនាងបានអនុញ្ញាតិ ឱ្យកូនអ្នកមានម្នាក់ដែលនៅជិតខាងនោះ ចូលទៅស្ដីដណ្ដឹង ។...

ពុទ្ធោ !... ពន្លកវល្លិស្នេហ៍ ដែលបានថ្ងៃផ្កា ព្រោះខ្ញុំខំដាំ ពេលនេះមានគេបេះយកទៅហើយ !!...

បទនេះ បកស្រាយដោយលោក **អ៊ុច-ណារី** ដែលមានអ្នកស្ដាប់ភាគច្រើនស្មានតែជាសម្លេងរបស់លោក **ស៊ីន-ស៊ីសាមុត**... ហើយទទួលការពេញនិយមរហូតមកដល់សព្វថ្ងៃនេះ... ។

# សម្លេងចាប ប្រាប់ស្នេហ៍ចាស់

| | | |
|---|---|---|
| បទភ្លេងនំនុកច្រៀង | សម្រួលតន្ត្រី | ច្រៀងដោយ |
| គន្ធ៚ម៉ុនឈឿន | ម៉ែរ៚ម៉ុន | អ៊ុំ៚ណារី |

(ដកស្រង់ចេញពីប្រលោមលោករឿង "**ស្នេហាចិត្តមួយ**" )

១- បងគេងចាក់ថ្នាំ នៅក្នុងពេទ្យធំ
ស្ដាប់ចាបវាយំ នៅមាត់បង្អួច
សម្លេងចាបអើយ ឮសូរថ្ងូរថ្ងូច
នឹកកាលបងលួច ស្នេហ៍ស្រីដំបូង ។

២- បងដើរឃ្វាលគោ នៅស្រែផ្ទះស្រី
ស្រែខ្ទមឫស្សី ចំការសំរោង
ពន្ធកវល្លិស្នេហ៍ លួតលាស់វារតោង
បងកាត់បេះដួង ទុកក្នុងទ្រូងស្រី ។

R- បងស្ញុំគ្រអួនស្មោះ តែទាស់ចាស់ៗ
ចិត្តស្រាលប្ដូរផ្លាស់ យកជំនួនថ្មី
ស្រឡាញ់មាសប្រាក់ ជាជាងភក្ដី
រៀបការកូនស្រី ជាមួយដុល្លារ ។

៣- ចំការសំរោង គោងកាចអ៊ីម្ញ៉េះ
បងដាំគេបេះ គ្មានក្ដីមេត្តា
បងល្បួរសៀម គ្រៀមស្នេហា
ខ្លាសអស់បក្សា ចចារចំអក ។

**BLUE**

I/. B1B4 B1C1 CC1 B4C IV B1B3 B4C C1C4 CC1 IV
C1C4 C1C4 C4C1 B4C I B1C1 C4C B4B1 I C4C4 ĐC4 C3C1 IV

II/. - - - - - - - - - - - - - - - - - - - B1C1 C4C B4B1 I C4C4 DC1 C4D IV

R- C1C1 C4C1 I C4C1 C4D I C4D1 DC4 DC4 C3C1 IV
C4C1 - CB4 I B4C1 CC I CB3 B1B - B3B1 BA1 IV
III/. ------------ ( ដូច $2^0$ Couplet ) ------------ - IV

* * * * *

## ទឹកភ្នែកស្រីហូរ

| បទភ្លេងទំនុកច្រៀង | សម្រួលតន្ត្រី | ច្រៀងដោយ |
| --- | --- | --- |
| គង្គ-ប៊ុនឈឿន | ម៉ែរ-ប៊ុន | តូច-តេង |

(បទនេះនិពន្ធនិងថតពីឆ្នាំ 1972 ផ្សាយតាមវិទ្យុជាតិ ដល់ឆ្នាំ 1991 ដាក់បញ្ចូលក្នុងខ្សែវីដេអូរឿង ត្រកួនភ្លេចបឹង ដោយឱ្យលោក ប៉ុន-ចាន់ថន ច្រៀងវិញ)

១- ទឹកភ្នែកស្រីហូរ ប្តូរអ្វីនឹងឈាម
ហូររហាម ស្ទើរក្ស័យជីវិត
ដូចកាត់ដួងចិត្ត ឥតមានមេត្តា
កុំស្រែកកុំយំ ខ្ញុំពុំស្នេហា
ទោសនេះមកពីអ្នកណា
គឺដោយសារ ផៃស្រី ។

R- ង៉ំចៅចាស់ ! ឈឺណាស់មិនទាន់ចាត់ស្នាម
ស្លាប់ចុះ ស្ងួតស្រក់ឈាម
ដែលហូររហាម ជាយូរឆ្នាំហើយ
អញ្ជើញចុះ !... តាមចិត្តអ្នកគិតថាត្រូវ
ខ្ញុំនេះមិនមែនចិត្តខ្មៅ
គោងតែផ្លាស់ផ្លូវ ទៅតាមសំណាង ។

**SLOW**

I/. C4CCB B1B3 CC1 I A1B II B BB1 BB1 BB IV
B3B B3C B3C4 C1C IV B3C B3C B3C C1B3 -
B3B B3C C1C I B1 BB4 I B3B1 II
R- B3C A1B I BB1 BB1 BB I B3C CC1 CC - B1B1 BB1 BB4 B3B1 IV
B3C A1B I BB1 BB1 BB I B3C CC1 CC - B1B1 BB1 BB4 B3B1 IV
( REVISION )

• • • • •

# កូនស្រីអ្នកនេសាទ

**ប្រវត្តិបើច** - ភូមិបាក់ព្រា គឺជាភូមិមួយនៅក្នុងឃុំកោះជីវាំង ស្រុកឯកភ្នំ ខេត្តបាត់ដំបង ។ ជាភូមិចុងកាត់មាត់ញក ឋិតនៅលើផ្លូវទឹក ទៅកាន់ពាមទន្លេសាប ប្រកបដោយទេសភាព ស្រងេះស្រងោចខ្មោចផ្សាពន់ប្រមាណ ។

កាលពីសម័យសង្គមរាស្ត្រនិយម មានទូកដរខ្លះ បានដឹកអ្នកដំណើរតាំងពីភ្នំពេញ រហូតទៅដល់ភូមិបាក់ព្រានេះទៀតផង ដល់ក្រោយមកទើបបានទូកបំពាក់ម៉ាស៊ីន ឬកាណូត ចុះឡើងរហូតទៅដល់ព្រែកទាល់ទន្លេសាប ។

កាលនៅរៀនពីក្មេង ខ្ញុំបានទៅលេងភ្លេង ក្នុងពិធីបុណ្យផ្កាប្រាក់នៅភូមិបាក់ព្រានេះ ហើយបានជាប់ចិត្តនឹងបូផាមួយទង ដែលជាកូនស្រីអ្នកនេសាទនៅតំបន់នោះ ទើបចាប់ផ្ដើមកត់ត្រាទុកក្នុងបេះដូង ទូវបទចំរៀងមួយ ដើម្បីឧទ្ទិសដល់បេះដូងស្រគត់ស្រគំនៃក្រមុំស្រុកទន្លេ ដែលរស់នៅឃ្លាតឆ្ងាយពីអរិយធម៌ នៃអ្នកបីពោក ។

កាលណោះ **Melodie** របស់បទនេះ គ្រាន់តែបានកត់ត្រាទុកនៅក្នុងសៀវភៅកំណត់ហេតុប៉ុណ្ណោះ លុះមកដល់ឆ្នាំ **1974** ទើបខ្ញុំរៀបចំតាក់តែងទំនុកច្រៀងឡើងវិញ ហើយបានថតផ្សាយនៅពេលនោះ ។ បទនេះ បានធ្វើឱ្យភ្ញាក់ផ្អើលដល់បងប្អូនប្រជាជន ដែលរស់នៅតាមតំបន់នោះជាខ្លាំង មិនតែ

ប៉ុណ្ណោះវាក៏ក្លាយទៅជានិមិត្តរូប នៃខ្សែជីវិតពិតៗរបស់កុលាបបងស្ទឹងចាក់ព្រា ដែលខ្ញុំបានពណ៌នា នៅក្នុងរឿងប្រលោមលោកមួយទៀតឈ្មោះ **កូនស្រីអ្នកនេសាទ** ។

នាង **រស់ សេរីសុទ្ធា** ដែលអ្នកផងតែងតែប្រសិទ្ធិនាមថា "**ព្រលឹងស្ទឹងខៀវ**" បាននិយាយប្រាប់ខ្ញុំនៅពេលថតបទនេះចប់ថា នាងច្រៀងបទនេះដោយចិត្តរំភើបញាប់ញ័រពន់ពេកណាស់ ដោយសារអតីតកាលរបស់នាងធ្លាប់រស់នៅតំបន់នោះ និងធ្លាប់មានបេះដូងប្រេះឆាដូចជាបុប្ផាចាក់ព្រានោះដែរ ។

នេះជាបទមួយ ដែលខ្ញុំបានពណ៌នាប្លែកពីគេ គឺបរិយាយពីស្នេហាព្រាត់ប្រាស់នៅលើភូមិដ្ឋានមួយ ដែលមើលទៅឃើញតែលំហទឹកល្ហាចល្ហឹម...ប្រៀបបីដូចជាទន្លេទឹកភ្នែករបស់នារី ដែលមានបេះដូងបរិសុទ្ធចំពោះសង្សារ តែគ្មានអ្នកណាមើលឃើញនូវសេចក្ដីស្មោះត្រង់របស់នាង... ឡើយ ។

បទនេះ អ្នកដែលមិនដឹងចេះតែនាំគ្នាហៅថា "**ខាសនាគូមិនចាក់ព្រា**" ការពិតគឺជាបទ "**កូនស្រីអ្នកនេសាទ**" វិញទេ ! ។

# កូនស្រីអ្នកនេសាទ

| បទភ្លេងដំនុកច្រៀង | សម្រួលតន្ត្រី | ច្រៀងដោយ |
|---|---|---|
| គន្ធ ប៊ុនឈឿន | ម៉ែរ ប៊ុន | រស់ សេរីសុទ្ធា |

១- និគ្មមិចាក់ព្រា នារពេលសូរិយារៀបលិច
រលកព្រេចៗ រំលេចពណ៌ព្រឹសុវណ្ណ
ជំនោររសាត់ មកផាត់នាពេលសាយណ្ហ
ឯនាយផ្កររលាន់ លាន់ឮសែនឆ្ងាយស្រណោះ ។

២- ភូមិអ្នកនេសាទ បណ្ដែតលើផ្ទៃជលសារ
ជំនោរសីហា គត់ត្រារឿងដើមទាំងអស់
កាលបងនិងអូន សាងក្ដីស្នេហាយ៉ាងស្មោះ

ឥឡូវបងបោះ បង់ចោលប្អូនឯកា ។

R- ហេតុតែប្អូន ជាកូនស្រីអ្នកនេសាទ

ជាផ្កាមិនស្អាត ប្រឡាក់ជាប់ក្លិនមច្ឆា

បងឬកបផ្កាហើយ បោះផ្កាចោលក្នុងជលសា

នេះគឺវាសនា ឬជានៅភូមិចាក់ព្រា ។

៣- ចាក់ព្រាព្រែកគ្រប់ បង្អប់រឿងស្នេហ៍អ្នកក្រ

ដូចព្រាហ្មកេសរ ត្រូវប្ដីយកទៅប្រហារ

ចាំតាំងពីព្រាំង រហូតដល់ខែវស្សា

មិនដឹងថ្ងៃណា ទើបប្រុសជីវ៉ាវិលវិញ ។

**BLUE**

I/. B4B4 BB2 B1B A1B I B1B4 II B4B4 CC C4B4 CC1 I C4C4 II
C4C1 C4D C4C1 CB4 I C1C II B4B1 B4C C1C B4B1 I B4B II

II/. ------------------------- B4B1 B4C C1C B4B1 I B4B II

R- BBBB - B4A1 BB1 B4B II B4B4B4B4 - CC1 C4C B4B1 II
CCCC - C1C B4B C4C1 I C1C4 I C1C4 I B4C C1C B4B1 II

III/. ------------ ( ដូច 2° Couplet ) ------------ II

* * * * *

# រាហូចាប់ច័ន្ទ

**ប្រវត្តិបើច** - បទនេះ ខ្ញុំបាននិពន្ធនិងថតនៅអំឡុងឆ្នាំ 1973 សំរាប់បញ្ចូលក្នុងប្រលោមលោកមួយឈ្មោះ **រាហូចាប់ច័ន្ទ** ហើយក៏ត្រៀមថតទៅជាខ្សែភាពយន្តទៀតផង ។ មុននឹងចាប់ផ្ដើមសរសេររឿងនេះ ខ្ញុំបានយកសាច់រឿងសង្ខេប ទៅសុំសេចក្ដីអនុញ្ញាតពីការិយាល័យពត៌មាន នៃក្រសួងឃោសនាការជាតិ ដោយឆ្លងកាត់សមាគមអ្នកភាពយន្តខ្មែរនាសម័យនោះ ហើយបានទទួលលេខតំកល់ទុកតាមច្បាប់ ( **Dépôt légal** ) ដើម្បីរក្សាសិទ្ធិមិនឱ្យអ្នកណាយកចំណងជើងរឿងនេះ ទៅប្រើប្រាស់ក្នុងផ្លូវជំនួញបានទៀតឡើយ ។

បានជាខ្ញុំលើកយករឿងនេះមកនិយាយ ព្រោះកាលណោះ មានចាងហ្វាងផលិតកម្មភាពយន្តមួយ ដែលបានឃើញប្រលោមលោករឿងរាហូចាប់ច័ន្ទចេញផ្សាយទៅមានសន្ទុះខ្លាំងនៅលើទីផ្សារ ក៏បានយកឈ្មោះរឿងនេះ ទៅដាក់ជាចំណងជើងរឿងរបស់[illegible] ។

ពេលនោះ ខ្ញុំបាន[illegible]ៗថា សុំកុំយក ព្រោះឈ្មោះរឿងនេះខ្ញុំបានសុំ **Dépôt légal** រួចហើយ ប៉ុន្តែចាងហ្វាងផលិតកម្មនោះមិនព្រមដោយសំអាងថា ឈ្មោះរាហូចាប់ច័ន្ទជាឈ្មោះបូរាណ អ្នកណាយកទៅធ្វើអ្វីក៏បាន ទើបគេក៏យកចំណងជើងនោះ ទៅដាក់រឿងរបស់គេតាមទំនើងចិត្ត ។ ខ្ញុំក៏បានធ្វើពាក្យប្ដឹងទៅ **Bureau de Presse** នាសម័យនោះ ។ ហើយគេក៏បានកាត់សេចក្ដីឱ្យខ្ញុំឈ្នះ ដោយតម្រូវឱ្យចាងហ្វាងផលិតកម្មនោះ សងជាប្រាក់ជំងឺចិត្តដល់ខ្ញុំទៀតផង ព្រោះច្បាប់បានសំអាងថា ពិតមែនតែពាក្យរាហូចាប់ច័ន្ទនេះ ជាពាក្យពីបូរាណ តែកន្លងមកពុំទាន់មានអ្នកណាទៅសុំច្បាប់រក្សាសិទ្ធិតំកល់ទុកជាផ្លូវការនៅឡើយ ដូច្នេះ អ្វីដែលខ្ញុំបានទៅសុំតំកល់ទុកមុន គឺចំណងជើងនេះពិតជាកម្មសិទ្ធិរបស់ខ្ញុំ មិនអាចមាននរណារំលោភបំពានលួច

យកទៅប្រើប្រាស់បានឡើយ លុះត្រាតែមានការព្រមព្រៀងគ្នាជាទ្វេភាគី ។

នេះ ចង់បញ្ជាក់ថា ច្បាប់ទម្លាប់យើងនាសម័យនោះ មានប្រសិទ្ធិភាពណាស់សំរាប់ការពារសិទ្ធិខាងបញ្ញាពលកម្ម ។ ប៉ុន្តែសម័យបច្ចុប្បន្ននេះ ទោះបីមានច្បាប់ស្តីពីកិច្ចការពារសិទ្ធិខាងនិពន្ធនេះហើយក៏ដោយ ក៏នៅតែមានការលួចបន្លំ រំលោភសិទ្ធិគ្នាទៅវិញទៅមកជាប់ជានិច្ច ។ល។

បទ **រាហូចាប់ច័ន្ទ** នេះ ខ្ញុំបាននិពន្ធទៅតាមលំអានសាច់រឿងប្រលោមលោក គឺតួប្រុសឈ្មោះ**រាហូ** បានផ្សងព្រេងរហូតទៅដល់កោះស៊ូម៉ាត្រា-កោះបាលីនៃប្រទេសឥណ្ឌូណេស៊ី ជួបនឹងកុលាបកោះបាលីនៅទីនោះ ហើយបង្កើតជាបញ្ហាស្មុគ្រស្មាញក្នុងឆាកស្នេហាផ្សងព្រេង... ។

សូមបញ្ជាក់ថា បទ**រាហូចាប់ច័ន្ទ** ឬបទ**លាហើយស៊ូម៉ាត្រា** សុទ្ធតែដកស្រង់ចេញពីរឿងរាហូចាប់ច័ន្ទដូចគ្នា ប៉ុន្តែពេលនេះ ខ្ញុំមិនបានទៅថតផ្ទាល់នៅ Studio ទេ ព្រោះមានជំងឺ គឺប្រគល់ឱ្យប្រពន្ធខ្ញុំជាអ្នកដឹកនាំចាត់ចែងទាំងអស់ ។...

សព្វថ្ងៃ បទទាំងពីរនេះ ត្រូវក្រុមហ៊ុនផលិតចំរៀងកាយវិការ-ការ៉ាអូខេយកទៅថត ប៉ុន្តែការរៀបចំសំលៀកបំពាក់ និងកាយវិការ ហាក់មិនបានត្រូវទៅតាមសាច់រឿងឡើយ ព្រោះគេមិនបានដឹងរឿងពិត ចេះតែថតឱ្យតែបានៗទៅ... ។

## រាហូចាប់ច័ន្ទ

| | | |
|---|---|---|
| **បទភ្លេងនំនុកច្រៀង** | **សម្រួលតន្ត្រី** | **ច្រៀងដោយ** |
| **គន្ធ-ប៊ុនឈឿន** | **ហាស់-សាឡន** | **ស៊ីន-ស៊ីសាមុត** |

១- ថ្ងៃបងជួបអូន ជាថ្ងៃសុបិន
ថ្ងៃដែលមាសឆ្អិន ចង់ប្រហារបង

រាហូចាប់ច័ន្ទ អូនចាប់បងផង
ឥឡូវចំណង ក្លាយជាស្នេហា ។

២- អាធ្រាតណាស់ហើយ បងកើយភ្លៅស្រី
សឡើមជោកជី ប្រស់ព្រំចិន្តា
ចម្រៀងផ្ទុំៗ ក្នុងខ្ទមជរា
ប្រវត្តិស្នេហា ចារដោយលោហិត ។

R- នេះគឺដួងច័ន្ទ ក្នុងដៃរាហូ
ផែនថ្គាល់ទាំងគូ ក្រអូបផ្អែមឆ្អិត
ទឹកភ្នែកស្រីមុំ បងសូមថើបផ្តិត
ចងក្រងដួងចិត្ត នេះបនិត្យលុះក្ស័យ ។

៣- ឥឡូវរាហូ ខ្ទាក់ច័ន្ទវិញហើយ
ឱដួងច័ន្ទអើយ កែវកុំយំអី
បើខឹងនឹងបង បងឱ្យប្រល័យ
ដកកាំបិតខ្វី ប្រហារបងចុះ ។

**BLUE**

I/. B1B4 CC1 - B4C C4C1 I CB4 C1C B4B1 I BB B3B1 BA1 IV
B3B3 B1B3 A1B B3B1 I B4C C1C B4B1 I C4C4 CC3 CC1 IV

II/.------------------------------- B3C C1A1 BB1 IV
R- CC1 C3C3 I C1C3 CC1 I C4C1 CB4 B1B4 CC1 IV
CB3 B1B I B1A1 BB1 I B3B3 CB3 A1B B1B3 IV

✦ ✦ ✦ ✦ ✦

# ភ្លេងមច្ចុរាជ

| បទភ្លេងនិងទំនុកច្រៀង | សម្រួលតន្ត្រី | ច្រៀងដោយ |
|---|---|---|
| គន្ធ-ប៊ុនឈឿន | ម៉ែរ-ប៊ុន | ស៊ីន-ស៊ីសាមុត |

(បទនេះនិពន្ធនិងថតនៅឆ្នាំ 1973 សំរាប់ក្នុងខ្សែភាពយន្តរឿង **ដៃដែក ៣២** របស់ **ផលិតកម្មគ្រប់ជីតាភាពយន្ត** )

**INTRO**-កុសល បងស្តាយណាស់ ដែលមកមិនទាន់ជម្លើមអូន ! អូនមិនគួរស្លាប់ចោលបងសោះ !... បងអស់សង្ឃឹមហើយ !...

១- ភ្លេងមច្ចុរាជ កំណាចឃោរឃៅ
ប្រគុំជង្គ្រៃពា[illegible]កាន់ពិភពថ្មី
ព្រហ្មលិខិត [illegible]ល្យលោករាល់ថ្ងៃ
ក្បត់ទាំងស្នេ[illegible] ប្រល័យឥតក្តីមេត្តា ។

២- ខ្ទែងស្រាករំពង បងឈរមុខផ្នូរ
ផ្កាវាំងរុះរោយក្នុងអួរ ថ្ងូចថ្ងូររកម្ចាស់ឱរា
ក្លិនផ្សែងទៀន ចិញ្ចៀនមុខខ្មោចអ្នកតា
ផែនដីទេវទត្តឫស្យា ប្រហារសង្សារកំសត់ ។

R- នេះហើយឬខ្សែជីវិត ? នេះហើយឬខ្សែជីវិត ?
ជីវិតគ្មានអ្វីទៀងទាត់ វេនកម្មចាំមកពង្រាត់
ឱ្យព្រាត់ស្នេហ៍ទាំងថ្ងូរចត់ សប្បថនៅវត្តភ្នំស្រី ។

៣- ដើមជ្រៃដើមពោធិ កុំឈរស្ងៀមនៅ
ចាក់ធ្លាក់សង្កត់ខ្ញុំទៅ រស់នៅក៏គ្មានន័យអ្វី
ស្លូមភ្នំភ្លើង ផ្ទុះឡើងបំប៉ើងផែនដី
បំផ្លាញចក្រវាឡចង្រៃ ឱ្យក្ស័យតាមម្ចាស់ស្នេហ៍ខ្ញុំ ។

BLUE

I/. C4C1 CB3 B1A1 B1B3 I B3C1 C3C1 B3B4 I B3B1 A1B B3B1 II

A1 B3B4 I B3C1 B3A1 B1B3 I B3C1 C3C0 C1C3 I C4C3 C1B3 B1A3 II

II/. - - - - - - - - - - - - - - - - - - - - B3C1 C3C0 C1C3 I C4C3 B3C4 C3C1 II

R- A1 - A4 B1B3 AA1 IV A1 - A4 B1B3 AA1 III B3 - B1 B3C B1B3 I

C1 I C C1C B3B1 - B B3B1 B A1B - AA1 BB1 B3C IV

III/. - - - - - - - - - - - - ( ប្ដូរ 2$^{0}$ Couplet ) - - - - - - - - - - - - - IV

★ ★ ★ ★ ★

# មន្ទា ស្នេហាបង

| បទភ្លេងនិពន្ធច្រៀង | សម្រួលតន្ត្រី | ច្រៀងដោយ |
| --- | --- | --- |
| គង្គ-ប៊ុនឈឿន | ម៉ែរ-ប៊ុន | ស៊ីន-ស៊ីសាមុត ម៉ែង-រៃន |

(បទនេះនិពន្ធនិងថតនៅឆ្នាំ 1973 បញ្ចូលក្នុងខ្សែភាពយន្តរឿង ដៃដែក៣២ របស់ផលិតកម្មគ្រប់ជីភាពយន្ត)

INTRO. ប- មន្ទា អូននៅឯណា ?

ស- អូននៅលើពពកឯណោះបង !... បង.. ឡើងម៉ោ !...

១.ប- ព្រះអើយសូមបក់យកស្លាបខ្ញុំទៅ យកស្លាបខ្ញុំទៅ

ឱ្យបានជួបពៅ ស្រស់បណ្ដូលស្នេហ៍

រលកដួងចិត្ត ថិតក្រោមដួងខែ

ជាតិនេះមានតែអូនទេ ដែលរៀមថ្នមថៃស្នេហ៍អូនលុះក្ស័យ ។

២.ស- កែវភ្នែកមុតថ្លាប្រហារចិត្តខ្ញុំ ប្រហារចិត្តខ្ញុំ

បងកុំបារម្ភ ថាអូនដោះដៃ

ប- ថ្វីបើរូបបងជាទន្សាយព្រៃ លបលួចគួចស្នេហ៍ច័ន្ទថ្ងៃ

ស- បងកុំភ័យអ្វី លុះក្ស័យអូនស្មោះ ។

R.ប- មន្ទាស្នេហាមាសបង

ត្រូវគ្រងបុព្វេ មានតែអូនទេ ជួយបងឱ្យរស់

ស- អូនលក់បេះដូង ជូនទ្រូងបងស្មោះ

ក្បូនស្នេហ៍លឿនឆ្ពោះ កោះកែវវាសនា ។

៣.ប- បើសិនទូននាងល្មៀងពីរូបបង ល្មៀងពីរូបបង

ជាតិនេះម្ល៉េះហ្មង បងលាមរណា

ស- ត្រែងតែទឹកលោកព្រាត់ចាត់សុរិយា ឬមេឃព្រាត់ដួងច័ន្ទថ្លា

នោះទើបមន្ទា ស្នេហាអស់ក្លិន ។

**BOLERO - LENT**

I/. CC4 CC2 C1C BB2 I BB2 B4C I C2C B4C C2C B4B2 IV

B4B4 BB AB B2B4 I C4C4 DC4 C2C I CC2 CB4 B2B4 CC2 IV

II/. ------------------------------ CC2 CB4 B1B A2B2 IV

R- B I B1 B3C1 CB1 I B3B1 A3B I BB A3B B1B A3A IV

B I C4C2 CC2 I CB B2B4 I CC2 CB4 BB1 CB3 IV

III/.----------- ( ដូច $2^0$ Couplet ) ------------ IV

ooooo

## លាហើយស៊ូម៉ាត្រា

**ប្រវត្តិដើម** - បទនេះ ក៏មានប្រវត្តិស្រដៀងគ្នានឹងបទ **រាហ៊ូចាប់ច័ន្ទ** ដែរ ។ គឺសុទ្ធតែដកស្រង់ចេញពីប្រលោមលោក **រឿងរាហ៊ូចាប់ច័ន្ទ**ដូចគ្នា គឺចង់គ្រដាង ពីឆាកស្នេហាដ៏ផ្អែមល្ហែមមួយ នៅលើកោះស៊ូម៉ាត្រា រវាងរាហ៊ូជាមួយកុលាបឥណ្ឌូណេស៊ីនោះ ។

អ្នកដែលមិនបានដឹងរឿងនេះពិតប្រាកដ ក៏ស្មានតែស៊ូម៉ាត្រាជាឈ្មោះតួអង្គស្រី ក៏នៅតែនាំគ្នាហៅឈ្មោះតួស្រីថា ស៊ូម៉ាត្រា ទៅវិញ ។

សព្វថ្ងៃ បទនេះមានឥទ្ធិពលខ្លាំងណាស់ នៅលើសន្ដានចិត្តអ្នកស្ដាប់ទូទៅ

គឺគេតែងយកបទនេះទៅច្រៀងឆ្លងឆ្លើយ នៅគ្រប់ទីកន្លែងទាំងអស់ ។

ក្រុមហ៊ុនថតចំរៀងកាយវិការ ឬការ៉ាអូខេ ក៏យកទៅថតដាក់តួឱ្យសំដែង មិនសូវដែលខានទេ ដោយគេចាត់ទុកថា ចំរៀងឆ្លងឆ្លើយនេះ ជានិមិត្តរូបនៃពិភពស្នេហ៍នៅលើផ្នែរខ្សាច់ ដ៏ប្រកបដោយក្ដីស្រមើស្រមៃលន្លង់លន្លោចមួយ។

ប៉ុន្តែ មានកំណត់សំគាល់មួយ ដែលគួរឱ្យសោកស្ដាយនិងចងចាំដែរ គឺពេលដែលថតនៅ **Studio** នាង **រស់˗សេរីសុទ្ធា** បានច្រៀងច្រឡំ **Parole** មួយម៉ាត់ នៅក្នុង **Refrain** ត្រង់ពាក្យថា **ចេញខ្សែនេត្រា** បែរជាច្រៀងថា **ដេញខ្សែនេត្រា**ទៅវិញ ។

នេះជាកំហុសដោយអចេតនា ពេលដែលកំពុងថតគ្មានអ្នកណាចាប់ភ្ញីកឡើយ មានតែខ្ញុំជាអ្នកនិពន្ធប៉ុណ្ណោះជាអ្នកដឹង ព្រោះខ្ញុំសរសេរអក្សរ វ និងអក្សរ ដ ច្រឡំគ្នា ។ ជួនជាពេលនោះ ខ្ញុំមានជំងឺ **Surmenace** នៅក្នុង **Studio** មិនបាន ទើបមិនមានអ្នកណាហ៊ានអារកាត់ ចំពោះសូរសៀងនៃទំនុកច្រៀងនេះ ។

នេះក៏ចាត់ទុកជាមេរៀនមួយសំរាប់អ្នកច្រៀងដែរ គឺអ្វីដែលច្រៀងច្រឡំហើយ ទោះជា ៣០-៤០ ឆ្នាំទៅក្រោយទៀត ក៏នៅតែភ័ន្តច្រឡំដដែល ហេតុនេះពេលកំពុងថត ត្រូវតែប្រយ័ត្នប្រយែងផ្ទៀងផ្ទាត់ពាក្យពេចន៍ឱ្យហ្មត់ចត់មែនទែន ជៀសវាងកុំឱ្យអ្នកជាន់ក្រោយ ច្រៀងទៅតាមការខុសឆ្គងនោះដែរ។

## លាហើយ ស៊ូម៉ាត្រា !

| បងគ្លងទំនុកច្រៀង | សម្រួលតន្ត្រី | ច្រៀងដោយ |
|---|---|---|
| គង្គ˗ប៊ុនឈឿន | ហាស់˗សាឡន | ស៊ីន˗ស៊ីសាមុត រស់˗សេរីសុទ្ធា |

១.ស- បិទភ្នែកស្រមៃ ក្នុងដៃប្រុសស្នេហ៍
ខ្យល់សោកបំពេរ ឆ្នេរកោះបាលី
ប- អូនជាកុលាប ឥណ្ឌូណេស៊ី

ស- បងជាឥន្ទ្រីយ ហើរពីដែនឆ្ងាយ ។

២.ប- ឱ្យបខៀវស្រៀវស្រើប ទើបភ្ញិទចរណៃ
បងសូមលាថ្ងៃ ស្រីស្រស់ឆោមឆាយ
លាមួយគ្រាសិន ទាំងក្តីសោកស្តាយ

ស- សូមប្រុសឆោមឆាយ កុំប្រែចិន្តា ។

R.ប- បងមិនភ្លេចទេ អនុស្សាវរីយ៍
បងនិងនារីស្រស់ស្ងំមាត្រា

ស- ខ្វល់ខ្វើយកើយដៃ ក្នុងល្អាងផ្កាស្វា
វេញខ្សែនេត្រា សាងស្នេហ៍រយជាតិ ។

៣.ប- លាហើយ លាហើយ វិថ្មលកោះស្នេហ៍
យ៉ាងយូរវេប់ខែ បងមកជួបទៀត

ស- ឯណាថ្កាល់បង អូនសូមស្រង់ជាតិ
ទោះបីបងឃ្លាត រសជាតិអូនចាំ ។

CODA. ប- លាហើយ ស្ងំមាត្រា (ស)- កុំភ្លេចអូនណា ប្រុសបង !...

**BOLERO - LENT**

I/. B4B4 C1C4 C1C4C1 B4B4 IV B4C1 C2C4 D0C4 C2C1C2 IV
C2C2 C0B4 B2B2 BB II B2B I CC C2C B4C IV

II/.------------------ B2B I CC C2C B2B4 IV

R- CC BB C2C B4C IV CC BB CB4 B2B4 IV
B2B2 B1B1 BB A2B I B4B I B4C C2C B4C IV

III/.------------( ដូច 2$^{0}$ Couplet )--------- IV

* * * * *

# បួតសណ្តែក

| បទភ្លេងទំនុកច្រៀង | សម្រួលតន្ត្រី | ច្រៀងដោយ |
|---|---|---|
| គន្ធ-ម៉ិនឈឿន | ហាស់-សាលួន | ស៊ិន-ស៊ីសាមុត ប៉ែន-រ៉ន |

(និពន្ធនិងថតនៅឆ្នាំ 1973 នៅក្នុងកម្រងកាសែត ឈ្មោះហុងផា កញ្ញា ប៉េសេ)

១- បួតសណ្តែក រទេះពាក់ប្រែក រទេះពាក់ប្រែក នាងលាវដើរបី
បួតសណ្តែក រទេះពាក់ប្រែក រទេះពាក់ប្រែក នាងលាវដើរបី
អស់ទាំងគេ គេជិះដីរ៉ នាងលាវដើរបី ជិះថ្លៃកំដើម
អស់ទាំងគេ គេជិះដីរ៉ នាងលាវដើរបី ជិះថ្លៃកំដើម ។

២- បួតសណ្តែក ក្អែបជិះកក្អែក ក្អែបជិះកក្អែក សេកជិះករុយ
បួតសណ្តែក ក្អែបជិះកក្អែក ក្អែបជិះកក្អែក សេកជិះករុយ
ទៅរើកាត់គេ នៅផ្ទះទីទុយ ឆ្កែតៀហក់ឆ្កុយ ទៅពាំមាន់ឆ្លាង
ទៅរើកាត់គេ នៅផ្ទះទីទុយ ឆ្កែតៀហក់ឆ្កុយ ទៅពាំមាន់ឆ្លាង ។

៣- បួតសណ្តែក ទៅលេងវត្តឯក ទៅលេងវត្តឯក បុណ្យចូលឆ្នាំថ្មី
បួតសណ្តែក ទៅលេងវត្តឯក ទៅលេងវត្តឯក បុណ្យចូលឆ្នាំថ្មី
ទន្សាយរាំវង់ កន្ទង់ថ្មីប៉ី ចង្រិតកន្ធី ប៉ីភ្លែចំរៀង
ទន្សាយរាំវង់ កន្ទង់ថ្មីប៉ី ចង្រិតកន្ធី ប៉ីភ្លែចំរៀង ។

៤- បួតសណ្តែក ទីទុយយំស្រែក ទីទុយយំស្រែក ក្អែកឡុកឆៃយុំ
បួតសណ្តែក ទីទុយយំស្រែក ទីទុយយំស្រែក ក្អែកឡុកឆៃយុំ
សេះលោតសប្បាយ ក្នុងបុណ្យចូលឆ្នាំ ប្រជុំគ្នារាំ ចង្វាក់រាំវង់
សេះលោតសប្បាយ ក្នុងបុណ្យចូលឆ្នាំ ប្រជុំគ្នារាំ ចង្វាក់រាំវង់ ។

**REAM VONG**

I/. B1 BB4 - BB1 BB4 - BB1 BB4 - B4C C4C1 I
B1 BB4 - BB1 BB4 - BB1 BB4 - B4C C4C1 I

C1C1 C4D - C4C1 C4C - B4B1 B4C - B4B1 B4B I
C1C1 C4D - C4C1 C4C - B4B1 B4C - B4B1 B4B I
---------- ( REVISION ) -----------

* * * * *

# ផ្ការបរប៉ៃលិន

| បទភ្លេងនិពន្ធបទចម្រៀង | សម្រួលតន្ត្រី | ច្រៀងដោយ |
|---|---|---|
| គង្គ_ម៉ុនឈឿន | ហាស់_សាឡុន | រស់_សេរីសុទ្ធា |

(និពន្ធនិងថតនៅឆ្នាំ 1973 នៅក្នុងកម្រងកាសែត កម្មោះហុងដា កញ្ញាប៉ៃសេ)

១- យប់មិញភ្លៀងធំ ខ្ញុំយំទល់ភ្លឺ
ទឹកឡើងសែនឈឺ ព្រោះឮផ្ការលាន់ដើមឆ្នាំ
ផ្ការបរប៉ៃលិន និន្នាជេរខ្ញុំ
ថាខ្ញុំចិត្តធំ ហ៊ានក្បត់ចិត្តចោលតួចាស់ ។

២- រោងការមុខផ្ទះ ចាស់ៗសង់ហើយ
និផ្ការលាន់អើយ កុំជៀលថាខ្ញុំផ្តេសផ្តាស
ការពិតខ្ញុំស្មោះ នឹងសង្សារណាស់
តែរឿងប្តូរផ្ទាស់ ក្រឡុះមកពីចាស់ទុំ ។

R- សូមព្រះអង្គខ្មៅ នៅបរយ៉ាខា
មេត្តាសន្តោសទោសខ្ញុំ
ការពិតខ្ញុំស្មោះ នឹងសង្សារខ្ញុំ
រឿងធំ ព្រោះព្រហ្មលិខិត ។

៣- ល្មុះអើយចោកបក់ រោងការចោលទៅ
កុំនាំអាស្រូវ ញាតិជៅថាខ្ញុំក្បត់ចិត្ត
ផ្ការបរប៉ៃលិន សូមអ្នកអាណិត
ខ្ញុំការមែនពិត តែចិត្តស្មោះបងរយជាតិ ។

**SARAVANN**

I/. C1C4 B1B4 CB4 B1C1 II CB4 B1C1 I B4C C1C B4B1 IV
B4B4 B1B4 CB4 B1B II B4A1 BB1 I BB1 BB1 B4C IV
II/. - - - - - - - - - - - - - - - - - - - - - - - - - - BB1 B4C B1B4 IV
R- C1C4 DC1 I CB4 B1C1 I C4C1 CB4 B1C1 IV
C1C4 DD0 I DC4 C1C4 - DC4 C1C B4C IV
III/. - - - - - - - - - - ( ដូច 2[e] Couplet ) - - - - - - - - - IV

* * * * *

# អានិត្យវង្សា ស៊ីសុរិយាវង្ស

| បទភ្លេងទំនុកច្រៀង | សម្រួលតន្ត្រី | ច្រៀងដោយ |
|---|---|---|
| គន្ធ-ម៉ិនឈឿន | ម៉ែរ-ម៉ិន | ស៊ីន-ស៊ីសាមុត |

(បទនេះនិពន្ធនិងថតនៅឆ្នាំ 1972 សំរាប់បញ្ចូលក្នុងខ្សែភាពយន្ត រឿង **អានិត្យវង្សា ស៊ីសុរិយាវង្ស** របស់**ផលិតកម្ម ឈ្មោះសាលមាសភាពយន្ត** )

INTRO- ម្ចាស់បងអានិត្យវង្សា !... ទូលបង្គំស៊ីសុរិយាវង្ស សូមពុះទ្រូង !
សូមពុះទ្រូងថ្វាយ...

១- ផ្ទូរកែវផ្ទូរមាស ផ្ទះលោហិត
ព្រោយដាវឆ្ពូងចិត្ត កំរិតផែនទ្រូងរងយកការពិត
ក្បួនស្នេហ៍ផែកម្ម ស្រែកផ្ដាំជីវិត
លាហើយទ្វីបលោកងងឹត បូជាចំពោះពិត អង្គព្រះជេដ្ឋា ។

២- យកទឹកឈាមត្រី យកស្រីលាងបាប
តស៊ូលុតក្រាប ខ្វែងនាគឆក់ឆាបស្នេហ៍ពីឧរា
ភាំងធនជីវិត បិទទ្វារវាសនា
ព្រោងលានចំអកឱ្យថា សុរិយាឆ្ងាយជីគ្មានថ្ងៃព្រាត់គ្នា ។

R- គ្រួសារទាំងអស់ ដែលរស់ក្នុងលោក

មានជ័យខ្វះជោគ ម្នាក់រៀងម្នាក់រោគទុក្ខសោកក្រាំក្រា
អ្នកហ៊ានលះបង់ គេដៀលថាណា
ចុះរូបខ្ញុំដែលបូជា ឥន្ទព្រហ្មយក្សមានិន្ទាឬអ្វី ? ។

៣- ក្លិនស្រីបងស្រូប ស្រៀវស្រើបវិញ្ញាណ
មិនគួរឃ្លាតបាន មិនគួរកល្យាណរុញច្រានលោកីយ
ជាតិក្រោយជាតិមុខ សូមសុខជាថ្មី
ជាតិនេះអប្រិយ គោធិកម្មអវិចិប្រល័យស្នេហ៍យើង ។

CODA- ភ្លងអមរិន្ទ ! អាទិត្យវង្សា ! ខ្ញុំសូមលាហើយ !...

**BLUE - FOLK**

I/. C1C C1C C1B B1B3 I CC1 I A1B - A1A1 BB1 B3C B1B3 IV
C3C3 DB3 CB3 CC1 I CB3 B1B3 BB1 I A1A3 BB1 B3A1 A1A1 IV

II/. ------------------------------A1A3 BB1 A1B BB IV

ឃ- C1B3 C1C C1B3 CC I C1C B3B1 I B3A1 B3B1 B3C B1B3 IV
C3C3 DB3 CB3 CC1 I A1A1 BB1 B3B3 I CC C1C C1C C1B5 IV

III/. ------------( ប្ទូប 2e Couplet )----------IV

* * * * *

## សម្ពាយកម្ម

| ចងភ្លេងដឹកនាំការច្រៀង | សម្រួលតន្ត្រី | ច្រៀងដោយ |
|---|---|---|
| គន្ធ_ម៉ិនឈឿន | ម៉ែ_ម៉ិន | ស៊ិន_ស៊ីសាមុត |

(បទនេះនិពន្ធនិងថតនៅឆ្នាំ 1973 ថតនៅកម្រងកាសែ្សតពស់មាស បញ្ចូលក្នុង ប្រលោមលោករឿង **ភ្លេងការ ភ្លេងកម្ម** )

**INTRO-** កូនមាសម្តាយ ! កូនស្លាប់ចោលម្តាយហើយ ! ម្តាយឈឺចាប់ណាស់ ! មិនគួរនឹពុកកូន គេបំភ្លេចរូបម្តាយនិងកូន ហើយទៅរៀបការចោលម្តាយសោះ ម្តាយត្រូវតែបីសពកូនចូលរោងការដើម្បីចងដៃឪពុកកូន !...

១- ភក្ដីបីក្ខន លួនឡើងរោងការ ទាំងទឹកនេត្រា
ស្រក់លើខាន់ស្លា ស្នេហាចុកឈាម
ចងដៃសពក្ខន ល្ខានស្នេហ៍ចៅព្រាហ្ម
ភ្លេងការតំរាម ស្ងត់ឈាមតំរក់នរកលោកីយ៍ ។

២- ថ្ងៃសុក្រនាងស៊េច ប្រមែ្យងនឹងស្នេហ៍
ថ្ងៃសៅរ៍ប្រួលប្រែ ទឹកប្រាក់មំបែរភ្លែកនាងនឹថ្លី
ឆាកល្ខោងទន្សាយ ក្លាយជាពង់សីហ៍
ចាយខុនចងដៃ ឲ្យបស្រីថ្ងៃឲងដៃសពក្ខន ។

R- និសម្ដាយកម្ម ចាំតែសង្កត់
រូបស្រីកំសត់ ឱ្យព្រាត់ភពស្នេហ៍សោះសូន្យ
ទឹកសំបូទឹកភ្នែក ដើងមេឃនិងក្សួន
នឹកាត់ទោសក្ខន ជំនួនទឹកភ្នែកសោកា ។

៣- រឿងមនុស្សជារឿង ដានគង់រទេះ
ជួបគ្នាថ្ងៃនេះ ថ្ងៃស្អែកក៏ប្រេះបែកពីឧរា
សម្ដាយទឹកភ្នែក សែនថ្នូរបុត្រា
ដូចពាក្យលោកថា អារសាច់ជូនខ្លាទើបនៅស្រុកបាន ។

**SLOW**

I/. C1C1 C1C4 - B4C C4C1 I B4C C4C1 CB4 I [illegible]1B4 B3B1 IV
B1B3 I B1B B1B3 BB1 I C1C4 DB4 - B1B1 B4C C1C4 CC1 IV
II/. ------------------------------ B1B1 B4C C1B4 B3B1 IV
R- C1C1 C4C4 DC4 C1C1 I B4C B4C1 C4C - B1C B1B4 B3B1 IV
BBBB I B1B4 A1BB1 I C1C4 DB4 - B1B1 B4C I C1C4 DD IV

* * * * *

# ម្លប់ស្នេហ៍ដើមស្រឡៅ

**ប្រវត្តិបើម** - កាលពីឆ្នាំ 1973 ខ្ញុំបានសរសេរប្រលោមលោកមួយ ឈ្មោះថា "**ជំនោរប៉ៃលិន**" ដោយសាររឿងនេះ មានប្រជាប្រិយភាពខ្លាំងចំពោះអ្នកអាន ទើបលោក **សុ៱ម៉ាន់ឈីច** អ្នកដឹកនាំរឿងប្រចាំ**ផលិតកម្មចន្ទច័ន្ទភាពយន្ត** បានមកសុំទិញរឿងនេះ យកទៅថតជាខ្សែភាពយន្ត ។

ទន្ទឹមនោះ ផលិតកម្មនេះក៏បានសំណូមពរឱ្យខ្ញុំ តែងបទចំរៀង ៤ បទ សំរាប់បញ្ចូលទៅក្នុងខ្សែភាពយន្តនេះផងដែរ គឺ **បទម្លប់ស្នេហ៍ដើមស្រឡៅ៱ ទំនួញត្អឹតាមាស៱ជំនោរប៉ៃលិន និង បេះដូងកំព្រា** ។

ប៉ុន្តែ ក្រោយពីបទទាំងបួននេះចេញផ្សាយហើយ មានការនិយមខ្លាំងពីអ្នកស្តាប់ ទើបគេសុំទិញយកទៅបញ្ចូលក្នុងថាស និងក្នុងកាសែ្សត ។

គួរឱ្យស្តាយណាស់ ភាពយន្តរឿងជំនោរប៉ៃលិន ថតមិនទាន់បានចប់ មិនទាន់បានបញ្ចាំងនៅឡើយ ស្រាប់តែព្រឹត្តិការណ៍ 17 មេសា បានមកដល់។

ចំពោះបទម្លប់ស្នេហ៍ដើមស្រឡៅ លោក**ស៊ីនស៊ីសាមុត** និងនាង **រស់សេរីសុទ្ធា** បាននិយាយថា ជាបទដែលលោកនិងនាងខំច្រៀងអស់ពីសមត្ថភាព និងអស់ពីមនោសញ្ចេតនា ។

ថ្វីបើពាក្យពេចន៍ទំនុកច្រៀង មានរៀបរាប់សុទ្ធតែឈ្មោះជាក់ស្តែងនៃតំបន់ នៅភូមិភាគប៉ៃលិន ប៉ុន្តែ **Melodie** ផ្អែមត្រជាក់ ធ្វើឱ្យសាច់បទកាន់តែពិរោះអណ្តែតអណ្តូង លន្លង់លន្លោចណាស់ទៅទៀត ។

នៅមានអនុស្សាវរីយ៍មួយទៀត ដែលធ្វើឱ្យខ្ញុំខ្លោចផ្សាពន់ប្រមាណ គឺខ្ញុំបានជួបនឹងលោក**ស៊ីនស៊ីសាមុត** នៅវត្តចំប៉ា ឃុំព្រែកឯង ពេលប៉ុលពតជម្លៀសចេញពីភ្នំពេញនៅឆ្នាំ 1975 ។ ពេលនោះ គាត់អង្គុយត្របោមក្បាលជង្គង់នៅលើផ្ទះឈើមួយ យកដៃអង្អែលក្បាលទំពែកតិចៗ ដែលមានពួកខ្មែរ

សិយមែន! ថ្ងៃនេះចំជាថ្ងៃស៊ិយ មកជួបតយដេកពាំងចំកណ្ដាលផ្លូវ។

ពោល.ស- នែ៎ កុំមាត់ខ្លាំងពេក ប្រយ័ត្នឆ្មាភ្ញាក់ណាំ !...

ប- ចាប់ជាប់ហើយ !.. ជាប់ហើយ... កុំរើទៅណា !....

៣.ប- ស្ងៀមកុំរើកុំរត់ ប្រយ័ត្នខាំដាច់កន្ទុយ
ថ្ងៃនេះហុងស៊ុយ ចាប់បានកណ្ដុរស៊ីស្រូវ

ស- និបងឆ្មាអើយ មេត្តាដោះលែងខ្ញុំទៅ
ខ្ញុំស៊ីតែស្រូវ មិនដែលស៊ីសាច់ម្ដងទេ (ពីរដង) ។

៤.ប- បើព្រមស្រឡាញ់ខ្ញុំ ទើបខ្ញុំមិនខាំហែកស៊ី
យើងរួមជីវិ រួមចិត្តគ្មានគិតឃ្នាន់ឃ្នេរ ចែកគ្នាម្នាក់មួយគ្មានព្រួយ
គ្មានចិត្តបែកទេ

ស- ខ្លាចញាតិជៀលជេរ ថាយើងខុសពូជពង្សទៅ (ពីរដង) ។

R-ប- ខុសពូជ តែយើងជាសត្វដូចគ្នា ស្នេហាមិនរើសពូជពង្សទេពៅ

ស- ក្រចកបងឯងវែងហើយមុតជ្រៅ ថ្ងៃក្រោយទៅ មុខជាបោកប្រាស់
យើងហើយ ។

៥.ប- បងមិនបោកប្រាសទេ មាសមេកុំព្រួយឱ្យសោះ បងពិតជាស្មោះ
ចំពោះតែស្រស់ត្រាណត្រើយ ហាំ! ហាំ! ហាំ! ហាំ! យើងរួមស្នេហ៍
ទៀតកើយ

ប+ស- ពីនេះតទៅអើយ គ្មានអ្វីអាចបំបែកបាន (ពីរដង)...

CODA- ក្នុងសួនច្បារ ស្នេហាឆ្មានិងកណ្ដុរ ! ក្នុងសួនច្បារ ស្នេហាឆ្មានិង
កណ្ដុរ...

[illegible]

[illegible] C1C B4B3 - BC C1C B4B3 I BB B1B3 I BB1 B4B3 BB1 I
[illegible] BA - BA BA BB1 I BB1 CB3 - B4B3 BB3 B4C I
BB1 CB3 - BB1 CB3 B1B I

R- CC4 I C4C C4C C4C3 II CC3 I C3C C3C C3C1 II
CC1 I CC1 C3C4 D1D II CD1D - D1D D1C C1C4 II

# សារ៉ាវ៉ាន់ស្លៀកខ្យល់

**ប្រវត្តិបើច** - បទនេះ ខ្ញុំនិពន្ធនៅឆ្នាំ 1973 សំរាប់បញ្ចូលក្នុងខ្សែភាពយន្តមួយរឿងឈ្មោះថា **ស្លៀកខ្យល់ជន្លប់មេឃ** របស់ផលិតកម្មឃ្លាំងមឿងភាពយន្ត ដែលដឹកនាំដោយខ្ញុំផ្ទាល់ ។

គួររំលឹកឡើងវិញថា ពេលដែលខ្ញុំតែងបទនេះរួច ខ្ញុំពិបាករកអ្នកច្រៀងណាស់ ព្រោះខ្ញុំចង់ឱ្យអ្នកច្រៀងបទនេះ អាចទៅសម្តែងផ្ទាល់ក្នុងខ្សែភាពយន្តនោះទៀតផង ដោយមិនចាំបាច់មកសំដែងហើយចាក់សម្លេងដាក់ពីលើ ដូចជាភាពយន្តដទៃ ។

រើសចុះ រើសឡើង ខ្ញុំក៏សំរេចយកនាង**សុសារឿន** ជាអ្នកច្រៀងបទនេះ ព្រោះសម្លេងនាងអាចស៊ីនឹងភាពរញ្ជាក់រញ្ជួររបស់ **Melodie** ដែលមានកន្ទែងបង្ហួសវែង។ ទៅតាមទំនួលបទ របស់បងប្អូនខ្មែរនៅភាគឥសាន ឬជនជាតិឡាវនៅខេត្ត សារ៉ាវ៉ាន់ ។

មិនតែប៉ុណ្ណោះ នាង**សុសារឿន** ក៏មានទេពកោសល្យពិសេស អាចសំដែងចេញក្នុងខ្សែភាពយន្តរបស់ខ្ញុំបានទៀតផង ទើបនៅពេលដែលកុននេះដាក់បញ្ចាំងនៅរោងភាពយន្តសុរិយា មានទស្សនិកជនជាច្រើន ភ្ញាក់ផ្អើលនាំគ្នាចូលទៅមើល ព្រោះគេមិននឹកថានាងសុសារឿន អាចសំដែងបានល្អយ៉ាងនេះ ។ ពិសេស មិនមែននៅលើសាច់រឿងប៉ុណ្ណោះទេ គឺនៅលើសាច់បទនេះតែម្តង ដែលអ្នកស្តាប់ទាំងឡាយមានការរន្ធត់ញាក់ញ័រ ហើយប្លែកត្រចៀកជាខ្លាំង ។

សព្វថ្ងៃនេះ **បទស្លៀកខ្យល់ជន្លប់មេឃ** នៅតែមានគេនិយមច្រៀងតាមវេទិកាតន្ត្រីផ្សេងៗ ប៉ុន្តែខ្លះក៏លេងជាចង្វាក់ **Saravan** សុទ្ធ ខ្លះទៀតក៏ប្រគុំជាបទរាំវង់តែម្តង ។

សូម្បីនាង**សុសាវឿន** និងលោក**កែវ ឆែម** បានបែកឃ្លាតពីគ្នា គឺម្នាក់ទៅរស់នៅឯបរទេស និងម្នាក់ទៀតឃ្លាតទៅពិភពថ្មីដោយមិនមានពេលត្រឡប់មកវិញក៏ដោយ ក៏ខ្ញុំនៅតែសូមឧទ្ទិសបទនេះដល់អ្នកទាំងពីរ ដែលបានជួយជ្រោមជ្រែងខ្ញុំយ៉ាងពេញទំហឹង ដើម្បីធ្វើឱ្យបទនេះបានសំរេចឡើង និងមានជីវិតរហូតមកដល់សព្វថ្ងៃ... ។

នាង**សុសាវឿន** មិនត្រឹមតែបានទទួលកិត្តិយសជា វៃមាសមានស្នេហ៍ប៉ុណ្ណោះទេគឺនាងជាមាតា សារ៉ាវ៉ាន់ ស្មៀកខ្យល់ដ៏មិនចេះសាបសូន្យទៀតផង។

## សារ៉ាវ៉ាន់ស្លៀកខ្យល់

| បទភ្លេងនិពន្ធប្រៀង | សម្រួលតន្ត្រី | ច្រៀងដោយ |
|---|---|---|
| គន្ធ ម៉ិនឈឿន | កែវ ឆែម | សុ សាវឿន |

INTRO- អ៊ូ ! អ៊ូ ! អ៊ូ !... សូមអញ្ជើញ !.....ម៉្លោ !... រាំលេង
ចូលមកចុះ ប្រុសឬស្រី ចាស់ឬក្មេង មករាំលេង Saravan
ឥតប្រកាន់ឡើយ !...

១- ស្លៀកខ្យល់ សារ៉ាវ៉ាន់ ស្លៀកខ្យល់
ស្លៀកខ្យល់ សារ៉ាវ៉ាន់ ស្លៀកខ្យល់ ដណ្តប់មេឃ សារ៉ាវ៉ាន់អើយ!
មកស្លៀកខ្យល់ មកដណ្តប់មេឃ ណា !

- ក្រុមនេះទើបនឹងបើកថ្មី ជនប្រុសស្រីរង់ចាំយូរលង់
រៀបចំលួត្រចង់ រាំវង់• រាំវង់ សារ៉ាវ៉ាន់ !
សារ៉ាវ៉ាន់បង់ចោយ បង់ចោយ បង់ចោយសារ៉ាវ៉ាន់
រាំបង់ចោយ សារ៉ាវ៉ាន់អើយ !... ។

២- ស្លៀកខ្យល់ សារ៉ាវ៉ាន់ ស្លៀកខ្យល់
ស្លៀកខ្យល់ សារ៉ាវ៉ាន់ ស្លៀកខ្យល់ ដណ្តប់មេឃ សារ៉ាវ៉ាន់អើយ!
មកស្លៀកខ្យល់ មកដណ្តប់មេឃ ណា !...

- ក្រុមនេះល្បីឈ្មោះសំខាន់ មកកំសាន្តបានអាយុវែង
អញ្ជើញចាស់ឬក្មេង រាំលេង រាំលេង សាវ៉ាវ៉ាន់
សាវ៉ាវ៉ាន់ទៅមុខ ទៅមុខ ទៅមុខសាវ៉ាវ៉ាន់
រាំទៅមុខ សាវ៉ាវ៉ាន់អើយ !... ។

៣- ស្មៀកខ្យល់ សាវ៉ាវ៉ាន់ ស្មៀកខ្យល់
ស្មៀកខ្យល់ សាវ៉ាវ៉ាន់ ស្មៀកខ្យល់ ផណ្ដប់មេឃ សាវ៉ាវ៉ាន់អើយ!
មកស្មៀកខ្យល់ មកផណ្ដប់មេឃ ណា៎ !
- មកស្រូបយកខ្យល់អាកាស មេឃស្រឡះ អប់ក្លិនបុប្ផ
ស្រីស្អាតដូចទេវតា ត្រៀបគ្រាដើរកំសាន្តសាវ៉ាន់
សាវ៉ាវ៉ាន់ថយក្រោយ ! ថយក្រោយ ថយក្រោយសាវ៉ាវ៉ាន់
រាំថយក្រោយ សាវ៉ាវ៉ាន់អើយ !...

**SARAVANN**

I/. B3C1 - CC4C1 B3C1 II C1D1 D D4D1 C1D1 I C4 D1D - DC4 DD1 II
C4DD1 - DC4 DD1 DC1 II
- D1D4 D1D4 D1C1 I C1 D1D4 DD1 D4D1 II C4C4 D C4D D1 II
C4D C1C4 CC1 II C C1C1 C1C1 I C1C4 C1C4 C1C1 I C4 DC1 -
C1C4 DD1 II
(REVISION)

❀ ❀ ❀ ❀ ❀

## បទដើរកាត់ភ្លៀង

**ប្រវត្តិបើច** - បទនេះ ខ្ញុំតែងនៅក្នុងអំឡុងឆ្នាំ 1973 ដែរ ដោយថតជាថាស និងបញ្ចូលក្នុងកម្រងកាព្យស្នេហ៍ "ស្នេហ៍មាស" ។
នេះជារឿងពិតរបស់ [illegible] [illegible] ដែលបាននិយាយប្រាប់ខ្ញុំ ពីវិបត្តិស្នេហា

របស់គេ ជាមួយនារីម្នាក់នៅភូមិចាក់ព្រា ក្នុងខេត្តបាត់ដំបង ។ គេបានជួប នាងដោយចៃដន្យ ពេលដែលគេដើរកាត់ភ្លៀងចូលទៅជ្រកស្បៃរងស្សរផ្ទះនាង។

ពេលនោះ គេឃើញនាងនៅផ្ទះម្នាក់ឯង តែគេឥតហ៊ានឡើងទៅលើផ្ទះ ឡើយ ព្រោះខ្លាចប្រពៃណីថាមិនសមរម្យ ។ ទោះបីយ៉ាងនេះក្តី ក៏យុវជននោះ ឈរសម្លឹងដំណក់ទឹកភ្លៀង ហើយស្រមៃដូចជាខ្លួនគេបានសារសងជាមួយធីតា នោះ ដោយសុំផាហ៊ីនាងជណ្តប់ ព្រោះគេរងាខ្លាំងពេក ។

នារីនោះស្អាតណាស់ ជាកូនអ្នកទន្ទេជីស្រគត់ស្រគំ ។ កន្តុយភ្នែកងីពោរ ពេញដោយមន្តស្នេហ៍របស់នាង បានធ្វើឱ្យបេះដូងគេរំភើបញាប់ញ័រ និងទុក នាងជាបុប្ផាមួយទង ដែលចិតក្នុងការថែរក្សារបស់ប្រពៃណីខ្មែរដ៏ថ្លៃថ្នូរ គឺក្រមុំ ចូលម្លប់ ។

អំណាចសេចក្តីស្នេហារបស់យុវជននេះ បានធ្វើឱ្យខ្ញុំជាអ្នកនិពន្ធជួយបក ស្រាយតាមរយៈមនោសញ្ចេតនា ដ៏អាថ៌កំបាំងមួយ ដែលមានភាពជាអមតៈ រហូតមកដល់សព្វថ្ងៃ ។ សូមបារមី ព្រះពុទ្ធអង្គនៅវត្តពាមសីមា ជួយថែរក្សា ព្រលឹងលោក **ស៊ីន‿ស៊ីសាមុត** ឱ្យបានទៅចិតនៅឋានសុគតិភពជាប់ជានិច្ច ព្រោះលោកបានច្រៀងបទនេះ យ៉ាងជាទីពេញចិត្តរបស់ម្ចាស់រឿងអាថ៌កំបាំង...

ជីវិតយុវវ័យ តែងជួបប្រទះ នូវរឿងរ៉ាវស្នេហាច្រើនបែបច្រើនប្រការ ណាស់ តែប្រការដែលសំខាន់ ស្នេហារបស់យុវវ័យប្រៀបដូចជាពន្លឺអំពិល អំពែក... ឬប្រៀបដូចជាផ្កាវបាក់ខ្នង ដែលបោះប្រមោយប្រាថ្នារកចាប់ភពថ្មី ជានិច្ច... ប៉ុន្តែបើមិនបានជួបអ្វីថ្មីទេ នោះគេក៏ក្រៀមក្រំអស់សង្ឃឹម ដូចជា កង្កែបនៅបាតអណ្តូងដ៏គួរឱ្យខ្លាច... ។

# បទដើរកាត់ភ្លៀង

| និពន្ធទំនុកច្រៀង | សម្រួលតន្ត្រី | ច្រៀងដោយ |
|---|---|---|
| គន្ធ-ប៊ុនឈឿន | ហាស់-សារឿន | ស៊ិន-ស៊ីសាមុត |

១- បងដើរកាត់ភ្លៀង ឆៀងចូលផ្ទះស្រី
ភ្លៀងធ្លាប់បើកថ្ងៃ វែលែងហានយំ .
បងរងាពេក ស្រែកទារផាហី
គ្រានោះ ស្រីមុំកំពុងចូលម្លប់ ។

២- ភ្លៀងមិនព្រមរាំង ឃាំងរូបខ្ញុំហើយ
ទៅមិនរួចឡើយ រហូតដល់យប់
ជាប់ភ្លៀងជាប់ស្នេហ៍ ដូចគេសន្ទប់
អូននៅក្នុងម្លប់ មិនហ៊ានវាចា ។

R- បងបានជាប់ចិត្ត លើទាវតូចតន់
កាលអូនទៅបុណ្យ វត្តពាមសីមា
ក្រពើអណ្តែត ស្រែកប្រាប់បងថា
រូបស្រីពុំងា គូព្រេងនឹងបង ។

៣- តំបន់បាក់ព្រា នាស្រុកសង្កែ
បងសូមថ្នមថៃ ផ្ការីកជាប់ទង
អូននៅក្នុងម្លប់ ខានជួបមុខបង
បីខែកន្លង បងសូមរៀបការ ។

**BOLERO - LENT**

I/. C4C1 CB4 B2C B2B4 IV B4B1 BB4 B4C C4C1 IV
C4C1 C4D C4D C1C4 II CC I C1C B4C2 C4C IV
II/. - - - - - - - - - - - - - - - - - - - - CC I C2C B4B2 CB4 IV
R- B4B4 B2B2 B1B A2B II AA2 BB2 I CC2 C4C IV
C2C C2C4 C2C B4B2 I CB I B2B4 B2B4 CC2 IV
III/. - - - - - - - - - - - - - ( ដូច $2^0$ Couplet ) - - - - - - - - -IV

# ទំនួញស្នេហ៍ព្រះជិន្នវង្ស

បទភ្លេងនិពន្ធក្រៅទៀន សម្រួលតន្ត្រី ច្រៀងដោយ
គន្ធ៘ម៉ិនឈឿន ម៉ែរ៘ម៉ុន រស់៘សេរីសុទ្ធា

(បទនេះនិពន្ធនិងថត នៅឆ្នាំ 1972 សំរាប់បញ្ចូលក្នុងខ្សែភាពយន្តរឿង **ព្រះជិន្នវង្ស** របស់**ផលិតកម្មប្រាសាទមាសភាពយន្ត**)

**INTRO**-ព្រះជិន្នវង្ស ! ព្រះជិន្នវង្ស ! ឱព្រះស្វាមីអើយ
ស្ដេចព្រាត់ទៅណាហើយ ខ្ញុំម្ចាស់កន្សើយ ព្រោះទឹកភស្នា !

១- ម៉ឺនសែនពិលាប ជ្រាបពេញទ្រូងឧរ
ចាំស្នេហ៍ចងស្មន្ស ដូចក្សន្រព្រាត់វាសនា
សព្វក៏វេទនាម្ចាស់ ចិត្តព្រានចង្រៃប្ញស្សា
ផ្សែងភ្លើងទុក្ខគ្រា ប្រាថ្នាប្រល័យ
- សាងអំណត់សំបថទឹកភ្នែក ស្ដាយពុនរែកខ្មោះវែកលោកិយ៍
ឈឺក្រៃកំម្លាយមិនរា ! ឱព្រហ្មលិខិត ម្ដេចមិនមេត្តាដល់ខ្ញុំផង ។

២- ហង្សមាសវះមេឃ ហែកលោកឱ្យព្រាត់
ជាតិនេះជួរចត់ ព្រាត់កូនទាំងម្ដាយហ្មង
សំបថពេជ្ឈឃាត ឱ្យអូនឃ្លាតក្ដីបំណង
ទឹកគ្រាស្នេហ៍ស្នង រួមរ័ក្សនឹងរៀម
- តើឱ្យអូនឆ្លើយតបយ៉ាងណា ខ្យល់ព្យុះភ្លៀងច្រៀងតែទុក្ខា
អនិច្ចា ភពឥតកោះត្រើយ...

R- សុរិយាអើយកុំរះ ! សុរិយាអើយកុំរះ ! កុំរះធ្វើអ្វី ទ្រាំរែកស្នើរ
ក្ស័យទៅហើយ និស្សត្រគ្រាណាត្រើយ ! ..អូនមិនដឹងឆ្លើយ ប្រាប់
យ៉ាងណាទេ !...

៣- ឱបក្សីអើយ អ្នកហើរទៅណា ?
សូមនាំវាចា ទៅទូលស្វាមីកំសត់

លោហិតខ្ញុំហូរ ស្ទើរស្ងួតទាំងក្ដីអំណត់

បើសិនជាព្រាត់ ស្លាប់ដោយភក្ដី

- [illegible] កម្មជំពាក់អន្ទាក់លោកីយ៍

[illegible]

CODA- [illegible] ! [illegible]ឱ្យឆាប់មក !

BOLERO - [illegible]

I/. C1C4 [illegible] DD1D C4C1 I C4C1 CC1 B4C I
B3C[illegible] - B4C C1C4 I DC3 C1C3 CC1 IV -
B1BB1 B4C C1C4 I C1CC1 C4C1 C4D - C4D1 DD DD I
C1C4B1 B4C I B4 C1C CC I B3 B1B3 BB1 IV

II/. - - - - - - - - - - - B4 C1C CC I B3 B1B3 BB1 IV

R- C1C4 B1B4C IV C1C4 B1 B4C IV C1 - C4 - C1C4 - D - D - IV
D2D1 DD1 C4C1 I C1C4 B1 B4C - C1C B4C B1B3 BB4 IV

● ● ● ● ●

## កុំខឹងណាំថ្លៃ !

| បទភ្លេងពិនពាទ្យ | សម្រួលតន្ត្រី | ច្រៀងដោយ |
| --- | --- | --- |
| គន្ធ ម៉ិនឈឿន | ហាស់ សាឡន | ស៊ិន ស៊ីសាមុត ស៊ុម ឆួច |

(បទនេះនិពន្ធនិងថតនៅឆ្នាំ 1974 ក្នុងកាសែ្សត ពស់មាស)

INTRO- ហ៊ឺ មិនដឹងលេងអី អីចឹងទេ ! ក្ដៅមិនទាន់ចាត់ផង !...ចេញទៅ វិញទៅ !...

១-ប- ព្រលឹងកុំខឹងណាំថ្លៃ ពីម្សិលម៉្ងៃ បងឃើញអូនមុខក្រញូវ
ទើបថ្ងៃនេះ បងសូមសួរចិត្តពៅ

ស- ចេញទៅ ! ចេញទៅ ! គាមក្ដៅចង់តែខាំហែក ! ។

២.ប- ខាំចុះ ! ខាំចុះ ! ខាំចុះ ! ខាំប្រមុះ ខាំត្រចៀកឬខាំភ្នែក

ស- ខាំក្បាលពោះ ខាំភ្លៅ ខាំហើយហែក
ប្រុសអីចម្លែក ចិត្តបែកបេះបីប្អូនព្រាំ ។

R.ប- យល់ខុសហើយពិសី បងស្ម័គ្រស្រី លុះដល់ក្ស័យមិនប្រេះស្រាំ
បងមិនប្រែចិត្ត (និយាយ) កុំលេងខាំក្បាលពោះ និងគល់ភ្លៅ
បងរសើបណាស់ !...

ស- រសើបក៏នៅតែខាំ កុំឱ្យរេជាបីប្អូនព្រាំ ខាំទុកជាស្នាមចែកកូន ។

៣.ប- អើយ៉ូយ! អើយ៉ូយរាងហើយ ម្ចាស់ថ្លៃអើយខាំក្បាលពោះចង់ធ្លាយព្រូន
កុំខាំងពេក ប្រយ័ត្នដាច់សរសៃកូន

ស- មុខដូចប្រុសស្ងួន ចង់បានកូនយកមកធ្វើអ្វី ?

(------- ភ្លេង --------)

៤.ប- អើយ៉ូយ! អើយ៉ូយរាងហើយ ម្ចាស់ថ្លៃអើយខាំក្បាលពោះចង់ធ្លាយព្រូន
កុំខាំងពេក ប្រយ័ត្នដាច់សរសៃកូន

ស- មុខដូចប្រុសស្ងួន ចង់បានកូនយកមកធ្វើអ្វី ? ។

៥.ប- ព្រលឹងសុំស្លាប់ចង់លិច វែរមាសឆ្អិន កុំចោទថាបងមានស្រី

ស- ផ្លូវផ្អកណាក៏ចង់បណ្តើរពីឆ្វេងម៉ែ កៀកកើយកាន់ដៃ សាក្សីក៏ខ្ញុំមានដែរ

R.ប- យល់ខុសហើយណាពិសី បងស្ម័គ្រស្រី លុះដល់ក្ស័យគ្មានកែប្រែ អូន
ព្រិលភ្នែកហើយ

ស- (ពោល) មិនមែនព្រិលភ្នែកទេ ខ្ញុំឃើញបងឯងបីបីគ្នាទៀតផង
បងថាស្ម័គ្រអូនមិនប្រែ តែមិនបានប៉ុន្មានខែ បងប្រែដោះដៃរកថ្មី ។

៦.ប- ចាប់ពីថ្ងៃនេះទៅ សូមពាលពៅជឿចិត្តបងចុះ ណាំថ្លៃ
បងស៊ូស្លាប់ ស្មោះនឹងអូន លុះដេកដី (ស)- បើពិតដូចបងស្តី
ចរណៃឈប់ខឹងទៀតហើយ

**CODA.** ស- បើពិតដូចបងស្តី (ប)- ចរណៃឈប់ខឹងទៀតទៅ !...

**BOLERO - CHACHA**

I/. B3C1 I C3C4 I C3C1 III CB3C1 CB3B1 BCB3 III
B3CC1 CB3B1 BB3B1 I A1B A1B B3C I BB1 B3C C1B3 III

II/.-------------------------------- BB1 B3C C1B III

R- C1 I C3C4 I C4C4 II CB3C1 CB3B1 BCB3 II C1C - C4C1 -
( និយាយ) CC1 CB3 CB1 - B3 B1B B1B3 CB1 - C1C C1B5 CC1 III

III/.------------ ( ដូច $2^0$ Couplet ) ------------ III

⊛ ⊛ ⊛ ⊛ ⊛

# ទិញស្រាឱ្យឪ !

| បណ្ដូលគំនុតច្រៀង | សម្រួលតន្ត្រី | ច្រៀងដោយ |
|---|---|---|
| គង្គ ម៉ុនឈឿន | កែវ អែម | តូច តេង សុ សាវឿន |

(បទនេះនិពន្ធនិងថតនៅឆ្នាំ 1974 សំរាប់បញ្ចូលក្នុងខ្សែភាពយន្តរឿង **ស្នេហ៍ខ្យល់ដណ្ដប់មេឃ**)

**INTRO.**(ពោល) ប-នែ៎កូន ចាំអីទៀត ទៅទិញស្រាឱ្យឪ !.. លឿនឡើង !
ស- ចា៎ !..ចា៎ !..ខ្ញុំទៅហើយ....ពុក !...

១.ប- នាងទៅណា ក្រោមសុរិយាថ្ងៃ
ស- ទិញស្រាឱ្យឪ ពៅកុំសង្ស័យ
បើយឺតគាត់វៃ វៃៗខ្នងខ្ញី ។

២.ប- ចូលមកសិន មកយកកូនផ្កាមួយពីរ
ជូនគាត់ក្មេកស្រា ណាំស្រស់នារី
កូនផ្កាមកូនតី កូនត្រីក្រីមផ្កា ។

R.ស- លឿនឡើង ! លឿនឡើង ! លឿនកុំបង្អង់
ចាប់ដាក់ក្នុងថង់ភ្ជាមរ៉ា
ញាំផ្កាម ញាំត្រី ជូនឪក្មេកស្រា

ករុណាខ្មែរ

ធ្វើទាន ដោះទុក្ខ កសាង

CAMBODIAN•EDUCATION•EXCELLENCE

មូលនិធិខ្មែរសម្រាប់ការសិក្សា

FOUNDATION